# បដ្ឋានបករណ៍

ថ្ងៃ ពុធ ១ រោច ខែ អាសាឍ ឆ្នាំ ច

អដ្ឋស័ក ព.ស ២៥៥០

ឆ្នាំ ២០០៦

បង្រៀនដោយ

**លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស**

( នៅសាលាសតិប្បដ្ឋានខេត្តបាត់ដំបង )



## ពាក្យប្រារព្ធ

ខ្ញុំព្រះករុណាខ្ញុំបាទមានសេចក្ដីជ្រះថ្លា រៀបរៀងសៀវភៅមហាបដ្ឋាន ដែលបង្រៀនដោយលោកគ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** នាវស្សាក្នុងឆ្នាំ ច អដ្ឋស័ក ព.ស ២៥៥០ នៅសាលាសតិប្បដ្ឋានខេត្តបាត់ដំបង នឹងដកស្រង់សេចក្ដីបន្ថែមខ្លះ ៗ ពីសៀវភៅមហាបដ្ឋានដែលរៀបរៀងដោយលោកអាចារ្យ ណែប មហានីរាន្ទ ដើម្បីងាយស្រួលក្នុងការសិក្សារបស់ពុទ្ធបរិស័ទយើង ក៏ដូចជាការជួយរក្សាទុកនូវមរតកព្រះពុទ្ធសាសនា , ម្យ៉ាងវិញទៀត ដើម្បីទុកជាឯកសារដល់បច្ឆាបរិស័ទ សិក្សារៀនសូត្រនូវគម្ពីរមហាបដ្ឋាននេះ ។

ក្រោយពីបានរៀបរៀងទៅតាមលំដាប់ តាមដែលលោកគ្រូបង្រៀនហើយ ខ្ញុំបាទក៏បានស្នើសុំឲ្យលោកអ្នកឈ្លាសវៃក្នុងបដ្ឋានគម្ពីរជួយផ្ទៀងផ្ទាត់ ត្រួតមើល មួយសាជាពីរសាទៀត ចៀសវាងក្នុងការភ្លាំងភ្លាត់ដោយប្រការផ្សេង ៗ ។

ក្នុងនោះមាន ៖

សាមណេរ ស សត្ថា គង់នៅអាស្រមព្រះគន្ធកុដិខេត្តបាត់ដំបង

លោកអាចារ្យ ជឹម ជំនិត នៅខេត្តបាត់ដំបង

បន្ទាប់ពីពិនិត្យផ្ទៀងផ្ទាត់រួចហើយ ឃើញថា អាចនឹងបោះពុម្ព ដើម្បីចែកគ្នាសិក្សាបាន ទោះបីសៀវភៅនេះពុំទាន់ចប់សព្វគ្រប់តាមមាតិកាធម៌នៃគម្ពីរបដ្ឋានក៏ដោយ ។

ចុងក្រោយនេះ ខ្ញុំបាទសូមឧទ្ទិសនូវបុណ្យកុសលដែលកើតឡើងក្នុងការងារជាធម្មទាននេះ ៖

គោរពជូន មាតាបិតាយើងខ្ញុំ

គោរពជូន លោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

គោរពជូន លោកគ្រូ ធម្មបណ្ឌិត រស់ សូផាត

ព្រមទាំងជូនដល់សព្វសត្វទាំងអស់ក្នុងត្រៃលោក

សូមលោកអនុមោទនាត្រេកអរ ដើម្បីជាប្រយោជន៍រៀង ៗ ខ្លួន ... ។

ថ្ងៃ ខែ កត្តិក ឆ្នាំ ច ព.ស ២៥៥០

ខ្ញុំបាទ ហាយ ចំរើន

---



## មាតិកាធម៌


| ឈ្មោះធម៌ | | លេខទំព័រ |
|---|---|---|
| មាតិកាបច្ច័យ ២៤ | ................................ | ១ |
| ហេតុប្បច្ច័យ | ................................ | ៤ |
| បញ្ហាវារៈ | ................................ | ៦ |
| អារម្មណប្បច្ច័យ | ................................ | ១៦ |
| បញ្ហាវារៈ | ................................ | ២០ |
| អធិបតិប្បច្ច័យ | ................................ | ៦៨ |
| សហជាតាធិបតិប្បច្ច័យ | ................................ | ៧១ |
| សរុបអង្គធម៌ | ................................ | ៧៤ |
| អារម្មណាធិបតិប្បច្ច័យ | ................................ | ៧៥ |
| សហជាតាធិបតិប្បច្ច័យ | ................................ | ៨៥ |
| អនន្តរប្បច្ច័យ | ................................ | ៩២ |
| សមនន្តរប្បច្ច័យ | ................................ | ១០៣ |
| សហជាតប្បច្ច័យ | ................................ | ១០៣ |

| | | |
|---|---|---|
| បញ្ហាវារៈ | .................................. | ១០៧ |
| អញ្ញមញ្ញប្បច្ច័យ | .................................. | ១២៣ |
| និស្សយប្បច្ច័យ | .................................. | ១៣០ |
| ចែកចេញជា ៣ បច្ច័យ | .................................. | ១៣៤ |
| វត្ថុបុរេជាតប្បច្ច័យ | .................................. | ១៣៥ |
| បញ្ហាវារៈដោយមិស្សកៈ | .................................. | ១៤៦ |
| ឧបនិស្សយប្បច្ច័យ | .................................. | ១៤៨ |
| ដោយលក្ខណៈជាដើម | .................................. | ១៥៩ |
| បកតូ. ចែកជាពីរ | .................................. | ១៦០ |
| បញ្ហាវារៈបកតូ. | .................................. | ១៦២ |
| សមាបត្តិ ៣ | .................................. | ១៦៩ |
| មគ្គវិថី | .................................. | ១៧០ |
| បដិសម្ភិទា ៤ | .................................. | ១៧១ |
| បុរេជាតប្បច្ច័យ | .................................. | ១៩៦ |
| បញ្ហាវារៈ | .................................. | ១៩៨ |
| បច្ឆាជាតប្បច្ច័យ | .................................. | ២០២ |
| បញ្ហាវារៈ | .................................. | ២០៥ |
| អាសេវនប្បច្ច័យ | .................................. | ២០៥ |
| កម្មប្បច្ច័យ | .................................. | ២០៩ |





| | | |
|---|---|---|
| នានក្ខណិក. | .................................. | ២១១ |
| អនន្តរកម្ម. | .................................. | ២១២ |
| សហជាតកម្ម. | .................................. | ២១៤ |
| វិបាកប្បច្ច័យ | .................................. | ២១៥ |
| អាហារប្បច្ច័យ | .................................. | ២១៧ |
| ឥន្ទ្រិយប្បច្ច័យ | .................................. | ២២០ |
| ចែកឥន្ទ្រិយ ២២ | .................................. | ២២៤ |
| ឈានប្បច្ច័យ | .................................. | ២២៦ |
| មគ្គប្បច្ច័យ | .................................. | ២២៩ |
| សម្បយុត្តប្បច្ច័យ | .................................. | ២៣៤ |
| វិប្បយុត្តប្បច្ច័យ | .................................. | ២៣៦ |
| នត្ថិប្បច្ច័យ | .................................. | ២៤០ |
| អត្ថិប្បច្ច័យ , វិគត. | .................................. | ២៤១ |
| អវិគតប្បច្ច័យ | .................................. | ២៤២ |
| ចែកបច្ច័យ ២៤ ជា ៤៨ | .................................. | ២៤២ |
| លំអិតក្នុងបច្ច័យ ២៤ | .................................. | ២៤៤ |

មាតិកា បច្ច័យ ២៤

១. ហេតុប្បច្ចយោ ២. អារម្មណប្បច្ចយោ
៣. អធិបតិប្បច្ចយោ ៤. អនន្តរប្បច្ចយោ
៥. សមនន្តរប្បច្ចយោ ៦. សហជាតប្បច្ចយោ
៧. អញ្ញមញ្ញប្បច្ចយោ ៨. និស្សយប្បច្ចយោ
៩. ឧបនិស្សយប្បច្ចយោ ១០. បុរេជាតប្បច្ចយោ
១១. បច្ឆាជាតប្បច្ចយោ ១២. អាសេវនប្បច្ចយោ
១៣. កម្មប្បច្ចយោ ១៤. វិបាកប្បច្ចយោ
១៥. អាហារប្បច្ចយោ ១៦. ឥន្ទ្រិយប្បច្ចយោ
១៧. ឈានប្បច្ចយោ ១៨. មគ្គប្បច្ចយោ
១៩. សម្បយុត្តប្បច្ចយោ ២០. វិប្បយុត្តប្បច្ចយោ
២១. នត្ថិប្បច្ចយោ ២២. អត្ថិប្បច្ចយោ
២៣. វិគតប្បច្ចយោ ២៤. អវិគតប្បច្ចយោ

ប្រែពាក្យ បដ្ឋាន

ក. បច្ច័យទាំងឡាយដោយប្រការផ្សេង ៗ មានហេតុប្បច្ច័យជាដើម ។



ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា ៈ-

( ១ ) អំពីធម៌ទាំងឡាយដែលកើតឡើងអំពីបច្ច័យ គឺ មិនមែនបច្ច័យតែមួយឡើយ មានមាតិកាបច្ច័យ ២៤ ហើយក្នុងបច្ច័យនីមួយ ៗ ចែកចេញជាបច្ច័យច្រើនទៀត ដូចជា ហេតុប្បច្ច័យ អធិបតិប្បច្ច័យ ផងក៏បាន ( អមោហៈ អង្គធម៌ គឺ បញ្ញា ជាសហជាតាធិបតិប្បច្ច័យ ) ឬ ក៏សហជាត , អញ្ញមញ្ញជាដើម ផងទៀត ។

( ២ ) ទាំងដែលព្រះអង្គទ្រង់ត្រាស់សម្តែងក្នុងបច្ច័យនីមួយ ៗ នោះ មានអង្គធម៌ច្រើនទៀតផង ដូចជាក្នុងហេតុប្បច្ច័យ មានអង្គធម៌ គឺ ចេតសិក ៦ ដូច្នេះជាដើម ។

១. ដោយសេចក្តីថា ព្រះអង្គទ្រង់ត្រាស់សម្តែងចែកនូវពួកធម៌ទាំងឡាយ ក្នុងគម្ពីរអភិធម្មសង្គណី មាន កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា . . . . . ហេតូ ធម្មា ជាដើមនេះ ដោយអំណាច នៃបច្ច័យផ្សេង ៗ ទើបឈ្មោះថា បដ្ឋាន ។
ដូចជា កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយហេតុប្បច្ច័យ , កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ , កុសលធម៌ ជាបច្ច័យនៃកុសលធម៌ផង អព្យាកតធម៌ផង ដោយហេតុប្បច្ច័យ ។

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយហេតុប្បច្ច័យ ,
អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ ,
អកុសលធម៌ ជាបច្ច័យនៃ អកុសលធម៌ផង អព្យាកតធម៌ផង ដោយហេតុប្បច្ច័យ ។
អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ ប៉ុណ្ណេះជាដើម ។

គ. ព្រះអង្គទ្រង់ត្រាស់សម្តែងថា បដ្ឋាន ដោយសេចក្តីថា ជាទីទៅនៃ សព្វញ្ញុតញ្ញាណ ។

---



១ - ហេតុប្បច្ច័យ

បច្ច័យ = ហេតុ ៦ គឺ លោភៈ ទោសៈ មោហៈ , អលោភៈ អទោសៈ អមោហៈ ហេតុទាំង ៦ នេះ ជាចេតសិកធម៌ ។ ៣ ខាងដើម ជាអកុសលសុទ្ធ , ៣ ខាងចុង ជាកុសលក៏មាន ជាអព្យាកតៈក៏មាន ។

បច្ចយុប្បន្ន = សហេតុកចិត្ត ៧១ ដួង , ចេតសិកសម្បយុត្ត ៥២ ( វៀរមោហចេតសិក ក្នុងមោហមូលចិត្ត ២ ដួង ) , សហេតុកចិត្តជរូប ១៧ , សហេតុកបដិសន្ធិកម្មជរូប ២០ ។

បច្ចនិក = ( បដិបក្ខនឹងបច្ចយុប្បន្នៈ ) = អហេតុកចិត្ត ១៨ ដួង , ចេតសិកសម្បយុត្ត ១២ ដួង , មោហចេតសិក ក្នុងមោហមូលចិត្ត ២ ដួង , អហេតុកចិត្តជរូប ១៧ , អហេតុកបដិសន្ធិកម្មជរូប ២០ , ពាហិររូប , អាហារជរូប ,

ឧតុជរូប , អសញ្ញសត្តរូប , បវត្តិកម្មជរូប ។

## បាលីវិធី

### សម្តែងអំពីបច្ច័យ និងបច្ចយុប្បន្ន

ហេតូ ហេតុសម្បយុត្តកានំ ធម្មានំ តំ សមុដ្ឋានានញ្ច រូបានំ
ហេតុប្បច្ចយេន បច្ចយោ ។

ប្រែ ៖ ហេតុ ៦ ជាបច្ច័យនៃធម៌ទាំងឡាយ ដែលប្រកបជា មួយហេតុ និងរូបទាំងឡាយ ដែលមានសហេតុកចិត្តនោះ ជាសមុដ្ឋាន ដោយហេតុប្បច្ច័យ ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

មាន ភាពជាទីតាំង ជាឫសកែវ ជាលក្ខណៈ ។

មាន សហជាតៈ ជាជាតិ ។

ជា បច្ចុប្បន្នកាល ។

ជា ជនកសត្តិ គឺ មានអំណាចឲ្យបច្ចយុប្បន្នធម៌កើតឡើង និង ជាឧបត្ថម្ភកសត្តិ មានអំណាចឧបការៈឲ្យបច្ចយុប្បន្នធម៌តាំងនៅ ។



## បញ្ហាវារៈ

កុសលោ ធម្មោ កុសលស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។
កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយហេតុប្បច្ច័យ ។

## បាលីអនុវាទ

កុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។
កុសលហេតុ ៣ ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤ ដោយហេតុប្បច្ច័យ ។

បច្ច័យ = អលោភៈ អទោសៈ អមោហៈ ដែលជាកុសល ។

បច្ចយុប្បន្ន = កុសលចិត្ត ២១ ដួង និងចេតសិកសម្បយុត្ត ៣៨ ។

កុ.ចេ ៣ ⟶ កុ. ២១ ចេ. ៣៨

### ចែកដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោ- ការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងព្រះសេក្ខបុគ្គល ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងកុសលជវនក្នុងបញ្ចទ្វារ និង ក្នុងមនោទ្វារតាមសមគួរ ។

២- កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស
ហេតុប្បច្ចយេន បច្ចយោ ។
កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ ។

កុសលា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ។
កុសលហេតុ ៣ ជាបច្ច័យនៃកុសលចិត្តសមុដ្ឋានរូប ១៧
ដោយហេតុប្បច្ច័យ ។

បច្ច័យ = កុសលចេតសិក ៣ គឺ អលោភៈ អទោសៈ អមោហៈ ។

បច្ចយុប្បន្ន = ចិត្តជរូប ១៧ ដែលមានកុសលចិត្តជាសមុដ្ឋាន ។

កុ.ចេ ៣ ⟶ ចិត្តជ. ១៧

ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។



ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងព្រះសេក្ខបុគ្គល ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងមនោទ្វារតាម សមគួរ ។

៣- កុសលោ ធម្មោ កុសលស្ស ច អព្យាកតស្ស ច ធម្មស្ស
ហេតុប្បច្ចយេន បច្ចយោ ។

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ផង អព្យាកតធម៌ផង
ដោយហេតុប្បច្ច័យ ។
កុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ
ហេតុប្បច្ចយេន បច្ចយោ ។
កុសលហេតុ ៣ ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤
និងចិត្តជរូបដែលមាន កុសលចិត្តជា សមុដ្ឋាន ។

---

ចិត្តជរូប ១៧ : អវិនិព្ភោគរូប ៨ , បរិច្ឆេទរូប ១ , វិញ្ញត្តិរូប ២ , វិការរូប ៣ , សទ្ទរូប ១ , ឧបចយរូប ១ សន្តតិរូប ១ ។

បច្ច័យ : = កុសលហេតុ ៣ គឺ អលោភៈ អទោសៈ
អមោហៈ ។

បច្ចយុប្បន្ន = កុសលចិត្ត ២១ ដួង ចេតសិកសម្ប-
យុត្ត ៣៨ កុសលចិត្តជរូប ១៧ ។

កុ.ចេ ៣ ⟶ កុ. ២១ ចេ. ៣៨ ចិត្តជ. ១៧

ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជននិងព្រះសេក្ខបុគ្គល ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅជាកុសលជវនតាមបញ្ចទ្វារ និង
មនោទ្វារ តាមសមគួរ ។

៤ - អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស ហេតុប្បច្ចយេន
បច្ចយោ ។

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយហេតុប្បច្ច័យ ។

អកុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ហេតុប្បច្ចយេន បច្ចយោ ។

អកុសលហេតុ ៣ ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤ ដោយ



ហេតុប្បច្ច័យ ។

បច្ច័យ = លោភៈ ទោសៈ មោហៈ ជាអកុសល-
ចេតសិក ។

បច្ចយុប្បន្ន = អកុសលចិត្ត ១២ ដួង និងចេតសិក-
សម្បយុត្ត ២៧ ( វៀរមោហចេតសិក
ក្នុងមោហមូលចិត្ត ២ ដួង ) ។

អកុ.ចេ ៣ ⟶ អកុ. ១២ ចេ. ២៧

ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ និងចតុវោ-
ការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៣
ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

៥- អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន
បច្ចយោ ។

អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ ។

អកុសលា ហេតូ ចិត្តសមុដ្ឋានានំ រូបានំ ហេតុប្បច្ចយេន បច្ចយោ ។

អកុសលហេតុ ៣ ជាបច្ច័យនៃអកុសលចិត្តសមុដ្ឋានរូប ១៧

ដោយហេតុប្បច្ច័យ ។

បច្ច័យ = អកុសលចេតសិក គឺ លោភៈ ទោសៈ មោហៈ ។

បច្ចយុប្បន្ន = ចិត្តជរូប ១៧ ដែលមានអកុសលចិត្តជាសមុដ្ឋាន ។

អកុ.ចេ ៣ ⟶ ចិត្តជ. ១៧

ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។



៦- អកុសលោ ធម្មោ អកុសលស្ស ច អព្យាកតស្ស ច ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ផង អព្យាកតធម៌ផង ដោយហេតុប្បច្ច័យ ។

អកុសលា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។

អកុសលហេតុ ៣ ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤ និងចិត្តជរូប ដែលមានអកុសលចិត្តហ្នឹងឯង ជាសមុដ្ឋាន ។

បច្ច័យ : = អកុសលហេតុ ៣ ។

បច្ចយុប្បន្ន = អកុសលចិត្ត ១២ ដួង ចេតសិកសម្បយុត្ត ២៧ ( វៀរមោហចេតសិក ក្នុងមោហមូលចិត្ត ២ ដួង ) ព្រមទាំងចិត្តជរូប ១៧ ដែលមានអកុសលចិត្តជាសមុដ្ឋាន ។

អកុ.ចេ ៣ ⟶ អកុ.១២ ចេ.២៧ ចិត្តជ.១៧

ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងព្រះសេក្ខ-បុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

**៧- អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។** អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយហេតុប្បច្ច័យ ។

**វិបាកាព្យាកតា កិរិយាព្យាកតា ហេតូ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ហេតុ ៣ ដែលជាអព្យាកតវិបាក និងហេតុ ៣ ជាអព្យាកត-កិរិយា ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤ និងសហេតុកវិបាកចិត្ត-សមុដ្ឋានរូប សហេតុកកិរិយាចិត្តសមុដ្ឋានរូប ១៧ ។



**បច្ច័យ** = អព្យាកតហេតុ ៣ ទាំងវិបាក ទាំងកិរិយា ។

**បច្ចយុប្បន្ន** = សហេតុកវិបាកចិត្ត ២១ ដួង និងសហេតុក-កិរិយាចិត្ត ១៧ ដួង ចេតសិក ៣៨ ចិត្តជរូប ១៧ ដែលមានសហេតុកវិបាកចិត្ត និងសហេតុ-កកិរិយាចិត្ត ជាសមុដ្ឋាន ។

\+ នៅក្នុងចតុវោការភូមិ វៀររូប ។

**អព្យា.ហេតុ.៣ ⟶ ស.វិ.២១ ស.កិ.១៧ ចេ.៣៨ ចិត្តជ.១៧ ។**

**បដិសន្ធិក្ខណេ វិបាកាព្យាកតា ហេតូ សម្បយុត្តកានំ ខន្ធានំ កដត្តា ច រូបានំ ហេតុប្បច្ចយេន បច្ចយោ ។**

ក្នុងខណៈបដិសន្ធិ , ហេតុ ៣ ជាអព្យាកតវិបាក ជាបច្ច័យនៃសម្បយុត្តនាមក្ខន្ធ ៤ និង សហេតុកបដិសន្ធិកម្មជរូប ២០ ដោយហេតុប្បច្ច័យ ។

**បច្ច័យ** = វិបាកហេតុ ៣ ក្នុងខណៈបដិសន្ធិ ។

**បច្ចយុប្បន្ន** = សហេតុកបដិសន្ធិចិត្ត ១៧ ដួង , ចេតសិក សម្បយុត្ត ៣៥ សហេតុកបដិសន្ធិកម្មជរូប ២០ ។

### ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល និងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងទុហេតុកៈ និងតិហេតុកបុថុជ្ជន និងផលបុគ្គល ៤ ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ តាមសមគួរ និងក្រៅទ្វារ ។

---



## ២ - អារម្មណប្បច្ច័យ

**១. រូបាយតនំ ចក្ខុវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

រូបារម្មណ៍ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុ ២ ដួង និងពួកធម៌ទាំងឡាយ បានដល់ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយនឹងចក្ខុវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

រូបា. ⟶ ចក្ខុ.វិ ២ , ចេ. ៧

**២. សទ្ទាយតនំ សោតវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

សទ្ទារម្មណ៍ ជាបច្ច័យនៃសោតវិញ្ញាណធាតុ ២ ដួង និងពួកធម៌ទាំងឡាយ បានដល់ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយនឹងសោតវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

សទ្ទា. ⟶ សោត.វិ ២ , ចេ. ៧

**៣. គន្ធាយតនំ ឃានវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

គន្ធារម្មណ៍ ជាបច្ច័យនៃសោតវិញ្ញាណធាតុ ២ ដួង និងពួកធម៌ទាំងឡាយ បានដល់សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយនឹងឃានវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

**គន្ធា. ⟶ ឃាន.វិ ២ , ចេ. ៧**

**៤. រសាយតនំ ជិវ្ហាវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

រសារម្មណ៍ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុ ២ ដួង និងពួកធម៌ទាំងឡាយ បានដល់ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយនឹងជិវ្ហាវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

**រសា. ⟶ ជិវ្ហា.វិ ២ , ចេ. ៧**

**៥. ផោដ្ឋព្វាយតនំ កាយវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

ផោដ្ឋព្វារម្មណ៍ ជាបច្ច័យនៃកាយវិញ្ញាណធាតុ ២ ដួង និងពួក



ធម៌ទាំងឡាយ បានដល់ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយនឹងកាយវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

**ផោដ្ឋ. ⟶ កាយ.វិ ២ , ចេ. ៧**

**៦. រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ មនោធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

បញ្ចារម្មណ៍ ជាបច្ច័យនៃមនោធាតុ ៣ ដួង និងពួកធម៌ទាំងឡាយ បានដល់ ចេតសិក ១០ ដែលប្រកបជាមួយនឹងមនោធាតុនោះ ដោយអារម្មណប្បច្ច័យ ។

**បញ្ចារម្មណ៍ ⟶ មនោធាតុ ៣ , ចេ. ១០**

**៧. សព្វេ ធម្មា មនោវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

**សព្វេ ធម្មា** គឺ អារម្មណ៍ ៦ គឺ ចិត្ត ៨៩ ដួង ចេតសិក

៥២ រូប ២៨ ដែលជាតេកាលិកៈ ( គ្រប់កាលទាំង ៣ ) និងនិព្វាន បញ្ញត្តិដែលជាកាលវិមុត្តិ ជាបច្ច័យដល់មនោវិញ្ញាណធាតុ ៧៦ ដួង និងពួកធម៌ទាំងឡាយ បានដល់ ចេតសិក ៥២ ដែលប្រកបជាមួយនឹងមនោវិញ្ញាណធាតុនោះ ដោយអារម្មណប្បច្ច័យ ។

**ចិត្ត.៨៩ ចេ.៥២ រូប២៨ និព្វាន បញ្ញត្តិ ⟶ ចិត្ត.៧៦ ចេ ៥២**

**យំ យំ ធម្មំ អារព្ភ យេ យេ ធម្មា ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា តេ តេ ធម្មា តេសំ តេសំ ធម្មានំ អារម្មណប្បច្ចយេន បច្ចយោ ។**

- **យេ យេ ធម្មា** ពួកធម៌ទាំងឡាយណា ៗ គឺ ចិត្ត ចេតសិកធម៌ បានប្រារព្ធនូវធម៌ដែលជាអារម្មណ៍ឯណានីមួយ កើតឡើង , **តេ តេ ធម្មា** ពួកធម៌ ទាំងឡាយនោះ ៗ ជាបច្ច័យនៃធម៌ទាំងឡាយនោះ ៗ ដោយអារម្មណប្បបច្ច័យ ។

**ចិ.៨៩-ចេ.៥២-រូប២៨-និព្វាន-បញ្ញត្តិ ⟶ ចិ.៨៩-ចេ ៥២**

- **យំ យំ ធម្មំ** និង **តេ តេ ធម្មា** ជាអារម្មណប្បច្ច័យ ។
- **យេ យេ ធម្មា** និង **តេសំ តេសំ ធម្មានំ** ជាអារម្មណ- ប្បច្ចយុប្បន្នៈ ។

**បច្ច័យ** = បរមត្ថធម៌ ៤ ( ចិ.ចេ.រូ.និ ) បញ្ញត្តិ ។



**បច្ចយុប្បន្ន** = ចិត្ត ៨៩ ចេតសិក ៥២ ។

**បច្ចនិក** = រូប ២៨ ( ទាំងអស់ ទាំង ៧ ក្រុម ) ។

**ដោយលក្ខណៈ កាល ជាតិ សត្តិ**

ដោយលក្ខណា : ជាទីត្រេកអរ និងជាទីតោង ជាលក្ខណៈ ។

ដោយកាល : ប្រព្រឹត្តទៅក្នុងកាលទាំង ៣ និងកាលវិមុត្តិ ។

ដោយជាតិ : ជាអារម្មណជាតិ ។

ដោយសត្តិ : ជាជនកសត្តិ និងឧបត្ថម្ភកសត្តិ ។

## បញ្ហាវារៈ មាន ៩

**១. កុសលោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២០ ( វៀរអរហត្តមគ្គចិត្ត ) ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង អភិញ្ញាកុសលចិត្ត ១ វិញ្ញាណញ្ចាយតនកុសល ១ និងនេវសញ្ញានាសញ្ញាយតនកុសល ១

ចេតសិក ៣៣ ( វៀរវិរតិ ៣ អប្បមញ្ញា ២ ) ។

**( ១ ) ទានំ ទត្វា សីលំ សមាទយិត្វា ឧបោសថកម្មំ កត្វា តំ បច្ចវេក្ខតិ ។**

បុគ្គលឲ្យទានហើយ សមាទានសីលហើយ ធ្វើនូវឧបោសថ-កម្មហើយ ពិចារណានូវទាន សីល ឧបោសថកម្ម ដែលបានធ្វើហើយនោះ ។

**បច្ច័យ** = មហាកុសល ៨ ចេតសិក ៣៦ ( វៀរ អប្បមញ្ញា ២ ) ។

**បច្ចយុប្បន្ន** = មហាកុសល ៨ ចេតសិក ៣៣ ( វៀរ វិរតិ ៣ អប្បមញ្ញា ២ ) ។

**មហាកុ.៨ ចេ.៣៦ ⟶ មហាកុ.៨ ចេ.៣៣**

**( ២ ) បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ។**

ពិចារណាដល់ពួកកុសលធម៌ ដែលខ្លួនធ្លាប់បានសន្សំល្អហើយ



ក្នុងកាលមុន ។

**បច្ច័យ** = មហាកុសល ៨ ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = មហាកុសល ៨ ចេតសិក ៣៣ ។

**មហាកុ.៨ ចេ.៣៨ ⟶ មហាកុ.៨ ចេ.៣៣**

**( ៣ ) ឈានា វុដ្ឋហិត្វា ឈានំ បច្ចវេក្ខតិ ។**

បុគ្គល កាលចេញចាកឈានហើយ ពិចារណានូវឈាននោះ ។

**បច្ច័យ** = មហគ្គតកុសល ៩ ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = មហាកុសល ៨ ចេតសិក ៣៣ ។

**មហ.កុ.៩ ចេ.៣៥ ⟶ មហាកុ.៨ ចេ.៣៣**

**( ៤ ) សេក្ខា គោត្រភុំ បច្ចវេក្ខន្តិ វោទានំ បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណានូវគោត្រភូញាណ ពិចា-រណានូវវោទាន ។

**បច្ច័យ** = មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ( វៀរវិរតិ ៣ អប្បមញ្ញា ២ ) ។

**បច្ចយុប្បន្ន** = មហាកុសល ៨ ចេតសិក ៣៣ ។

**មហាកុ.ស.៤ ចេ.៣៣ ⟶ មហាកុ.៨ ចេ.៣៣**

**( ៥ ) សេក្ខា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ចេញចាកអំពីមគ្គហើយ ពិចារណានូវមគ្គនោះ ដោយបច្ចវេក្ខណញ្ញាណ ។

**បច្ច័យ** = មគ្គចិត្ត ៣ ខាងក្រោម ចេតសិក ៣៦ ( វៀរអប្បមញ្ញា ២ ) ។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**មគ្គ.៣ ចេ.៣៦ ⟶ មហាកុសំ.៤ ចេ.៣៣**

**( ៦ ) សេក្ខា វា បុថុជ្ជនា វា កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ចម្រើនវិបស្សនា ពិចារណាឃើញនូវកុសលថា មិនទៀង ជាទុក្ខ ជាអនត្តា ។

**បច្ច័យ** = លោកិយកុសល ១៧ ដួង ចេតសិក ៣៨ ។



**បច្ចយុប្បន្ន** = មហាកុសល ៨ ដួង ចេតសិក ៣៣ ។

**លោកិយកុ.១៧ ចេ.៣៨ ⟶ មហាកុ.៨ ចេ.៣៣**

**( ៧ ) ចេតោបរិយញ្ញាណេន កុសលចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។**

( ព្រះសេក្ខបុគ្គលទាំងឡាយ និងតិហេតុកបុថុជ្ជនទាំងឡាយ )
ដឹងចិត្តបុគ្គលដទៃដែលព្រមព្រៀងដោយកុសលចិត្ត
ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = កុសលចិត្ត ២០ ( វៀរអរហត្តមគ្គ ) ចេតសិកសម្បយុត្ត ៣៨ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**កុ.២០ ចេ.៣៨ ⟶ អភិ.កុ.១ ចេ.៣០**

**( ៨ ) អាកាសានញ្ចាយតនកុសលំ វិញ្ញាណញ្ចាយតនកុសលស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញាណញ្ចាយតនកុសល ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកាសានញ្ចាយតនកុសលចិត្ត ១ ដួង

ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = វិញ្ញាណញ្ចាយតនកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**អាកា.កុ.១ ចេ.៣០ ⟶ វិ.កុ.១ ចេ.៣០**

**( ៩ ) អាកិញ្ចញ្ញាយតនកុសលំ នេវសញ្ញានាសញ្ញាយតនកុសលស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនកុសល ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកិញ្ចញ្ញាយតនកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**អាកិ.កុ.១ ចេ.៣០ ⟶ នេវ.កុ.១ ចេ.៣០**

**( ១០ ) កុសលា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**



កុសលខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២០ ដួង ( វៀរអរហត្តមគ្គ ) ចេតសិក ៣៨ ដែល ជាកុសលខន្ធ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣០ ដែលជាញាណទាំង ៥ ។

**កុ.២០ ចេ.៣៨ ⟶ អភិ.កុ.១ ចេ.៣០**

## ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល = គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ = គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល = គឺប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៣ ពួក ។

ដោយទ្វារ = គឺ ប្រព្រឹត្តទៅតាមទ្វារទាំង ៦ តាមសមគួរ ។

## បញ្ហាវារៈទី ២

**កុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**លោកិយកុ.១៧ ចេ.៣៨ ⟶ អកុ. ១២ , ចេ. ២៧**

**( ១ ) ទានំ ទត្វា សីលំ សមាទយិត្វា ឧបោសថកម្មំ កត្វា តំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលឲ្យទានហើយ សមាទានសីលហើយ ធ្វើឧបោសថកម្មហើយ ក៏ត្រេកអររីករាយ ភ្លើតភ្លើនទៅក្នុងកុសលនោះ ៗ ព្រោះប្រារព្ធនូវកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៦ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។



**មហាកុ.៨ ចេ.៣៦ ⟶ អកុ. ១២ , ចេ. ២៧**

**( ២ ) បុព្វេ សុចិណ្ណានិ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអររីករាយ ភ្លើតភ្លើនទៅក្នុងកុសល ដែលខ្លួនបានសន្សំហើយក្នុងកាលមុន ព្រោះប្រារព្ធនូវកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**មហាកុ.៨ ចេ.៣៨ ⟶ អកុ.១២ ចេ.២៧**

**( ៣ ) ឈានា វុដ្ឋហិត្វា ឈានំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ឈានេ បរិហីនេ វិប្បដិសារិស្ស ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលចេញចាកឈាន ហើយត្រេកអររីករាយ ភ្លើតភ្លើនទៅក្នុងឈាននោះ ព្រោះប្រារព្ធនូវឈាននោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង

វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ព្រោះការសាបសូន្យទៅនៃឈាន ទោមនស្សរបស់អ្នកដែលមានសេចក្តីសោកស្តាយ ក៏កើតឡើង ។

**បច្ច័យ** = មហគ្គតកុសលចិត្ត ៩ ដួង ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**មហាកុ.៨ ចេ.៣៥ ⟶ អកុ.១២ ចេ.២៧**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល = គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ = គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល = គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៣ ពួក ។

ដោយទ្វារ = គឺ ប្រព្រឹត្តទៅក្នុងមនោទ្វារ ទាំងបច្ច័យ និងបច្ចយុប្បន្នៈ ។

## បញ្ហាវារៈទី ៣

**កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**



កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = កាមាវចរកិរិយា ១០ ដួង ( វៀរបញ្ចទ្វារាវជ្ជនៈ ) តទាលម្ពណចិត្ត ១១ ដួង អភិញ្ញាកិរិយាចិត្ត ១ ដួង វិញ្ញាណញ្ចាយតនវិបាក ១ ដួង វិញ្ញាណញ្ចាយតនកិរិយា ១ ដួង នេវសញ្ញានាសញ្ញាយតនវិបាក ១ ដួង នេវសញ្ញានាសញ្ញាយតនកិរិយា ១ ដួង ចេតសិក ៣៣ ។

**កុ.២១ ចេ.៣៨ ⟶ កាម.កិ ១០ តទា.១១ អភិ.កិ ១ វិញ្ញា.វិ ១វិញ្ញា.កិ ១ នេ.វិ ១ នេ.កិ ១ ចេ.៣៣ ។**

**( ១ ) អរហា មគ្គា វុដ្ឋហិត្វា មគ្គំ បច្ចវេក្ខតិ ។**

ព្រះអរហន្ត ចេញចាកមគ្គហើយ ពិចារណានូវមគ្គ ។

**បច្ច័យ** = អរហត្តមគ្គចិត្ត ១ ដួង ចេតសិក ៣៦ ។

**បច្ចយុប្បន្ន** = មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**អរហត្តមគ្គ.១ ចេ.៣៦ ⟶ កិ.សម្ប.៤ , ចេ. ៣៣**

**( ២ ) បុព្វេ សុចិណ្ណានិ បច្ចវេក្ខតិ ។**

ព្រះអរហន្ត ពិចារណានូវកុសលដែលធ្លាប់បានសន្សំហើយ ក្នុងកាលមុន ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = មហាកិរិយា ៨ ដួង ចេតសិក ៣៣ ។

**កុ.៨ ចេ.៣៨ ⟶ កិ.៨ , ចេ. ៣៣**

**( ៣ ) កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។**

( ព្រះអរហន្ត ) ពិចារណាឃើញនូវកុសលធម៌ ថា មិនទៀង ជាទុក្ខ ជាអនត្តា ។

**បច្ច័យ** = លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ។



**បច្ចយុប្បន្ន** = មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ។

**កុ.១៧ ចេ.៣៨ ⟶ មហាកិ.៨ , ចេ. ៣៣**

**( ៤ ) ចេតោបរិយញ្ញាណេន កុសលចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

( ព្រះអរហន្ត ) ដឹងចិត្តអ្នកដទៃ ដែលព្រមព្រៀងដោយកុសលចិត្ត ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។

**កុ.២១ ចេ.៣៨ ⟶ អភិ.កិ.១ ចេ.៣០**

**( ៥ ) សេក្ខា វា បុថុជ្ជនា វា កុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ បុថុជ្ជនទាំងឡាយក្តី ពិចារណាឃើញកុសលធម៌ថា មិនទៀង ជាទុក្ខ ជាអនត្តា , កាលដែលកុសលវិបស្សនារលត់ទៅ វិបាកក៏កើតឡើង ធ្វើតទាលម្ពណកិច្ច ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = តទាលម្ពណចិត្ត ១១ ដួង ចេតសិក ៣៣ ។

**កុ.៨ ចេ.៣៨ ⟶ តទា.១១ ចេ.៣៣**

**( ៦ ) កុសលំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ អកុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

បុគ្គលត្រេកអរីករាយ ភ្ញើតភ្ញើន ទៅក្នុងកុសលធម៌ ព្រោះប្រារព្ធនូវកុសល រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង កាលដែលអកុសលរលត់ទៅ វិបាកក៏កើតឡើង ធ្វើតទាលម្ពណកិច្ច ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = តទាលម្ពណចិត្ត ១១ ដួង ចេតសិក ៣៣ ។

**កុ.៨ ចេ.៣៨ ⟶ តទា.១១ ចេ. ៣៣**

**( ៧ ) អាកាសានញ្ចាយតនកុសលំ វិញ្ញាណញ្ចាយតនវិបាកស្ស ច កិរិយស្ស ច អារម្មណប្បច្ចយេន បច្ចយោ ។**



អាកាសានញ្ចាយតនកុសល ជាបច្ច័យនៃវិញ្ញាណញ្ចាយតនវិបាកផង វិញ្ញាណញ្ចាយតនកិរិយាផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកាសានញ្ចាយតនកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = វិញ្ញាណញ្ចាយតនវិបាកចិត្ត ១ ដួង , វិញ្ញាណញ្ចាយតនកិរិយា ១ ដួង ចេតសិក ៣០ ។

**អាកា.កុ.១ ចេ.៣០ ⟶ វិញ្ញា.វិ.១ វិញ្ញា.កិ.១ ចេ.៣០**

**( ៨ ) អាកិញ្ចញ្ញាយតនកុសលំ នេវសញ្ញានាសញ្ញាយតនវិបាកស្ស ច កិរិយស្ស ច អារម្មណប្បច្ចយេន បច្ចយោ ។**

អាកិញ្ចញ្ញាយតនកុសល ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនវិបាកផង ដល់នេវសញ្ញានាសញ្ញាយតនកិរិយាផង ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកិញ្ចញ្ញាយតនកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១

ដួង នេវសញ្ញានាសញ្ញាយតនកិរិយា-
ចិត្ត ១ ដួង ចេតសិក ៣០ ។

**អាកិ.កុ.១ ចេ.៣០ → នេវ.វិ.១ នេវ.កិ.១ ចេ. ៣០**

**( ៩ ) កុសលា ខន្ធា ចេតោបរិយញ្ញាណស្ស**
**បុព្វេនិវាសានុស្សតិញ្ញាណស្ស**
**យថាកម្មុបគញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ**
**អារម្មណប្បច្ចយេន បច្ចយោ ។**

កុសលក្ខន្ធទាំងឡាយ ជាបច្ច័យនៃចេតោបរិយញ្ញាណ
បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ
និងមនោទ្វារាវជ្ជនៈ ។

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។
**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០
មនោទ្វារាវជ្ជនចិត្ត ១ ដួង ចេតសិក
១១ ។

**កុ.២១ ចេ.៣៨ → អភិ.កិ.១ ចេ.៣០ មនោទ្វារ.១ ចេ.១១**



### ដោយកាល ភូមិ បុគ្គល ទ្វារ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ( ចំពោះបច្ច័យ
រីឯបច្ចយុប្បន្ន មានទាំងបដិសន្ធិកាលផង ) ។
ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោ-
ការភូមិ ។
ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៤
ពួក ។
ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងក្នុងមនោទ្វារ
( បច្ចយុប្បន្នប្រព្រឹត្តទៅក្រៅទ្វារក៏មាន ) ។

## បញ្ហាវារៈទី ៤

**អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន**
**បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។
**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**( ១ ) រាគំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ**

**ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអររីករាយ ភ្លើតភ្លើន ទៅក្នុងរាគៈនោះ ៗ

ព្រោះប្រារព្ធរាគៈនោះ រាគៈកើត ឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង

ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = ( រាគៈ ) លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**លោភ.៨ ចេ.២២ ⟶ អកុ.១២ ចេ.២៧**

**( ២ ) ទិដ្ឋឹ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអររីករាយ ភ្លើតភ្លើន ទៅក្នុងទិដ្ឋិនោះ ៗ

ព្រោះប្រារព្ធទិដ្ឋិនោះ រាគៈកើត ឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង

ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = លោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ៤ ដួង ចេតសិក ២១ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។



**លោភទិដ្ឋិសំ.៤ ចេ.២១ ⟶ អកុ.១២ ចេ.២៧**

**( ៣ ) វិចិកិច្ឆំ អារព្ភ វិចិកិច្ឆា ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធវិចិកិច្ឆា វិចិកិច្ឆាកើតឡើង ទិដ្ឋិកើតឡើង

ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = មោហមូលចិត្តវិចិកិច្ឆាសម្បយុត្ត ១ ដួង ចេតសិក ១៥ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ៨ ដួង ( វៀរលោភមូលចិត្ត-ទិដ្ឋិគតវិប្បយុត្ត ៤ ដួង ) ចេតសិក ២៦ ( វៀរមានះ ) ។

**មោហសំ.វិចិ.១ ចេ.១៥ ⟶ អកុ.៨ ចេ.២៦**

**( ៤ ) ឧទ្ធច្ចំ អារព្ភ ឧទ្ធច្ចំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធឧទ្ធច្ចៈ ឧទ្ធច្ចៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង

ទោមនស្សកើតឡើង ។

**បច្ច័យ** = មោហមូលចិត្តឧទ្ធច្ចសម្បយុត្ត ១ ដួង ចេតសិក ១៥ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ៨ ដួង ( វៀរលោភមូលចិត្ត-ទិដ្ឋិគតវិប្បយុត្ត ៤ ដួង ) ចេតសិក ២៦ ។

**មោហសំ.ឧទ្ធច្ច.១ ចេ.១៥ ⟶ អកុ.៨ ចេ.២៦**

**( ៥ ) ទោមនស្សំ អារព្ភ ទោមនស្សំ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ។**

ព្រោះប្រារព្ធទោមនស្ស ទោមនស្សកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ។

**បច្ច័យ** = ទោសមូលចិត្ត ២ ដួង ចេតសិក ២២ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ៨ ដួង ( វៀរលោភមូលចិត្ត-ទិដ្ឋិគតវិប្បយុត្ត ៤ ដួង ) ចេតសិក ២៦ ( វៀរមានះ ) ។

**ទោស.២ ចេ.២២ ⟶ អកុ.៨ ចេ.២៦**



**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និង បញ្ចវោការភូមិ តាមសមគួរ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផល-សេក្ខបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

## បញ្ហាវារៈ ទី ៥

**អកុសលោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣៣ ( វិរតិចេតសិក ប្រកប ជាមួយមហាកុសលចិត្ត វៀរចាកអកុសលប្រព្រឹត្ត ទៅតាមសមគួរ ) ។

អកុ.១២ ចេ.២៧ ⟶ កុ.៨ អភិ.កុ១ ចេ.៣៣

**( ១ ) សេក្ខា បហីនក្កិលេសេ បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គល ពិចារណាពួកកិលេសដែលលះបង់បានហើយ ។

**បច្ច័យ** = អកុសលចិត្ត ១១ ដួង ( វៀរមោហមូលចិត្តឧទ្ធច្ចសម្បយុត្ត ១ ដួង ចេតសិក ២៧ ។ ព្រះសោតាបន្នបុគ្គល ពិចារណាលោភមូលចិត្តទិដ្ឋិគតសម្បយុត្ត ៤ ដួង មានទិដ្ឋិជាប្រធាន និងមោហមូលចិត្តវិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង មានវិចិកិច្ឆាជាប្រធាន ចេតសិកដែលប្រកបជាមួយនឹងចិត្ត ៥ ដួង នេះទៀត ។ ព្រះសកទាគាមិបុគ្គល ពិចារណានូវរាគៈ ទោសៈ មោហៈ ដែលគ្រោតគ្រាត ដែលលះបង់បានថែមទៀត ។ ព្រះអនាគាមិបុគ្គល ពិចារណានូវ កាមរាគៈ បដិឃៈ ដែលលះបង់ដាច់ជាសមុច្ឆេទ ថែមបន្តទៀត ដោយប្រការដូច្នេះឯង ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣



( វៀរវិរតិ ៣ អប្បមញ្ញា ២ ) ។

**( ២ ) សេក្ខា វិក្ខម្ភិតក្កិលេសេ បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គល ពិចារណានូវពួកកិលេសដែលសង្កត់សង្កិន នូវពួកកិលេសបានហើយ ។

**បច្ច័យ** = កិលេស ៨ ( វៀរទិដ្ឋិ វិចិកិច្ឆា ) ។ ព្រះសោតាបន្នបុគ្គល ពិចារណានូវកិលេស ៨ គឺ លោភៈ ទោសៈ មោហៈ មានះ អហិរិកៈ អនោតប្បៈ ថីនៈ ឧទ្ធច្ចៈ , ព្រះសកទាគាមី ពិចារណានូវកិលេសទាំង ៨ នេះ ដែលស្រាលស្តើង , ព្រះអនាគាមី ពិចារណាកិលេស ដែលកាន់តែស្រាលស្តើងហើយនោះ គឺ ៖-

១ លោភៈ ( រូបរាគៈ អរូបរាគៈ មិនមានកាមរាគៈទេ ) ។

២ មោហៈ

៣ មានះ

៤ អហិរិកៈ

៥ អនោតប្ប:

៦ ថីន:

៧ ឧទ្ធច្ច:

ដែលសង្កត់សង្កិនបានហើយ ដោយប្រការដូច្នេះ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ។

**( ៣ ) បុព្វេ សមុទាចិណ្ណេ កិលេសេ ជានន្តិ ។**

( ព្រះសេក្ខបុគ្គលទាំងឡាយ )

ដឹងនូវពួកកិលេសដែលបានកើតឡើងហើយ ធ្លាប់សន្សំហើយ

ក្នុងកាលមុន ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ។

**អកុ.១២ ចេ.២៧ ⟶ មហាកុ.៨ ចេ.៣៣**

**( ៤ ) សេក្ខា វា បុថុជ្ជនា វា អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**



ព្រះសេក្ខបុគ្គលទាំងឡាយក្តី បុថុជ្ជនទាំងឡាយក្តី ពិចារណាដោយវិបស្សនានូវអកុសល ឃើញច្បាស់ថា មិនទៀង ជាទុក្ខ ជាអនត្តា ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ។

**អកុ.១២ ចេ.២៧ ⟶ មហាកុ.៨ ចេ.៣៣**

**( ៥ ) ចេតោបរិយញ្ញាណេន អកុសលចិត្តសមង្គិស្ស ចិត្តំ ជានន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ និងតិហេតុកបុថុជ្ជនបុគ្គល

ដឹងចិត្តបុគ្គលដែល កំពុងព្រមព្រៀងដោយអកុសល

ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ដែលប្រព្រឹត្តទៅជាចេតោបរិយញ្ញាណ ចេតសិក ៣០ ។

**អកុ.១២ ចេ.២៧ ⟶ អភិ.កុ.១ ចេ.៣០**

**( ៦ ) អកុសលា ខន្ធា ចេតោបរិយញ្ញាណស្ស**

**បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុបគញ្ញាណស្ស**

**អនាគតំសញ្ញាណ អារម្មណប្បច្ចយេន បច្ចយោ ។**

អកុសលក្ខន្ធទាំងឡាយ ជាបច្ច័យនៃអភិញ្ញាកុសលទាំង ៤ គឺ

ចេតោបរិយញ្ញាណជាដើម ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣០ ។

**អកុ.១២ ចេ.២៧ ⟶ អភិ.កុ.១ ចេ.៣០**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលសេក្ខបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងមនោទ្វារ ។

## បញ្ហាវារៈ ទី ៦

**អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**



អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = កាមាវចរកិរិយាចិត្ត ១០ ( វៀរ បញ្ចទ្វារាវជ្ជនៈ ) តទាលម្ពណចិត្ត ១១ ដួង អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣៣ ។

**អកុ.១២ ចេ.២៧ ⟶ កាម.កិ.១០ តទា.១១**

**អភិ.កិ.១ ចេ.៣៣ ។**

**( ១ ) អរហា បហីនក្កិលេសេ បច្ចវេក្ខតិ ។**

ព្រះអរហន្ត ពិចារណាពួកកិលេស ដែលលះបង់បានហើយ ។

**បច្ច័យ** = កិលេស ១០ ឬអកុសលធម៌ទាំងអស់ ។

**បច្ចយុប្បន្ន** = មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ។

**កិលេស.១០ ចេ.២៧ ⟶ មហាកិ.៨ ចេ.៣៣**

**( ២ ) បុព្វេ សមុទាចិណ្ណេ កិលេសេ ជានាតិ ។**

( ព្រះអរហន្ត ) ដឹងនូវពួកកិលេសដែលកើតឡើងហើយ

ធ្លាប់សន្សំហើយ ក្នុងកាលមុន ។

**បច្ច័យ** = កិលេស ១០ ឬអកុសលធម៌ទាំងអស់ ។

**បច្ចយុប្បន្ន** = មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ។

**កិលេស.១០ ចេ.២៧ ⟶ មហាកិ.៨ ចេ.៣៣**

**( ៣ ) អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។**

ព្រះអរហន្ត ឃើញច្បាស់នូវអកុសលថា មិនទៀង ជាទុក្ខ ជាអនត្តា ។

**បច្ច័យ** = អកុសល ១២ ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ។

**អកុ.១២ ចេ.២៧ ⟶ មហាកិ.៨ ចេ.៣៣**

**( ៤ ) ចេតោបរិយញ្ញាណេ អកុសលចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

ព្រះអរហន្ត ដឹងចិត្តអ្នកដទៃដែលព្រមព្រៀងដោយអកុសល
ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។



**កិលេស.១០ ចេ.២៧ ⟶ អភិ.កិ.៨ ចេ.៣០**

**( ៥ ) សេក្ខា វា បុថុជ្ជនា វា អកុសលំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ កុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី តិហេតុកបុថុជ្ជនទាំងឡាយក្តី
ឃើញច្បាស់នូវអកុសលថា មិនទៀង ជាទុក្ខ ជាអនត្តា
កាលដែលកុសលរលត់ហើយ វិបាកក៏កើតឡើង ។

**បច្ច័យ** = អកុសលចិត្ត ១២ ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = តទាលម្ពណចិត្ត ១១ ដួង ចេតសិក ៣៣ ។

**អកុសល.១០ ចេ.២៧ ⟶ តទា.១០ ចេ.៣៣**

**( ៦ ) អកុសលំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ អកុសលេ និរុទ្ធេ វិបាកោ តទារម្មណតា ឧប្បជ្ជតិ ។**

បុគ្គលត្រេកអររីករាយ ភ្លើតភ្លើន នឹងអកុសលនោះ
ព្រោះប្រារព្ធនូវអកុសលនោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង
វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង

កាលដែលអកុសលនោះរលត់ទៅហើយ

វិបាក ( តទាលម្ពណចិត្ត ) កើតឡើង ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = តទាលម្ពណចិត្ត ១១ ដួង ចេតសិក ៣៣ ។

**អកុ.១២ ចេ.២៧ ⟶ តទា.១១ ចេ.៣៣**

**( ៧ ) អកុសលា ខន្ធា ចេតោបរិយញ្ញាណស្ស**
**បុព្វេនិវាសានុស្សតិញ្ញាណស្ស យថាកម្មុបគញ្ញាណស្ស**
**អនាគតំសញ្ញាណស្ស អាវជ្ជនាយ**
**អារម្មណប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ទាំងឡាយ ជាបច្ច័យនៃចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណ អនាគតំសញ្ញាណ មនោទ្វារាវជ្ជនៈ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួងមនោទ្វារាវជ្ជន ១ ចេតសិក ៣០ ។



**អកុ.១២ ចេ.២៧ ⟶ អភិ.កិ.១ មនោទ្វារ.១ ចេ.៣០**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។ បើបច្ចយុប្បន្ន មានបដិសន្ធិកាលផងដែរ ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុរោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលបុគ្គល ៤ ពួក។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងមនោទ្វារ ។ បច្ចយុប្បន្នៈ ប្រព្រឹត្តទៅក្រៅទ្វារក៏មាន ។

## បញ្ហាវារៈទី ៧

**អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ រូប ២៨ និព្វាន ។

**បច្ចយុប្បន្ន** = កាមាវចរវិបាកចិត្ត ២៣ ដួង កាមាវចរកិរិយាចិត្ត ១១ ដួង វិញ្ញាណញ្ចាយតនកិរិយាចិត្ត

១ ដួង នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ ដួង អភិញ្ញាកិរិយាចិត្ត ១ ដួង លោកុត្តរវិបាក-ចិត្ត ៤ ដួង ចេតសិក ៣៦ ( វៀរអប្បមញ្ញា ២ ) ។

**( ១ ) អរហា ផលំ បច្ចវេក្ខតិ ។**

ព្រះអរហន្ត ពិចារណានូវអរហត្តផល ដោយបច្ចវេក្ខណញ្ញាណ ។

**បច្ច័យ** = អរហត្តផលចិត្ត ១ ដួង ចេតសិក ៣៦ ។

**បច្ចុប្បន្ន** = មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**អរហត្តផល ១ ចេ.៣៦ ⟶ មហាកិ.សម្ប.៤ ចេ.៣៣**

**( ២ ) និព្វានំ បច្ចវេក្ខតិ ។**

ព្រះអរហន្ត ពិចារណានូវព្រះនិព្វាន ដោយបច្ចវេក្ខណញ្ញាណ ។

**បច្ច័យ** = និព្វាន ។

**បច្ចុប្បន្ន** = មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង



ចេតសិក ៣៣ ។

**និព្វាន ⟶ មហាកិ.សម្ប.៤ ចេ.៣៣**

**( ៣ ) និព្វានំ ផលស្ស អាវជ្ជនាយ អារម្មណប្បច្ចយេន បច្ចយោ ។**

ព្រះនិព្វាន ជាបច្ច័យនៃលោកុត្តរវិបាកចិត្ត និងមនោទ្វារាវជ្ជនចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = និព្វាន ។

**បច្ចុប្បន្ន** = លោកុត្តរវិបាកចិត្ត ៤ ដួង ចេតសិក ៣៦ មនោទ្វារាវជ្ជចិត្ត ១ ដួង ចេតសិក ១១ ។

**និព្វាន ⟶ ផល.៤ ចេ.៣៦ មនោទ្វារ.១ ចេ.១១**

**( ៤ ) អរហា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ សោតំ ឃានំ ជីវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ វិបាកាព្យាកតេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។**

ព្រះអរហន្ត ឃើញច្បាស់នូវចក្ខុថា មិនទៀង ជាទុក្ខ ជាអនត្តា និងឃើញ ច្បាស់នូវត្រចៀក ច្រមុះ អណ្តាត កាយ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ហទយវត្ថុ វិបាកអព្យាកតក្ខន្ធ កិរិយាអព្យាកតក្ខន្ធ ថា

មិនទៀង ជាទុក្ខ ជាអនត្តា ដោយមហាកិរិយា ។

**បច្ច័យ** = ឱឡារិករូប ១២ ហទយវត្ថុ ១ លោកិយ-
វិបាកចិត្ត ៣២ ដួង និងកិរិយាចិត្ត ២០ ដួង
ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = មហាកិរិយាចិត្ត ៨ ដួង ចេតសិក ៣៣ ។

**ឱឡា.រូ.១២ ហទយ.១ លោកិយវិ.៣២ កិ.២០ ចេ.៣៥**

**⟶ មហាកិ.៨ ចេ.៣៣ ។**

**( ៥ ) ទិព្វេន ចក្ខុនា រូបំ បស្សតិ ។**

ព្រះអរហន្ត ឃើញរូបដោយចក្ខុទិព្វ ។

**បច្ច័យ** = រូបារម្មណ៍ ជាបច្ចុប្បន្ន ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០
ដែលប្រព្រឹត្តទៅជាចក្ខុទិព្វ ។

**រូបា.១ ⟶ អភិ.កិ.១ ចេ.៣០**

**( ៦ ) ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ។**

ព្រះអរហន្ត ស្តាប់ឮសំលេង ដោយទិព្វសោត ។



**បច្ច័យ** = សទ្ទារម្មណ៍ ជាបច្ចុប្បន្ន ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០
ដែលប្រព្រឹត្តទៅជា ទិព្វសោត ។

**សទ្ទ.១ ⟶ អភិ.កិ.១ ចេ.៣០**

**( ៧ ) ចេតោបរិយញ្ញាណេន វិបាកាព្យាកតកិរិយាព្យាកត**
**ចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**

ព្រះអរហន្ត ដឹងចិត្តអ្នកដទៃដែលព្រមព្រៀងដោយអព្យាកត-ចិត្ត វិបាក ឬ កិរិយា ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០ ដួង
ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០
ដែលប្រព្រឹត្តទៅជា ចេតោបរិយញ្ញាណ ។

**វិ.៣៦ កិ.២០ ចេ.៣៨ ⟶ អភិ.កិ.១ ចេ.៣០**

**( ៨ ) អាកាសានញ្ចាយតនកិរិយំ វិញ្ញាណញ្ចាយតនកិរិយស្ស**
**អារម្មណប្បច្ចយេន បច្ចយោ ។**

អាកាសានញ្ចាយតនកិរិយា ជាបច្ច័យនៃវិញ្ញាណញ្ចាយតនកិរិយា ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកាសានញ្ចាយតនកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។

**អាកា.កិ.១ ចេ.៣០ ⟶ វិញ្ញា.កិ.១ ចេ.៣០**

**( ៩ ) អាកិញ្ចញ្ញាយតនកិរិយំ នេវសញ្ញានាសញ្ញាយតនកិរិយស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អាកិញ្ចញ្ញាយតនកិរិយា ជាបច្ច័យនៃនេវសញ្ញានាសញ្ញាយតនកិរិយា ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = អាកិញ្ចញ្ញាយតនកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។

**បច្ចយុប្បន្ន** = នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ ដួង ចេតសិក ៣០ ។

**អាកិ.កិ.១ ចេ.៣០ ⟶ នេវ..កិ.១ ចេ.៣០**



**( ១០ ) រូបាយតនំ ចក្ខុវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

រូបារម្មណ៍ ជាបច្ច័យនៃចក្ខុវិញ្ញាណចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = រូបារម្មណ៍ ។

**បច្ចយុប្បន្ន** = ចក្ខុវិញ្ញាណចិត្ត ២ ដួង ចេតសិក ៧ ។

**រូបា. ⟶ ចក្ខុវិ..២ ចេ.៧**

**( ១១ ) សទ្ទាយតនំ សោតវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

សទ្ទារម្មណ៍ ជាបច្ច័យនៃសោតវិញ្ញាណចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = សទ្ទារម្មណ៍ ។

**បច្ចយុប្បន្ន** = សោតវិញ្ញាណចិត្ត ២ ដួង ចេតសិក៧ ។

**សទ្ទ. ⟶ សោតវិ..២ ចេ.៧**

**( ១២ ) គន្ធាយតនំ ឃានវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ។**

គន្ធារម្មណ៍ ជាបច្ច័យនៃឃានវិញ្ញាណចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = គន្ធារម្មណ៍ ។

**បច្ចយុប្បន្ន** = ឃានវិញ្ញាណចិត្ត ២ ដួង ចេតសិក ៧ ។

**គន្ធា.** ⟶ **ឃានវិ..២ ចេ.៧**

**( ១៣ ) រសាយតនំ ជិវ្ហាវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

រសារម្មណ៍ ជាបច្ច័យនៃជិវ្ហាវិញ្ញាណចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = រសារម្មណ៍ ។

**បច្ចយុប្បន្ន** = ជិវ្ហាវិញ្ញាណចិត្ត ២ ដួង ចេតសិក ៧ ។

**រសា.** ⟶ **ជិវ្ហាវិ..២ ចេ.៧**

**( ១៤ ) ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

ផោដ្ឋព្វារម្មណ៍ ជាបច្ច័យនៃកាយវិញ្ញាណចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = ផោដ្ឋព្វារម្មណ៍ ។

**បច្ចយុប្បន្ន** = កាយវិញ្ញាណចិត្ត ២ ដួង ចេតសិក ៧ ។

**ផោដ្ឋ.** ⟶ **កាយវិ..២ ចេ.៧**

**( ១៥ ) អព្យាកតា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំសញ្ញាណស្ស អាវជ្ជនាយ**



**អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ អនាគតំសញ្ញាណ និងមនោទ្វារាវជ្ជនចិត្ត ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ រូប ២៨ និព្វាន ។

**បច្ចយុប្បន្ន** = អភិញ្ញាកិរិយាចិត្ត ១ ដួង ចេតសិក ៣០ មនោទ្វារាវជ្ជនចិត្ត ១ ចេតសិក ១១ ។

**វិបា.៣៦ កិ.២០ រូប.២៨ និព្វាន** ⟶ **អភិ.កិ.១ ចេ.៣០ មនោទ្វា.១ ចេ.១១ ។**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងឯកវោការ ចតុវោការ និងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផល-

បុគ្គល ៤ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងទ្វារ ៦ និងក្រៅទ្វារ តាមសមគួរ ។

ក្នុង ១៥ ចំណុច ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង មិនបានគ្រប់អង្គធម៌ក្នុងបាលីវិធីដែលជាបញ្ហាវារៈឡើយ បើពោលឲ្យបានគ្រប់អង្គធម៌ទាំងអស់នោះ មិនចំពោះតែក្នុងបវត្តិកាលប៉ុណ្ណោះ ព្រោះវិបាកាព្យាកតៈប្រព្រឹត្តទៅទាំងក្នុងបដិសន្ធិកាល និងចុតិកាល , ដូច្នេះ មហាកិរិយា គឺ កិរិយាព្យាកតៈប្រព្រឹត្តទៅក្នុងមរណាសន្នកាលក៏មានជាដើម សុទ្ធតែជាកាលប្រព្រឹត្តទៅដោយអារម្មណប្បច្ច័យទាំងអស់ ។ ចំណែកឯកវេការរកត គ្រាន់តែធ្វើជាអារម្មណ៍ប៉ុណ្ណោះ មិនមានអារម្មណ៍ឡើយ ។

## បញ្ហាវារៈ ទី ៨

### អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណប្បច្ច័យ ។



**បច្ច័យ** = វិបាកចិត្ត ៣៥ ដួង ( វៀរអរហត្តផល) កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ រូប ២៨ និព្វាន ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង អភិញ្ញា-កុសលចិត្ត ១ ដួង មគ្គចិត្ត ៤ ដួង ចេតសិក ៣៦ ។

**វិបា.៣៥ កិ.២០ រូប.២៨ និព្វាន ⟶ មហាកុ.៨ អភិ.កុ.១ មគ្គ.៤ ចេ.៣៦**

### ( ១ ) សេក្ខា ផលំ បច្ចវេក្ខន្តិ ។

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណានូវផល ។

**បច្ច័យ** = ផលចិត្ត ៣ ដួង ខាងក្រោម ចេតសិក ៣៦។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**ផល.៣ ចេ.៣៦ ⟶ មហាកុ.សម្ប.៤ ចេ.៣៣**

( ២ ) និព្វានំ បច្ចវេក្ខន្តិ ។

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណានូវព្រះនិព្វាន ។

**បច្ច័យ** = ព្រះនិព្វាន ។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត ៤ដួង ចេតសិក ៣៣ ។

**និព្វាន ⟶ មហាកុ.សម្ប.៤ ចេ.៣៣**

( ៣ ) និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស អារម្មណប្បច្ចយេន បច្ចយោ ។

ព្រះនិព្វាន ជាអារម្មណ៍នៃគោត្រភូញាណ វោទាន និងមគ្គ ៤ ។

**បច្ច័យ** = ព្រះនិព្វាន ។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ដែលជាគោត្រភូញាណ វោទាន និងមគ្គចិត្ត ៤ ដួង ចេតសិក ៣៦ ។

**និព្វាន ⟶ មហាកុ.សម្ប.៤ ចេ.៣៣ មគ្គ.៤ ចេ.៣៦**



( ៤ ) សេក្ខា វា បុថុជ្ជនា វា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ

**សោតំ ....... ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ ....... វិបាកាព្យាកេ កិរិយាព្យាកតេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយក្តី តិហេតុកបុថុជ្ជនទាំងឡាយក្តី ឃើញច្បាស់នូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រូប សំលេង ក្លិន រសេ ផោដ្ឋព្វៈ ហទយវត្ថុ វិបាកាព្យាកតក្ខន្ធ កិរិយាព្យាកតក្ខន្ធ ថាមិនទៀង ជាទុក្ខ ជាអនត្តា ។

**ឱឡា.រូប.១២ ហទយ.១ លោកិ.៣២ កិ.២០ ចេ.៣៥**

**⟶ ម.កុ.៨ ចេ.៣៣ ។**

( ឱឡារិករូប ១២ គឺ វត្ថុរូប ៥ វិសយរូប ៧ )

( ៥ ) ទិព្វេន ចក្ខុនា រូបំ បស្សន្តិ ។

ព្រះសេក្ខបុគ្គលទាំងឡាយ ឬតិហេតុកបុថុជ្ជន ឃើញរូបដោយ

ទិព្វចក្ខុ ។

**បច្ច័យ** = បច្ចុប្បន្នរូបារម្មណ៍ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣៣ ដែលជាទិព្វចក្ខុ ។

រូបា. ⟶ អភិ.កុ.១ ចេ.៣០

**( ៦ ) ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ឬតិហេតុកបុថុជ្ជន ឃើញរូបដោយទិព្វចក្ខុ ។

**បច្ច័យ** = បច្ចុប្បន្នសទ្ទារម្មណ៍ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣៣ ដែលជាទិព្វសោត ។

សទ្ទ. ⟶ អភិ.កុ.១ ចេ.៣០

**( ៧ ) ចេតោបរិយញ្ញាណេន វិបាកាព្យាកតកិរិយាព្យាកត ចិត្តសមង្គិស្ស ចិត្តំ ជានាតិ ។**



ព្រះសេក្ខបុគ្គល ឬតិហេតុកបុថុជ្ជន ដឹងចិត្តអ្នកដទៃដែលព្រមព្រៀងដោយអព្យាកតចិត្ត វិបាក ឬកិរិយា ដោយចេតោបរិយញ្ញាណ ។

**បច្ច័យ** = វិបាកចិត្ត ៣៥ ដួង ( វៀរអរហត្តផល ) កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣០ ដែលប្រព្រឹត្តទៅជាចេតោបរិយញ្ញាណ ។

**វិ.៣៥ កិ.២០ ចេ.៣៨ ⟶ អភិ.កុ.១ ចេ.៣០**

**( ៨ ) អព្យាកតា ខន្ធា ឥទ្ធិវិធញ្ញាណស្ស ចេតោបរិយញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណស្ស អនាគតំសញ្ញាណស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតក្ខន្ធទាំងឡាយ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ អនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = វិបាកចិត្ត ៣៥ ដួង ( វៀរអរហត្តផល )

កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ រូប ២៨ និព្វាន ( និព្វានមិនមែនជាខន្ធ ) ។

**បច្ចយុប្បន្ន** = អភិញ្ញាកុសលចិត្ត ១ ដួង ចេតសិក ៣០។

**វិបា.៣៥ កិ.២០ រូប.២៨ និព្វាន ⟶ អភិ.កុ.១ ចេ.៣០**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល និងបដិសន្ធិកាល តាមសមគួរ ។

ដោយភូមិ : គឺ គ្រប់ភូមិទាំងអស់ជាអារម្មណប្បច្ច័យ ប៉ុន្តែ បច្ចយុប្បន្ន មានតែក្នុងចតុវោការភូមិ បញ្ចវោការភូមិប៉ុណ្ណោះ តាមសមគួរ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងព្រះអរិយបុគ្គល ៧ ពួក តាមសមគួរ ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ មនោទ្វារ និងក្រៅទ្វារ តាមសមគួរ ។

**( ទាំងអស់នេះ គិតតាមអដ្ឋធម៌ក្នុងបាលីវិធី )**



## បញ្ហាវារៈ ទី ៩

**អព្យាកតោធម្មោ អកុសលស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណប្បច្ច័យ ។

**បច្ច័យ** = រូប ២៨ លោកិយវិបាកចិត្ត ៣២ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ដួង ចេតសិក ២៧ ។

**រូប.២៨ លោកិ.វិបា.៣២ កិ.២០ ⟶ អកុ.កុ.១ ចេ.៣០**

**ចក្ខុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ សោតំ ......... ឃានំ ជីវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ ........ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិចិកិច្ឆា ឧប្បជ្ជតិ ឧទ្ធច្ចំ ឧប្បជ្ជតិ ទោមនស្សំ ឧប្បជ្ជតិ ។**

បុគ្គលរមែងត្រេកអរីករាយ ភ្លើតភ្លើនក្នុងចក្ខុ ព្រោះប្រារព្ធនូវ

ចក្ខុ រាគៈកើតឡើង ទិដ្ឋកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។ល។ សោតៈ ឃានៈ ជីវ្ហា កាយ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ហទយវត្ថុ វិបាកព្យាកតក្ខន្ធ កិរិយាព្យាកតកន្ធ កាលប្រារព្ធនូវអារម្មណ៍នោះ ៗ រាគៈកើតឡើង ទិដ្ឋិកើតឡើង វិចិកិច្ឆាកើតឡើង ឧទ្ធច្ចៈកើតឡើង ទោមនស្សកើតឡើង ។

**បច្ច័យ** = ឱឡារិករូប ១២ ហទយវត្ថុរូប ១ លោកិយវិបាកចិត្ត ៣២ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។ ( មានរាគៈ ទិដ្ឋិ វិចិកិច្ឆា ឧទ្ធច្ចៈ ទោមនស្សជាប្រធាន ) ។

**ឱឡា.រូប.១២ ហទយ.១ លោកិ.វិបា.៣២ កិ.២០ ចេ.៣៥**

**⟶ អកិ.កុ.១ ចេ.៣០ ។**

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល និងបដិ-



សន្ធិកាល តាមសមគួរ ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភពបញ្ចវោការភូមិ តាមសមគួរ ( គ្រប់ភូមិទាំងអស់ជាអារម្មណ៍ ) ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន និងផលបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងមនោទ្វារ និងក្រៅទ្វារផង តាមសមគួរ ។

---

## អធិបតិប្បច្ច័យ

**អធិបតិប្បច្ច័យ** បែកចេញជា ២ ផ្នែក គឺ ៖-

១. អារម្មណាធិបតិប្បច្ច័យ

២. សហជាតាធិបតិប្បច្ច័យ

**១.អារម្មណាធិបតិប្បច្ច័យ យំ យំ ធម្មំ គរុំ កត្វា យេ យេ ធម្មា ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា តេ តេ ធម្មា តេសំ តេសំ ធម្មានំ អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

ពួកធម៌ណា ៗ គឺ ចិត្ត ចេតសិកធម៌កើតឡើង ព្រោះធ្វើនូវពួកធម៌ឯណានីមួយឲ្យធ្ងន់ ពួកធម៌នោះ ៗ ជាបច្ច័យនៃធម៌នោះ ៗ ដោយអារម្មណាធិបតិប្បច្ច័យ ។

**យំ យំ ធម្មំ** និង **តេ តេ ធម្មា** នេះជាបច្ច័យ ។

**យេ យេ ធម្មា** និង **តេសំ តេសំ ធម្មានំ** ជាបច្ចយុប្បន្ន ។

**បច្ច័យ** = អារម្មណ៍ទាំង ៦ បានដល់ ឥដ្ឋនិប្ផន្នរូប ១៨ ( វៀរអសភាវរូប ១០ ) ចិត្ត ៨៤ ( វៀរទោសមូលចិត្ត ២ ដួង មោហមូលចិត្ត ២ ដួង ទុក្ខសហគតកាយវិញ្ញាណ ១ ) ចេតសិក ៤៧ ( វៀរ ទោចតុក: ៤ និងវិចិកិច្ឆា ១ ) និង និព្វាន ។

**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង មហាកុសលចិត្ត ៨ ដួង មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង និងលោកុត្តចិត្ត ៨ ( សរុប



ចិត្ត ២៨ ដួង ) ចេតសិក ៤៥ ( វៀរ ទោចតុក: ៤ វិចិកិច្ឆា ១ អប្បមញ្ញា ២ ) ។

**បច្ចនិក** = លោកិយចិត្ត ៨១ ដួង ចេតសិក ៥២ ក្នុងនេះ លោភមូលចិត្ត ៨ ដួង មហាកុសលចិត្ត ៨ និងមហាកិរិយាញាណ-សម្បយុត្ត ៤ ដួង ព្រមទាំងចេតសិក សម្បយុត្ត មិនពិតប្រាកដ ( អនេកន្ត:លោកិយចិត្តុប្បាទ ដទៃអំពីចិត្តុប្បាទ ២០ ដួងទៀត ជាបច្ចនិក: ពិតប្រាកដ ) ( ជាឯកន្ត: ) ។

\+ រូបទាំងអស់ ។

**ដោយលក្ខណ: ជាតិ កាល សត្តិ**

ដោយលក្ខណ: : មានពីរ គឺ ជាទីតោង ជាទីរីករាយ ( អារម្មណ: ) និងមានភាពជាធំ ( អធិបតិ ) ១ ។ ទាំងពីរនេះ ជាលក្ខណ:នៃអារម្មណាធិបតិប្បច្ច័យ ។

ដោយជាតិ : គឺ ជាប្រភេទអារម្មណជាតិ ។

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងកាលទាំង ៣ ( តេកាលិកៈ ) និងជាកាលវិមុត្តិ ។

ដោយសត្តិ : គឺ អំណាច ប្រព្រឹត្តទៅក្នុងសត្តិទាំងពីរ ។

## ៣.សហជាតាធិបតិប្បច្ច័យ

**( ១ ) ឆន្ទាធិបតិ ឆន្ទសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

ឆន្ទាធិបតិ ជាបច្ច័យនៃធម៌ទាំងឡាយ ដែលប្រកបជាមួយនឹងឆន្ទៈនោះ ព្រមទាំងចិត្តជរូបដែលមានឆន្ទាធិបតិ និងសម្បយុត្តធម៌របស់ឆន្ទាធិបតិនោះ ជាសមុដ្ឋាន ដោយសហជាតាធិបតិប្បច្ច័យ ។

**បច្ច័យ** = ឆន្ទចេតសិក ក្នុងសាធិបតិជវនចិត្ត ៥២ ដួង ( គឺចិត្តដែលប្រកបដោយហេតុ ២ និងហេតុ ៣ ) ( ក្នុង ជវនចិត្ត ៥៥ ដួង វៀរមោហមូលចិត្ត ២ ដួង និង ហសិតុប្បាទចិត្ត ១ ដួង ) ។

**បច្ចយុប្បន្ន** = សាធិបតិជវនចិត្ត ៥២ ដួង ចេតសិក ៥០ ( វៀរឆន្ទៈ វិចិកិច្ឆា ) សាធិបតិចិត្តជរូប ១៧ ។



**សាធិបតិជវនចិត្ត ៥២** គឺ កាមជវនចិត្ត ២៦ ( មហាកុសលចិត្ត ៨ ដួង មហាកិរិយាចិត្ត ៨ ដួង លោភមូលចិត្ត ៨ ដួង ទោសមូលចិត្ត ២ ដួង ) , និងអប្បនាជវនចិត្ត ២៦ ( មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរចិត្ត ៨ ដួង ) ។

**សាធិបតិជវនចិត្ត** = កាមជវន ២៦ + អប្បនាជវន ២៦ = ៥២

**( ២ ) វីរិយាធិបតិ វីរិយសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

វីរិយាធិបតិ ជាបច្ច័យនៃសាធិបតិជវនចិត្តនោះ និងចេតសិក ព្រមទាំងសាធិបតិចិត្តជរូប ដោយសហជាតាធិបតិប្បច្ច័យ ។

**បច្ច័យ** = វីរិយចេតសិក ក្នុងសាធិបតិជវនចិត្ត ៥២ ដួង ( គឺ កាមជវនចិត្ត ២៦ ដួង និងអប្បនាជវន ២៦ ។

**បច្ចយុប្បន្ន** = សាធិបតិជវនចិត្ត ៥២ ដួង ចេតសិក ៥០ ( វៀរវីរិយៈ វិចិកិច្ឆា ) ។

**( ៣ ) ចិត្តាធិបតិ ចិត្តសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

សាធិបតិចិត្ត ៥២ ជាបច្ច័យនៃចេតសិកសម្បយុត្ត និងសាធិបតិចិត្តជរូប ដោយសហជាតាធិបតិប្បច្ច័យ ។

**បច្ច័យ** = សាធិបតិជវនចិត្ត ៥២ ដួង ។

**បច្ចយុប្បន្ន** = ចេតសិក ៥១ ( វៀរវិចិកិច្ឆា ) សាធិបតិចិត្តជរូប ១៧ ។

**( ៤ ) វីមំសាធិបតិ វីមំសសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

វីមំសា គឺ បញ្ញា ជាអធិបតិដល់សម្បយុត្តធម៌នោះ និងសាធិបតិចិត្តជរូប ដោយសហជាតាធិបតិប្បច្ច័យ ។

បច្ច័យ = បញ្ញាក្នុងតិហេតុកសាធិបតិជវនចិត្ត ៣៤ ដួង ( គឺ កាមជវនចិត្ត ៨ ដួង និង អប្បនាជវន ២៦ ។



( កាមជវនចិត្ត ៨ ដួង ក្នុងទីនេះ គឺ មហាកុ.សម្ប.៤ មហាកិ.សម្ប.៤ ) ។

**បច្ចយុប្បន្ន** = តិហេតុកសាធិបតិជវនចិត្ត ៣៤ ដួង ចេតសិក ៣៧ ( វៀរបញ្ញា ) និងសាធិបតិចិត្តជរូប ១៧ ។

**សរុបអត្ថធម៌**

**បច្ច័យ** = អធិបតិប្បច្ច័យ ៤ បានដល់ **ឆន្ទ វីរិយ វីមំសា** ក្នុងជវន ៥២ តាមសមគួរ និង ជវនចិត្ត ៥២ ដួង ។

**បច្ចយុប្បន្ន** = ជវនចិត្ត ៥២ ដួង ចេតសិក ៥១ ( វៀរវិចិកិច្ឆា ) ក្នុងនោះត្រូវវៀរអត្ថធម៌ដែលជាបច្ច័យ សាធិបតិចិត្តជរូប ១៧ ។

**បច្ចនិក** = កាមាវចរចិត្ត ៥៤ ដួង មហគ្គតវិបាកចិត្ត ៩ ដួង ( កាមជន ២៦ ដួង មិនប្រាកដ ព្រោះពេលខ្លះ ជាបច្ចយុប្បន្ន ) ចេតសិក ៥២ រួមទាំងអត្ថធម៌ដែលជា

អធិបតិប្បច្ច័យណាមួយ និរាធិបតិចិត្តជរូប បដិសន្ធិកម្មជរូប ពាហិររូប អាហារជរូប ឧតុជរូប អសញ្ញសត្តរូប បវត្តិកម្មជរូប ( រូបទាំងអស់នេះ ក្រៅអំពីសាធិបតិចិត្តជរូប ១៧ ) ។

**ដោយលក្ខណ ជាតិ កាល សត្តិ**

ដោយលក្ខណៈ : មានលក្ខណៈសំខាន់ពីរបែប គឺ មានសភាពជាធំ ( អធិបតិ ) ១ និងកើតព្រមគ្នាចំពោះបច្ច័យ និងបច្ចយុប្បន្នៈ ( សហជាត ) ១ ។

ដោយជាតិ : គឺ សហជាត ជាតិ ។

ដោយកាល : គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ : គឺ សត្តិទាំងពីរ ។

## អារម្មណាធិបតិប្បច្ច័យ

**( មាន ៧ បញ្ហាវារៈ )**

### បញ្ហាវារៈទី ១



**កុសលោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២០ ដួង ( វៀរអរហត្តមគ្គ ) ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ។

**កុ.២០ ចេ.៣៨ ⟶ កុ.៨ ចេ.៣៣**

( បញ្ហាវារៈមាន ៥ ចំណុច ដូច ៥ ចំណុចខាងដើមនៃបញ្ហាវារៈទី ១ ក្នុងអារម្មណប្បច្ច័យដែរ គ្រាន់តែថែម " **គរុំ កត្វា** " មុន " **បច្ចវេក្ខតិ** និង **បច្ចវេក្ខន្តិ** " ឯចំណែកអង្គធម៌វិញ ទាំងបច្ច័យ ទាំងបច្ចយុប្បន្ន ក៏ដូចគ្នាជាមួយនឹងអារម្មណប្បច្ច័យផងដែរ ។

### បញ្ហាវារៈ ទី ២

**កុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**បច្ច័យ** = លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ។
**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

កុ.១៧ ចេ.៣៨ ⟶ លោភ.៨ ចេ.២២

( ១ ) ទានំ ទត្វា សីលំ សមាទយិត្វា ឧបោសថកម្មំ កត្វា តំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។

បុគ្គលបានធ្វើទានហើយ សមាទានសីលហើយ ធ្វើឧបោសថកម្មហើយ ដោយសេចក្ដីត្រេកអររីករាយ ភ្ញើតភ្ញើនដ៏ធ្ងន់ កាលនឹកដល់កុសលនោះដ៏ធ្ងន់ទៀត រាគៈកើតឡើង ទិដ្ឋិកើតឡើង ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៦ ។
**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មាន រាគៈ ទិដ្ឋិ ជាប្រធាន ។

កុ.៨ ចេ.៣៦ ⟶ លោភ.៨ ចេ.២២

( ២ ) បុព្វេ សុចិណ្ណានិ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។

**បច្ច័យ** = មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៨ ។



**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មាន រាគៈ ទិដ្ឋិ ជាប្រធាន ។

កុ.៨ ចេ.៣៨ ⟶ លោភ.៨ ចេ.២២

( ៣ ) ឈានា វុដ្ឋហិត្វា ឈានំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។

បុថុជ្ជន និងព្រះសេក្ខបុគ្គលដែលជាឈានលាភី កាលចេញចាកឈានហើយ មានសេចក្ដីត្រេកអររីករាយ ភ្ញើតភ្ញើនក្នុងឈានរបស់ខ្លួនដ៏ធ្ងន់ កាលនឹកដល់ឈាននោះហើយ រាគៈកើតឡើង ទិដ្ឋិកើតឡើង ( តាមសមគួរ ) ។

**បច្ច័យ** = មហគ្គតកុសលចិត្ត ៩ ដួង ចេតសិក ៣៥ ។
**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មាន រាគៈ ទិដ្ឋិ ជាប្រធាន ។

មហ.កុ.៩ ចេ.៣៥ ⟶ លោភ.៨ ចេ.២២

## បញ្ហាវារៈ ទី ៣

### កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន

បច្ចយោ ។

កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**អរហា មគ្គា វុដ្ឋហិត្វា មគ្គំ គរុំ កត្វា បច្ចវេក្ខតិ ។**

ព្រះអរហន្តចេញចាកមគ្គ ហើយពិចារណាធ្វើឲ្យធ្ងន់ក្នុងមគ្គ ដោយបច្ចវេក្ខណញ្ញាណ ។

**បច្ច័យ** = អរហត្តមគ្គចិត្ត ១ ដួង ចេតសិក ៣៦ ។

**បច្ចយុប្បន្ន** = មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**អរហត្តមគ្គ.១ ចេ.៣៦ ⟶ មហាកិ.សំ.៤ ចេ.៣៣**

## បញ្ហាវារៈ ទី ៤

**អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។



**បច្ច័យ** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

**លោភ.៨ ចេ.២២ ⟶ លោភ.៨ ចេ.២២**

**( ១ ) រាគំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គលណាមានសេចក្តីរីករាយ ភ្លើតភ្លើន ធ្វើរាគៈឲ្យធ្ងន់ក្នុងចិត្ត រាគៈកើតឡើង ទិដ្ឋិកើតឡើង ។

**បច្ច័យ** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មានរាគៈជាប្រធាន ។

**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មានរាគៈ និងទិដ្ឋិ ជាប្រធាន ។

**លោភ.៨ ចេ.២២ ⟶ លោភ.៨ ចេ.២២**

**( ២ ) ទិដ្ឋឹ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គលណា មានសេចក្តីរីករាយ ត្រេកអរ ធ្វើទិដ្ឋិឲ្យធ្ងន់ក្នុងចិត្ត រាគៈកើតឡើង ទិដ្ឋិកើតឡើង ។

**បច្ច័យ** = លោភមូលចិត្តទិដ្ឋិគតសម្បយុត្តចិត្ត ៤ ដួង ចេតសិក ២១ មានទិដ្ឋិជាប្រធាន ។

**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ មាន

រាគៈ និងទិដ្ឋិ ជាប្រធាន ។

**លោភ.សម្ប.៤ ចេ.២១ ⟶ លោភ.៨ ចេ.២២**

## បញ្ហាវារៈ ទី ៥

**អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**( ១ ) អរហា ផលំ គរុំ កត្វា បច្ចវេក្ខតិ និព្វានំ គរុំ កត្វា បច្ចវេក្ខតិ ។**



ព្រះអរហន្ត ពិចារណាអរហត្តផល ពិចារណាព្រះនិព្វាន ដោយធ្វើឲ្យធ្ងន់ក្នុងចិត្ត ដោយបច្ចវេក្ខណញ្ញាណ ។

**បច្ច័យ** = អរហត្តផលចិត្ត ១ ដួង ចេតសិក ៣៦ និព្វាន ។

**បច្ចយុប្បន្ន** = មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

**អរហ.១ ចេ.៣៦ ⟶ កិ.សម្ប.៤ ចេ.៣៣**

**( ៣ ) និព្វានំ ផលស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

ព្រះនិព្វាន ជាបច្ច័យជួយឧបការៈដល់ផលចិត្ត ដោយអារម្មណាធិបតិប្បច្ច័យ ។

**បច្ច័យ** = ព្រះនិព្វាន ។

**បច្ចយុប្បន្ន** = ផលចិត្ត ៤ ដួង ចេតសិក ៣៦ ។

**និព្វាន ⟶ ផល.៤ ចេ.៣៦**

## បញ្ហាវារៈ ទី ៦

**អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន**

### បច្ចយោ ។

អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**( ១ ) សេក្ខា ផលំ គរុំ កត្វា បច្ចវេក្ខន្តិ និព្វានំ គរុំ កត្វា បច្ចវេក្ខន្តិ ។**

ព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណាឲ្យធ្ងន់ក្នុងចិត្ត នូវផលខាងក្រោម ៣ និងព្រះនិព្វាន ។

**បច្ច័យ** = ផលចិត្ត ៣ ដួង ខាងក្រោម ចេតសិក ៣៦ និព្វាន ។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ចេតសិក ៣៣ ។

ផល.៣ ចេ.៣៦ ⟶ កុ.សម្ប.៤ ចេ.៣៦

**( ២ ) និព្វានំ គោត្រភុស្ស វោទានស្ស មគ្គស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

ព្រះនិព្វាន ជាបច្ច័យនៃគោត្រភូ វោទាន និងមគ្គទាំង ៤ ដោយអារម្មណាធិបតិប្បច្ច័យ ។



**បច្ច័យ** = ព្រះនិព្វាន ។

**បច្ចយុប្បន្ន** = មហាកុសលញាណសម្បយុត្តចិត្ត៤ដួង ចេតសិក ៣៣ ដួង មគ្គចិត្ត ៤ ដួង ចេតសិក ៣៦ ។

ព្រះនិព្វាន ⟶ កុ.សម្ប.៤ ចេ.៣៣ មគ្គ.៤ ចេ.៣៦

## បញ្ហាវារៈ ទី ៧

### អព្យាកតោ ធម្មោ អកុសលស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ

អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

**ចក្ខុំ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ សោតំ ឃានំ ជីវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ វត្ថុំ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ គរុំ កត្វា អស្សាទេតិ អភិនន្ទតិ តំ គរុំ កត្វា រាគោ ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ ។**

បុគ្គលត្រេកអរីករាយ ភ្លើតភ្លើនក្នុងភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ រូប សំលេង ក្លិន រស ផោដ្ឋព្វ ហទយវត្ថុ វិបាកក្ខន្ធ

កិរិយាខន្ធ ដោយដាក់ចិត្តឲ្យ ចូនក្នុងធម៌នោះ រាគៈកើតឡើង ទិដ្ឋិកើតឡើង ។

**បច្ច័យ** = ឥដ្ឋនិប្ផន្នរូប ១៨ ប៉ុន្តែក្នុងបាលីមាន ១៣ រូប គឺ ឱឡារិករូប ១២ វត្ថុរូប ១ លោកិយវិបាក ៣១ ដួង ( វៀរទុក្ខ-កាយវិញ្ញាណ ) កិរិយាចិត្ត ២០ ដួង ចេតសិក ៣៥ ។

**បច្ចយុប្បន្ន** = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

ឥដ្ឋ.រូ.១៨ វិ.៣១ កិ.២០ ចេ.៣៥ ⟶ លោភ.៨ ចេ.២២

## សហជាតាធិបតិប្បច្ច័យ

( មាន ៧ បញ្ហាវារៈ )

### បញ្ហាវារៈ ទី ១

**កុសលោ ធម្មោ កុសលស្ស ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ**

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ ដោយសហជាតាធិបតិប្បច្ច័យ ។

កុ. ⟶ កុ.



**កុសលាធិបតិ សម្បយុត្តកានំ ខន្ធានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

អធិបតិកុសល ៤ ក្នុងកុសលចិត្ត ២១ ដួង ជាបច្ច័យនៃសម្ប-យុត្តក្ខន្ធ ៤ ឬ ៣ ដោយសហជាតាធិបតិប្បច្ច័យ ។

**បច្ច័យ** = អធិបតិ ៤ ឆន្ទៈ វិរិយៈ បញ្ញា និង កុសលចិត្តណាមួយ ក្នុងកុសលចិត្ត ២១ ដួង តាមសមគួរ ។

**បច្ចយុប្បន្ន** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ( វៀរអង្គធម៌ដែលជាអធិបតិ ) ។

### បញ្ហាវារៈ ទី ២

**កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស អារម្មណាធិបតិប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអារម្មណាធិបតិប្បច្ច័យ ។

កុ. ⟶ អព្យា.

**បច្ច័យ** = អធិបតិ ៤ ដែលជាកុសល នៅក្នុងកុសល-ចិត្ត ២១ ដួង ។

**បច្ចយុប្បន្ន** = កុសលាធិបតិចិត្តជរូប ១៧ ។

**កុសលាធិបតិ ចិត្តសមុដ្ឋានានំ រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

កុសលអធិបតី ជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋាន ដោយសហជាតាធិបតិប្បច្ច័យ ។

**កុ.អធិបតី ៤ ——→ សាធិបតិកុសលចិត្តជរូប ១៧**

## បញ្ហាវារៈ ទី ៣

**កុសលោ ធម្មោ កុសលស្ស ច អព្យាកតស្ស ច ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃកុសលធម៌ផង អព្យាកតធម៌ផង ដោយសហជាតាធិបតិប្បច្ច័យ ។

**កុ. ——→ កុ. អព្យា.**

**កុសលាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**



កុសលអធិបតី ជាបច្ច័យដល់នាមក្ខន្ធ ៤ ឬ ៣ និងដល់ចិត្តជរូប ដែលកើតពីកុសលអធិបតី ដោយសហជាតាធិបតិប្បច្ច័យ ។

**បច្ច័យ** = អធិបតី ៤ ជាកុសល ។

**បច្ចយុប្បន្ន** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ (វៀរអធិបតី) សាធិបតិចិត្តជរូប ១៧ ។

## បញ្ហាវារៈ ទី ៤

**អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយសហជាតាធិបតិប្បច្ច័យ ។

**អកុ. ——→ អកុ.**

**អកុសលាធិបតិ សម្បយុត្តកានំ ខន្ធានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** = អធិបតី ៣ ជាអកុសល ( វៀរបញ្ញា ) ប្រព្រឹត្តទៅក្នុងអកុសលចិត្ត ១០ ដួង

( វៀរមោហមូលចិត្ត ២ ដួង ) ចេតសិក ២៦ ។

បច្ចយុប្បន្ន = អកុសលចិត្ត ១០ ដួង ចេតសិក ២៦ ( វៀរវិចិកិច្ឆា និងអធិបតី ) ។

## បញ្ហាវារៈ ទី ៥

អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ

អកុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតាធិបតិប្បច្ច័យ ។

អកុ. ⟶ អព្យា.

អកុសលាធិបតិ ចិត្តសមុដ្ឋានានំ រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ

អកុសលធិបតី ជាបច្ច័យនៃរូបដែលមានចិត្តជាសមុដ្ឋាន ដោយ សហជាតាធិបតិប្បច្ច័យ ។

បច្ច័យ = អធិបតី ៣ ជាអកុសល ។

បច្ចយុប្បន្ន = សាធិបតិចិត្តជរូប ១៧ ។



## បញ្ហាវារៈ ទី ៦

អកុសលោ ធម្មោ អកុសលស្ស ច អព្យាកតស្ស ច ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ ។

អកុ. ⟶ អកុ. អព្យា.

អកុសលាធិបតិ សម្បយុត្តកានំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។

បច្ច័យ = អធិបតិ ៣ ជាអកុសល ។

បច្ចយុប្បន្ន = អកុសលចិត្ត ១០ ដួង ចេតសិក ២៦ ( វៀរវិចិកិច្ឆា និងអធិបតី ) អកុសលាធិបតិចិត្តជរូប ១៧ ។

## បញ្ហាវារៈ ទី ៧

អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស សហជាតាធិបតិប្បច្ចយេន បច្ចយោ ។

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ ។

អព្យា. ⟶ អព្យា.

វិបាកាព្យាកតា កិរិយាព្យាកតាធិបតិ សម្បយុត្តកានំ ខន្ធានំ

### ចិត្តសមុដ្ឋានានញ្ច

### រូបានំ សហជាតាធិបតិប្បច្ចយេន បច្ចយោ ។

**បច្ច័យ** = អធិបតី ៤ ជាអព្យាកត ( ផលចិត្ត ៤ កិរិយាចិត្ត ៨ + ៩ ) ។

**បច្ចយុប្បន្ន** = ផលចិត្ត ៤ ដួង ចេតសិក ៣៦ ( វៀរអធិបតី ) ចិត្តជរូប ១៥ ( វៀរវិញ្ញត្តិរូប ២ ) ។ កិរិយាចិត្ត ១៧ ដួង ចេតសិក ៣៥ ( វៀរអធិបតី ) ចិត្តជរូប ១៧ ។

**+ បូកសរុបបញ្ហាវារៈ ក្នុងអធិបតិប្បច្ច័យ ទាំងអស់មាន ១០ គឺ ៈ-**

| | | | | | |
|---|---|---|---|---|---|
| ១. | កុ → | កុ. | អារម្មណាធិបតិ | សហជាតាធិបតិ |
| ២. | កុ → | អកុ. | អារម្មណាធិបតិ | |
| ៣. | កុ → | អព្យា. | អារម្មណាធិបតិ | សហជាតាធិបតិ |
| ៤. | កុ. → | កុ. + អព្យា. | | សហជាតាធិបតិ |
| ៥. | អកុ → | អកុ. | អារម្មណាធិបតិ | សហជាតាធិបតិ |
| ៦. | អកុ. → | អព្យា. | | សហជាតាធិបតិ |
| ៧. | អកុ. → | អកុ. + អព្យា. | | សហជាតាធិបតិ |
| ៨. | អព្យា → | អព្យា. | អារម្មណាធិបតិ | សហជាតាធិបតិ |



| | | | | |
|---|---|---|---|---|
| ៩. | អព្យា → | កុ. | អារម្មណាធិបតិ |
| ១០. | អព្យា → | អកុ. | អារម្មណាធិបតិ |

( ដោយកុសលបទ មាន ៤ អកុសលបទ មាន ៣ អព្យាកតបទ មាន ៣ )

## អនន្តរប្បច្ច័យ

**( ១ ) ចក្ខុវិញ្ញាណធាតុ តំសម្បយុត្តកា ច ធម្មា មនោធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

ចក្ខុវិញ្ញាណធាតុ ២ ដួង និងសព្វចិត្តសាធារណចេតសិក ៧ ជាបច្ច័យដល់ មនោធាតុ ២ ដួង ធ្វើសម្បដិច្ឆន្នកិច្ច និងចេតសិក ១០ ( វៀរវីរយៈ បីតិ ឆន្ទៈ ) ដោយអនន្តរប្បច្ច័យ ។

**ចក្ខុ.វិ.២ ចេ.៧ → សម្បដិ.២ ចេ.១០**

**( ២ ) មនោធាតុ តំសម្បយុត្តកា ច ធម្មា មនោវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

មនោធាតុ ២ ដួង ជាវិបាកធម៌ និងចេតសិក ១០ ជាបច្ច័យ

ដល់មនោវិញ្ញាណធាតុ ៣ ដួង ធ្វើសន្តីរណកិច្ច និងចេតសិក ១១ ( វៀរវីរិយៈ ឆន្ទៈ ) ដោយអនន្តរប្បច្ច័យ ។

**សម្បដិ.២ ចេ.១០ ⟶ សន្តីរ.៣ ចេ.១១**

**" បណ្ឌិតគប្បីធ្វើឲ្យពិស្តារ នូវធម៌ដូច្នេះ ៤ គូ ទៀត មានសោតវិញ្ញាណធាតុជាដើម " ។**

**( ១១ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ កុសលានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

( លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ដែលកើតមុន ៗ ( វៀរកុសលជវនខណៈចុងក្រោយ ) ជាបច្ច័យនៃកុសលចិត្ត ២១ ដួង ចេតសិក ៣៨ ( វៀរកុសលជវនខណៈទីមួយ ) ។

**បច្ច័យ** = លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ( វៀរខណៈចុងក្រោយ ) ។

**បច្ចយុប្បន្ន** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ( វៀរខណៈ ទី ១ ) ។

**លោកិ.កុ.១៧ ចេ.៣៨ ⟶ កុ.២១ ចេ.៣៨**



**( ១២ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ជាបច្ច័យនៃកាមាវចរ-វិបាកចិត្ត ១១ ដួង ចេតសិក ៣៣ ធ្វើតទាលម្ពណកិច្ច ឬភវង្គកិច្ច ឬចុតិកិច្ច , មហគ្គតវិបាកចិត្ត ៩ ដួង ចេតសិក ៣៥ ធ្វើភវង្គកិច្ច និងចុតិកិច្ច , ផលចិត្ត ៤ ដួង ចេតសិក ៣៦ ក្នុងមគ្គវិថី ផល-សមាបត្តិវិថី និងនិរោធសមាបត្តិវិថី ។

**( ១៣ ) បុរិមា បុរិមា អកុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អកុសលានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

( អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ដែលកើតមុន ៗ ( វៀរកុសលជវនខណៈចុងក្រោយ ) ជាបច្ច័យនៃអកុសលចិត្ត ១២ ដួង ចេតសិក ២៧ ( វៀរ អកុសលជវនខណៈទីមួយ ) ដោយអនន្តរប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ( វៀរខណៈចុងក្រោយ ) ។

**បច្ចយុប្បន្ន** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧

( វៀរខណៈ ទី ១ )

**អកុ.១២ ចេ.២៧ ⟶ អកុ.១២ ចេ.២៧**

**( ១៤ ) បុរិមា បុរិមា អកុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ក្នុងខណៈជវនចុងក្រោយ ជាបច្ច័យដល់វិបាកចិត្ត ២០ ដួង គឺ កាមាវចរវិបាកចិត្ត ១១ ដួង ធ្វើតទាលម្ពណកិច្ចជាដើម និងមហគ្គតវិបាកចិត្ត ៩ ដួង ដែលធ្វើភវង្គកិច្ច ចេតសិក ៣៥ ។

លោភមូលចិត្ត ៨ ដួង និងមោហមូលចិត្ត ២ ដួង ជាបច្ច័យដល់តទាលម្ពណចិត្ត ១១ ភវង្គចិត្ត ១៩ ដួង ។ ទោសមូលចិត្ត ២ ដួង ជាបច្ច័យដល់តទាលម្ពណៈដែលប្រកបដោយឧបេក្ខា ៦ ដួង , ឧបេ-ក្ខាភវង្គ ៦ ដួង ផងដែរ ។

**អកុ.១២ ចេ.២៧ ⟶ អព្យា.២០ ចេ.៣៥**

**( ១៥ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ដែលកើតមុន ៗ ជាបច្ច័យដល់អព្យាកតធម៌ ដែល



កើតក្រោយ ៗ ដោយអនន្តរប្បច្ច័យ ។

វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ ដែលកើតមុន ៗ ( វៀរចុតិចិត្តរបស់ព្រះអរហន្ត ) ជាបច្ច័យដល់អព្យាកតចិត្ត ៥៦ ដួង និងចេតសិក ៣៨ រួមទាំងចុតិចិត្តរបស់ព្រះអហន្តផង ។

**អព្យា.៥៦ ចេ.៣៨ ⟶ អព្យា.៥៦ ចេ.៣៨**

( ១ ) បដិសន្ធិ ជាបច្ច័យដល់បឋមភវង្គ , ភវង្គខណៈទី ១ ជាដំបូងនេះ ជាបច្ច័យដល់ភវង្គទី ២ ( ទុតិយភវង្គ ) ជាបច្ច័យត ៗ រហូតដល់ភវង្គទី ១៥ ជាបច្ច័យដល់ភវង្គទី ១៦ ដោយអនន្តរប្បច្ច័យ ។

( ២ ) បញ្ចវោការភវង្គ ១៥ ( មហាវិ. ៨ អហេតុកវិ. ២ , មហគ្គតវិ.៥ ភវង្គក្នុងភពដែលមានខន្ធ ៥ ) ជាបច្ច័យដល់អាវជ្ជនៈទាំង ២ គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ , មនោទ្វារាវជ្ជនចិត្ត ១ ដោយអនន្ត-រប្បច្ច័យ ។

( ៣ ) អរូបភវង្គ ៤ ជាបច្ច័យដល់មនោទ្វារាវជ្ជនចិត្ត ១ ដោយអនន្តរប្បច្ច័យ ។

( ៤ ) បញ្ចទ្វារាវជ្ជនចិត្ត ១ ដួង ជាបច្ច័យដល់ទ្វិបញ្ចវិញ្ញាណ-

ចិត្ត ១០ ដួង ដោយអនន្តរប្បច្ច័យ ។

( ៥ ) ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង ជាបច្ច័យដល់សម្បដិច្ឆន្ន-ចិត្ត ២ ដួង ដោយអនន្តរប្បច្ច័យ ។

( ៦ ) សម្បដិច្ឆន្នចិត្ត ២ ដួង ជាបច្ច័យដល់សន្តីរណចិត្ត ៣ ដួង ដោយអនន្តរប្បច្ច័យ ។

( ៧ ) សន្តីរណចិត្ត ៣ ដួង ជាបច្ច័យដល់វោដ្ឋព្វនចិត្ត ១ ដួង បើជាវោដ្ឋព្វនវារៈ វោដ្ឋព្វនចិត្តទី ១ ជាបច្ច័យដល់វោដ្ឋព្វនចិត្តទី ២ វោដ្ឋព្វនចិត្តខណៈទី ២ ជាបច្ច័យដល់វេដ្ឋព្វនចិត្តខណៈទី ៣ រួចហើយធ្លាក់ចុះកាន់ភវង្គ ។

( ៨ ) វោដ្ឋព្វនចិត្ត ១ ដួង ជាបច្ច័យដល់កិរិយាជវន ៩ គឺ មហាកិរិយាចិត្ត ៨ ដួង និងហសិតុប្បាទចិត្ត ១ ដួង ក្នុងជវនខណៈទី ១ ដោយអនន្តរប្បច្ច័យ ។

( ៩ ) កាមកិរិយាជវន ៩ ដួង ដែលកើតមុន ៗ គឺ ខណៈទី ១ ដល់ខណៈ ទី ៦ ជាបច្ច័យដល់កាមកិរិយាជវន ៩ ដួងនេះ ក្នុងខណៈ ក្រោយ ៗ ។

( ១០ ) ហសិតុប្បាទចិត្ត ១ ដួង នេះ ក្នុងខណៈទី ៧ ជាបច្ច័យនៃសោមនស្សតទាលម្ពណចិត្ត ៥ ដួង បើជាជវនវារៈ ហសិតុ-



ប្បាទចិត្ត ជាបច្ច័យដល់ តិហេតុកបញ្ចវោការភវង្គ ៩ ( មហាវិបាក-ញាណសម្បយុត្តចិត្ត ៤ ដួង និងរូបាវចរ ៥ ដួង ។

( ១១ ) សោមនស្សមហាកិរិយាចិត្ត ៤ ដួង ក្នុងខណៈទី ៧ ជាបច្ច័យដល់ សោមនស្សតទាលម្ពណចិត្ត ៥ ដួង ឬតិហេតុកភវង្គ ១៣ ដួង ។

( ១២ ) ឧបេក្ខាមហាកិរិយាចិត្ត ៤ ដួង ក្នុងខណៈទី ៧ ជាបច្ច័យដល់ ឧបេក្ខាតទាលម្ពណចិត្ត ៦ ដួង ឬតិហេតុកភវង្គ ១៣ ដួង ( វៀរទុហេតុកភវង្គ ៤ ដួង និងអហេតុកភវង្គ ២ ) ។

( ១៣ ) មហាកិរិយាចិត្តគូ ទី ១ ក្នុងខណៈជាគោត្រភូ ឬវោទាន ជាបច្ច័យ ដល់សោមនស្សមហគ្គតកិរិយាចិត្ត ៤ ដួង និងសោម-នស្សអរហត្តផលចិត្ត ៤ ដួង ក្នុងផលសមាបត្តិវិថី ។

( ១៤ ) មហាកិរិយាចិត្តគូ ទី ៣ ក្នុងខណៈជាគោត្រភូ ឬវោទាន ជាបច្ច័យ ដល់ឧបេក្ខាមហគ្គតកិរិយាចិត្ត ៥ ដួង និងឧបេក្ខាអរហត្ត-ផលចិត្ត ១ ដួង ក្នុងផលសមាបត្តិវិថី ។

( ១៥ ) មហគ្គតកិរិយាចិត្ត៩ ដួង ដែលកើតមុន ៗ ជាបច្ច័យដល់មហគ្គតកិរិយាចិត្ត ៩ ដួង ដែលកើតក្រោយ ៗ នៅក្នុងឈាន-សមាបត្តិវិថី មានខណៈចិត្ត ច្រើន មិនកំណត់ចំនួន ។

( **១៦** ) រូបាវចរកិរិយាចិត្ត ៥ ដួង ក្នុងខណៈចុងក្រោយ ជាបច្ច័យដល់ តិហេតុកបញ្ចវោការភវង្គ ៩ ដួង ។

( **១៧** ) អាកាសានញ្ចាយតនកិរិយាជវន ខណៈចុងក្រោយ ជាបច្ច័យដល់តិហេតុកបញ្ចវោការភវង្គ ៩ ដួង និងអរូបភវង្គថ្នាក់ក្រោម ១ ដួង ។

( **១៨** ) វិញ្ញាណញ្ចាយតនកិរិយាជវន ខណៈចុងក្រោយ ជាបច្ច័យនៃតិហេតុកបញ្ចវោការភវង្គ ៩ ដួង និងអរូបភវង្គថ្នាក់ក្រោម ២ ដួង ។

( **១៩** ) អាកិញ្ចញ្ញាយតនកិរិយាជវន ខណៈចុងក្រោយ ជាបច្ច័យនៃតិហេតុកបញ្ចវោការភវង្គ ៩ ដួង និងអរូបភវង្គថ្នាក់ក្រោម ៣ ដួង ។

( **២០** ) នេវសញ្ញានាសញ្ញាយតនកិរិយាជវន ខណៈចុងក្រោយ ជាបច្ច័យនៃតិហេតុកភវង្គ ១៣ ដួង និងអរហត្តផលចិត្ត ១ ដួង ពេលព្រះអរហន្តចេញអំពីនិរោធសមាបត្តិ ។

( **២១** ) ផលចិត្ត ៤ ដួង ដួងណាមួយដែលកើតមុន ៗ ជាបច្ច័យដល់ផលចិត្ត ៤ ដួង នោះ ៗ ក្នុងខណៈក្រោយ ៗ ក្នុងមគ្គវិថីក្តី ក្នុងផលសមាបត្តិវិថីក្តី ( ក្នុងមគ្គវិថី ផលចិត្តមាន ២ ខណៈ ឬ ៣



ខណៈ , ក្នុងផលសមាបត្តិវិថី មានច្រើនខណៈ ) ។

( **២២** ) ផលចិត្ត ៤ ដួង ក្នុងខណៈចុងក្រោយ ជាបច្ច័យនៃតិហេតុកភវង្គ ១៣ ដួង ។

( **២៣** ) តទាលម្ពណចិត្ត ១១ ដួង ខណៈទី ១ ជាបច្ច័យនៃតទាលម្ពណចិត្ត ខណៈទី ២ ។

( **២៤** ) តទាលម្ពណចិត្ត ១១ ដួង ខណៈទី ២ ជាបច្ច័យនៃកាមភវង្គចិត្ត ១០ ដួង ។

( **២៥** ) តទាលម្ពណចិត្ត ១១ ដួង ខណៈទី ២ ជាបច្ច័យនៃ កាមចុតិចិត្ត ១០ ដួង ក្នុងមរណាសន្នវិថិ តទាលម្ពណវារៈ ។

( **២៦** ) មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ក្នុងខណៈទី ៥ ជាបច្ច័យនៃតិហេតុកចុតិចិត្ត ១៣ ដួង ក្នុងមរណាសន្នវិថិ ជវនវារៈ ។

( **២៧** ) ភវង្គចិត្ត ១៩ ដួង ជាបច្ច័យដល់ចុតិចិត្ត ១៩ ដួង ក្នុងមរណាសន្នវិថិ ជវនវារៈ ឬតទាលម្ពណវារៈ ។

( **២៨** ) ទុហេតុកចុតិចិត្ត ៤ ដួង ( មហាវិបាក.វិប្ប. ) និងអហេតុកចុតិចិត្ត ២ ដួង ជាបច្ច័យនៃកាមបដិសន្ធិចិត្ត ១០ ដួង ។

( **២៩** ) តិហេតុកកាមចុតិចិត្ត ៤ ដួង ជាបច្ច័យ នៃបដិសន្ធិចិត្ត ១៩ ដួង ។

( ៣០ ) រូបាវចរចុតិចិត្ត ៥ ដួង ជាបច្ច័យនៃបដិសន្ធិចិត្ត ១៧ ដួង ( វៀរ អហេតុកបដិសន្ធិចិត្ត ២ ដួង ) ។

( ៣១ ) អរូបចុតិចិត្តទី ១ ជាបច្ច័យនៃតិហេតុកកាមបដិសន្ធិចិត្ត ៤ ដួង និងអរូបបដិសន្ធិចិត្ត ៤ ដួង ។

( ៣២ ) អរូបចុតិចិត្ត ទី ២ ជាបច្ច័យនៃតិហេតុកកាមបដិសន្ធិចិត្ត ៤ ដួង និងអរូបបដិសន្ធិចិត្តជាន់លើ ៣ ដួង ។

( ៣៣ ) អរូបចុតិចិត្តទី ៣ ជាបច្ច័យនៃតិហេតុកកាមបដិសន្ធិចិត្ត ៤ ដួង និងអរូបបដិសន្ធិជាន់លើ ២ ដួង ។

( ៣៤ ) អរូបចុតិចិត្តទី ៤ ជាបច្ច័យនៃតិហេតុកកាមបដិសន្ធិចិត្ត ៤ ដួង និងនេវសញ្ញានាសញ្ញាយតនបដិសន្ធិចិត្ត ១ ដួង ។

**( ១៦ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ កុសលានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

វោដ្ឋព្វនៈក្នុងបញ្ចទ្វារវិថីនៈ ឬមនោទ្វារវិថីនៈ ជាអនន្តរប្បច្ច័យដល់មហាកុសលចិត្ត ៨ ដួង ជវនខណៈទី ១ ។

**វោដ្ឋ. មនោទ្វារ. ⟶ មហាកុ.៨ ជវនខណៈទី ១**



**( ១៧ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ អកុសលានំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

វោដ្ឋព្វនៈក្នុងបញ្ចទ្វារវិថីនៈ ឬមនោទ្វារវិថីនៈ ជាអនន្តរប្បច្ច័យដល់ អកុសលចិត្ត ១២ ដួង ជវនខណៈទី ១ ។

**វោដ្ឋ. មនោទ្វារ. ⟶ អកុ.១២ ជវនខណៈទី ១**

**( ១៨ ) យេសំ យេសំ ធម្មានំ អនន្តរា យេ យេ ធម្មា ឧប្បជ្ជន្តិ ចិត្តចេតសិកា ធម្មា តេ តេ ធម្មា តេសំ តេសំ ធម្មានំ អនន្តរប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ ( វៀរចុតិចិត្តព្រះអរហន្ត ) ។

**បច្ចយុប្បន្ន** = ចិត្ត ៨៩ ដួង ចេតសិក ៥២ រួមទាំងចុតិចិត្តព្រះអរហន្តផង ។

**បច្ចនិក** = រូបទាំង ៧ ពួក និព្វាន ។

**អនន្តរលក្ខណៈ** គឺ បច្ច័យ និងបច្ចយុប្បន្ន មានលក្ខណៈមិនមានរវាងចន្លោះ ។

**ដោយជាតិ** គឺ អនន្តរជាតិ ។

**ដោយកាល** គឺ អតីតកាល ។

**ដោយសត្តិ** គឺ ជាជនកសត្តិតែម្យ៉ាងប៉ុណ្ណោះ ។

**អនន្តរប្បច្ច័យ មាន ៧ បញ្ហាវារៈ**

១. កុ → កុ.　　២. កុ. → អព្យា.

៣. អកុ. → អកុ.　　៤. អកុ. → អព្យា.

៥.អព្យា. → អព្យា.　　៦.អព្យា. → កុ.

អព្យា. → អកុ.

## ៥. សមនន្តរប្បច្ច័យ

ដូចអនន្តរប្បច្ច័យគ្រប់យ៉ាង ផ្សេងតែព្យញ្ជនៈប៉ុណ្ណោះ ។

## ៦. សហជាតប្បច្ច័យ

**១. ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញំ សហជាតប្បច្ចយេន បច្ចយោ ។**

អរូបក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ទៅវិញទៅមក

ដោយសហជាតប្បច្ច័យ ។



ចិត្ត ៨៩ ដួង ចេតសិក ៥២ ⇄ ចិត្ត ៨៩ ដួង ចេតសិក ៥២

**២. ចត្តារោ មហាភូតា អញ្ញមញ្ញំ សហជាតប្បច្ចយេន បច្ចយោ ។**

មហាភូតរូប ៤ ជាបច្ច័យដល់គ្នានឹង ទៅវិញទៅមក

ដោយសហជាតប្បច្ច័យ ។

+ មហាភូតរូប ៤ នេះ គឺ ប្រព្រឹត្តទៅជារូបទាំងអស់ បានដល់ ចិត្តជមហាភូតរូប , បដិសន្ធិកម្មជមហាភូតរូប , ពាហិរមហាភូតរូប ( មហាភូតរូបក្រៅ ពីមនុស្ស.សត្វទាំងអស់ ) , អាហារជមហាភូតរូប , ឧតុជមហាភូតរូប , អសញ្ញសត្តមហាភូតរូប និងបវត្តិកម្មជមហា-ភូតរូប ។

**៣. ឱក្កន្តិក្ខណេ នាមរូបំ អញ្ញមញ្ញំ សហជាតប្បច្ចយេន បច្ចយោ ។**

ក្នុងខណៈបដិសន្ធិ នាមធម៌ បានដល់ បញ្ចវោការបដិសន្ធិ-ចិត្ត ១៥ ដួង ចេតសិក ៣៥ និងរូបធម៌ បានដល់ ហទយវត្ថុ-បដិសន្ធិកម្មជរូប ជាបច្ច័យដល់គ្នានឹងគ្នា ទៅវិញទៅមក ដោយសហ-ជាតប្បច្ច័យ ។

**បញ្ច.បដិ.១៥ ចេ.៣៥ ហទយកម្ម. ⇄ បញ្ច.បដិ.១៥ ចេ.៣៥ ហទយកម្ម.**

**៤. ចិត្តចេតសិកា ធម្មា ចិត្តសមុដ្ឋានានំ រូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

ធម៌ទាំងឡាយ គឺ ចិត្ត ៧៥ ដួង ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង អរូបវិបាកចិត្ត ៤ ដួង និងចុតិចិត្តរបស់ព្រះអរហន្ត ) ចេតសិក ៥២ ក្នុងបវត្តិកាល ជាបច្ច័យដល់ចិត្តសមុដ្ឋានរូប ១៧ ដោយសហ-ជាតប្បច្ច័យ ។

**ចិត្ត.៧៥ ចេ.៥២ ⟶ ចិត្ត.សមុ.១៧**

**៥. មហាភូតា ឧបាទារូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

មហាភូតរូប គ្រប់រូបទាំងអស់ បានដល់ មហាភូតរូប ៤ ជាសហជាតប្បច្ច័យ ដល់ឧបាទាយរូប ២៤ ។

**មហាភូតរូប ៤ ⟶ ឧបាទាយរូប ២៤**

**៦. រូបិនោ ធម្មា អរូបិនំ ធម្មានំ កិញ្ចិ កាលំ សហជាតប្បច្ចយេន បច្ចយោ កិញ្ចិ កាលំ ន សហជាតប្បច្ចយេន បច្ចយោ ។**

រូបធម៌ទាំងឡាយ បានដល់ បដិសន្ធិកម្មជហទយវត្ថុរូប ជា



សហជាតប្បច្ច័យ ដល់បញ្ចវោការបដិសន្ធិចិត្ត ១៥ ដួង ចេតសិក ៣៥ ក្នុងបដិសន្ធិកាល មិនជាសហជាតប្បច្ច័យក្នុងបវត្តិកាលឡើយ ។

បដិ.កម្ម.១ ⟶ បញ្ច.១៥ ចេ.៣៥

**សរុបបច្ច័យ និង បច្ចយុប្បន្ន**

**បច្ច័យ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ មហាភូត-រូប ៤ ហទយវត្ថុបដិសន្ធិកម្មជរូប ។

**បច្ចយុប្បន្ន** = ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

**បច្ចនិក** = មិនមាន ( និព្វាន និងបញ្ញត្តិ មិនមែនជាបច្ចយុប្បន្នធម៌ របស់បច្ច័យ ២៤ ដូច្នេះទើបមិនចាំបាច់ពោលថា ជាបច្ចនិកៈក្នុងបច្ច័យណាមួយឡើយ ម្យ៉ាងទៀតមិនមែនជាធម៌ដែលមានការកើតឡើង និងរលត់ទៅ ដូចជាសង្ខតធម៌ដទៃ ៗ ដូច្នេះទើបមិនចាំបាច់ពោលទុកក្នុងបច្ចនិកៈ)។

**សហជាតប្បច្ច័យ** មានលក្ខណៈ គឺ សហជាតិលក្ខណៈ គឺ បច្ច័យ និងបច្ចយុប្បន្នៈ កើតព្រមគ្នាជាលក្ខណៈ ។

- មានសហជាត ជាតិ ។

- ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាល ។
- ដោយសត្តិទាំងពីរ ។

## បញ្ហាវារៈមាន ៩

## បញ្ហាវារៈទី ១

**កុសលោ ធម្មោ កុសលស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។**

**( ១ ) កុសលា ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។**

កុសលនាមក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ ដោយសហជាតប្បច្ច័យ ។

**( ២ ) តយោ ខន្ធា ឯកស្ស ខន្ធស្ស សហជាតប្បច្ចយេន បច្ចយោ ។**

ខន្ធ ៣ ជាបច្ច័យដល់ខន្ធ ១ ដោយសហជាតប្បច្ច័យ ។

**( ៣ ) ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។**

ខន្ធ ២ ជាបច្ច័យដល់ខន្ធ ២ ដោយសហជាតប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។



**បច្ចយុប្បន្ន** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

## បញ្ហាវារៈទី ២

**កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។**

កុសលធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ ។

**កុសលា ខន្ធា ចិត្តសមុដ្ឋានានំ រូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

កុសលនាមក្ខន្ធទាំង ៤ ជាបច្ច័យនៃចិត្តសមុដ្ឋានរូប ១៧ ដោយសហជាតប្បច្ច័យ ។

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

**បច្ចយុប្បន្ន** = ចិត្តជរូប ១៧ ។

## បញ្ហាវារៈទី ៣

**កុសលោ ធម្មោ កុសលស្ស ច អព្យាកតស្ស ច សហជាតប្បច្ចយេន បច្ចយោ ។**

កុសលធម៌ជាបច្ច័យនៃកុសលធម៌ផង អព្យាកតធម៌ផង ដោយ សហជាតប្បច្ច័យ ។

( ១ ) កុសលោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( ២ ) តយោ ខន្ធា ឯកស្ស ខន្ធស្ស ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( ៣ ) ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

បច្ច័យ = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

បច្ចយុប្បន្ន = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ និងចិត្តជរូប ១៧ ។

## បញ្ហាវារៈទី ៤

អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។



អកុ. ១២ ចេ.២៧ ⟶ អកុ.១២ ចេ.២៧

## បញ្ហាវារៈទី ៥

អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។

អកុ.១២ ចេ.២៧ ⟶ ចិត្តជ.១៧

## បញ្ហាវារៈទី ៦

អកុសលោ ធម្មោ អកុសលស្ស ច អព្យាកតស្ស ច ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។

អកុ.១២ ចេ.២៧ ⟶ អកុ.១២ ចេ.២៧ ចិត្តជ.១៧

## បញ្ហាវារៈទី ៧

អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។

បច្ច័យ = វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ មហាភូតរូប ៤ បដិសន្ធិហទយវត្ថុរូប ១ ។

បច្ចយុប្បន្ន = អព្យាកតចិត្ត ៥៦ ចេតសិក ៣៨ រូប ២៨ ។

១- ( ក ) វិបាកាព្យាកតោ កិរិយាព្យាកតោ ឯកោ ខន្ធោ តិណ្ណំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( ខ ) តយោ ខន្ធា ឯកស្ស ខន្ធស្ស ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( គ ) ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ ចិត្តសមុដ្ឋានានញ្ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

បច្ច័យ = វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ ។

បច្ចយុប្បន្ន = វិបាកចិត្ត ៣៦ កិរិយាចិត្ត ២០ ចេតសិក ៣៨ ចិត្តជរូប ១៧ ។

ដោយកាល ភូមិ បុគ្គល ទ្វារ វិថី

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល និងចុតិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងចតុវោការភូមិ និងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផលបុគ្គល ៤ ពួក ។



ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ មនោទ្វារ និងទ្វារវិមុត្តិ ( វៀរ បដិសន្ធិ ) ។

ដោយវិថី : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវិថិ កាមមនោទ្វារវិថិ មរណាសន្នជវនវិថិ ឈានវិថិ មហគ្គតកិរិយាវិថិ អភិញ្ញាវិថិ មគ្គវិថិ ផលសមាបត្តិវិថិ និងនិរោធសមាបត្តិវិថិ ( មុនចូលនិរោធសមាបត្តិ និងផលចិត្ត ២ ខាងលើ ពេលចេញពីនិរោធ ) ។

២- ( ក ) បដិសន្ធិក្ខណេ វិបាកាព្យាកតោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ កដត្តា ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( ខ ) តយោ ខន្ធា ឯកស្ស ខន្ធស្ស កដត្តា ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

( គ ) ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ កដត្តា ច រូបានំ សហជាតប្បច្ចយេន បច្ចយោ ។

ក្នុងខណៈបដិសន្ធិ វិបាកក្ខន្ធ ១ ជាបច្ច័យនៃខន្ធ ៣ និងកម្មជរូប

ដោយ សហជាតប្បច្ច័យ ខន្ធ ៣ ជាបច្ច័យនៃខន្ធ ១ និងកម្មជរូប ដោយសហជាតប្បច្ច័យ ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ និងកម្មជរូប ។

**បច្ច័យ** = បញ្ចវោការបដិសន្ធិចិត្ត ១៥ ដួង ចេតសិក ៣៥ ( អរូបវិបាក ៤ ក្នុងខណៈបដិសន្ធិ នាមក្ខន្ធ ៤ ក៏ជាសហជាតប្បច្ច័យដល់គ្នាទៅវិញទៅមកដែរ គ្រាន់តែបច្ចយុប្បន្នៈមិនមានកម្មជរូបប៉ុណ្ណោះ ) ។

**បច្ចយុប្បន្ន** = បញ្ចវោការបដិសន្ធិចិត្ត ១៥ ដួង ចេតសិក ៣៥ ( អរូបបដិសន្ធិ តាមសមគួរ ) និងបដិសន្ធិកម្មជរូប ២០ ។

**ដោយកាល ភូមិ បុគ្គល ទ្វារ វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ( ចតុវោការភូមិ តាមសមគួរ ) ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផលបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅជាទ្វារវិមុត្តិ ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងវីថិមុត្តចិត្ត ។



**( ៣ ) ខន្ធា វត្ថុស្ស សហជាតប្បច្ចយេន បច្ចយោ វត្ថុ ខន្ធានំ សហជាតប្បច្ចយេន បច្ចយោ ។**

វិបាកនាមក្ខន្ធ ៤ ក្នុងខណៈបដិសន្ធិ ( ក្នុងឧប្បាទខណៈ ) ជាបច្ច័យនៃហទយវត្ថុរូប , ហទយវត្ថុរូប ជាបច្ច័យនៃវិបាកនាមក្ខន្ធ ៤ ខណៈបដិសន្ធិ ( ទាំងវិបាកបដិសន្ធិ ទាំងវត្ថុរូប ជាសហជាតប្បច្ច័យក្នុងឧប្បាទខណៈតែប៉ុណ្ណោះ ខណៈចិត្តដទៃ ៗ ទៀត ក៏ដូចគ្នា ) ។

**ដោយកាល ភូមិ បុគ្គល ទ្វារ វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល ( ឧប្បាទខណៈ ) ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ តែម្យ៉ាង ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផលបុគ្គល ៣ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅជាទ្វារវិមុត្តិ ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងវីថិមុត្តចិត្ត ។

**( ៤ ) ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ តយោ មហាភូតា ឯកស្ស មហាភូតស្ស សហជាតប្បច្ចយេន បច្ចយោ ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ សហជាតប្បច្ចយេន**

បច្ចយោ ។

**បច្ច័យ** = មហាភូតរូប ៤ ( ១ , ៣ , ២ ) ដែលជាចិត្តសមុដ្ឋានរូប និងបដិសន្ធិកម្មជរូប និងបវត្តិកម្មជរូប ។

**បច្ចយុប្បន្ន** = មហាភូតរូប ៤ ( ៣ , ១ , ២ ) មានសមុដ្ឋាន និងកាល ដូចបច្ច័យដែរ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល និងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផលបុគ្គល ៤ ពួក ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅជារូបវីថិ ។

( ៥ ) **មហាភូតា សមុដ្ឋានានំ រូបានំ កដត្តារូបានំ ឧបាទារូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** = មហាភូតរូប ៤ ដែលមានចិត្តជាសមុដ្ឋាន និងមានកម្មជាសមុដ្ឋាន ( កម្មជមហាភូតរូប ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ) ។



**បច្ចយុប្បន្ន** = ចិត្តជឧបាទាយរូប ១៣ កម្មជឧបាទាយរូប ១៦ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល និងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផលបុគ្គល ៤ ពួក ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅជារូបវីថិ ។

( ៦ ) **ពាហិរំ ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ សហ-ជាតប្បច្ចយេន បច្ចយោ តយោ មហាភូតា ឯកស្ស មហាភូតស្ស សហជាតប្បច្ចយេន បច្ចយោ ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ មហាភូតា ឧបាទារូបានំ សហជាត-ប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** = មហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ជាពាហិររូប បានដល់អវិញ្ញាណកវត្ថុទាំងឡាយ មានដើមឈើ ផែនដី ជាដើម ។

**បច្ចយុប្បន្ន** = មហាភូតរូប ៤ ( ៣ , ១ , ២ ) ពាហិរឧបាទាយរូប ៦ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ មិនប្រព្រឹត្តទៅក្នុងកាលទាំង ៣ ( គឺ បដិសន្ធិកាល បវត្តិកាល និងចុតិកាល ) ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្រៅបុគ្គលទាំង ៨ ពួក ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅជារូបវីថិខាងក្រៅ ។

( ៧ ) **អាហារសមុដ្ឋានំ ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ តយោ មហាភូតា ឯកស្ស មហាភូតស្ស សហជាតប្បច្ចយេន បច្ចយោ ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ មហាភូតា ឧបាទារូបានំ សហជាតប្បច្ចយេន បច្ចយោ ។**



**បច្ច័យ** = អាហារសមុដ្ឋានមហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ។

**បច្ចយុប្បន្ន** = មហាភូតរូប ៤ ( ៣ , ១ , ២ ) អាហារសមុដ្ឋានឧបាទាយរូប ១០ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងកាមភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុគ្គលទាំង ៨ ពួក ។

ដោយវីថិ : គឺ ជារូបវីថិ ។

( ៨ ) **ឧតុសមុដ្ឋានំ ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ តយោ មហាភូតា ឯកស្ស មហាភូតស្ស សហជាតប្បច្ចយេន បច្ចយោ ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ មហាភូតា ឧបាទារូបានំ សហជាតប្បច្ចយេន បច្ចយោ ។**

**បច្ច័យ** = ឧតុសមុដ្ឋានមហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ។

បច្ចយុប្បន្ន = ឧតុសមុដ្ឋានមហាភូតរូប ៤ ( ៣ , ១ , ២ ) និង ឧបាទាយរូប ១១ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ និងឯកវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុគ្គលទាំង ៨ ពួក ។

ដោយវីថិ : គឺ ជារូបវីថិ ។

( ៩ ) អសញ្ញសត្តានំ ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ តយោ មហាភូតា ឯកស្ស មហាភូតស្ស សហជាតប្បច្ចយេន បច្ចយោ ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ សហជាតប្បច្ចយេន បច្ចយោ មហាភូតា កដត្តារូបានំ ឧបាទារូបានំ សហជាតប្បច្ចយេន បច្ចយោ ។

បច្ច័យ = អសញ្ញសត្តមហាភូតរូប ៤ ( ១ , ៣ , ២ ) បានដល់ អសញ្ញសត្តកម្មជរូប ។

បច្ចយុប្បន្ន = អសញ្ញសត្តកម្មជមហាភូតរូប ៤ ( ៣ ,



១ , ២ ) និង ឧបាទាយរូប ៦ ( អសញ្ញសត្តកម្មជរូប មានជីវិតនវកៈ និងបរិច្ឆេទរូប ) ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបដិសន្ធិកាល និងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងឯកវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងអសញ្ញសត្តាព្រហ្ម ។

ដោយវីថិ : គឺ ជារូបវីថិ ។

## បញ្ហាវារៈទី ៨

**កុសលោ ច អព្យាកតោ ច ធម្មា អព្យាកតស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ។**

កុសលធម៌ផង អព្យាកតធម៌ផង ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ

កុ. + អព្យា. ⟶ អព្យា.

**បច្ច័យ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ និង មហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ។

**បច្ចយុប្បន្ន** = ចិត្តជរូប ១៧ ដែលមានកុសលចិត្ត ជាសមុដ្ឋាន បានដល់ មហាភូតរូប ៤ ( ៣ , ១ , ២ ) និងឧបា-ទាយរូប ១៣ ។

**កុសលា ខន្ធា ច មហាភូតា ច ចិត្តសមុដ្ឋានានំ រូបានំ**
**សហជាតប្បច្ចយេន បច្ចយោ ។**

កុសលនាមក្ខន្ធ ៤ និងកុសលចិត្តជមហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ជាបច្ច័យនៃចិត្តជមហាភូតរូប ( ៣ , ២ , ១ ) និងកុសលចិត្តជឧបាទាយរូប ១៣ ដោយសហជាតប្បច្ច័យ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងព្រះ-អរិយបុគ្គល ៧ ពួក ( វៀរព្រះអរហន្ត ) ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវីថិ កាមជវនមនោ-



ទ្វារវីថិ ឈានវីថិ អភិញ្ញាវីថិ មគ្គវីថិ ។

## បញ្ហាវារៈទី ៩

**អកុសលោ ច អព្យាកតោ ច ធម្មា អព្យាកតស្ស ធម្មស្ស**
**សហជាតប្បច្ចយេន បច្ចយោ ។**

អកុសលធម៌ផង អព្យាកតធម៌ផង ជាបច្ច័យនៃអព្យាកតធម៌ ដោយសហជាតប្បច្ច័យ ។

**អកុសលា ខន្ធា ច មហាភូតា ច ចិត្តសមុដ្ឋានានំ រូបានំ**
**សហជាតប្បច្ចយេន បច្ចយោ ។**

អកុសលនាមក្ខន្ធ ៤ និងអកុសលចិត្តជមហាភូតរូប ៤ ( ១ , ៣ , ២ ឬ ៤ ) ជាបច្ច័យនៃចិត្តជមហាភូតរូប ( ៣ , ១ , ២ ) និងអកុសលចិត្តជឧបាទាយរូប ១៣ ដោយសហជាតប្បច្ច័យ ។

**បច្ច័យ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ និងមហាភូតរូប ៤ ។

**បច្ចយុប្បន្ន** = អកុសលចិត្តជរូប ១៧ ។

**ដោយកាល ភូមិ បុគ្គល វីថិ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក និងផល-
បុគ្គល ៣ ពួក។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវីថិ កាមជវនមនោ-
ទ្វារវីថិ និងរូបវីថិ ។

---

## ៧.អញ្ញមញ្ញប្បច្ច័យ

១. ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

ចិត្ត ៨៩ ចេតសិក ៥២ ⇄ ចិត្ត ៨៩ ចេតសិក ៥២

២. ចត្តារោ មហាភូតា អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

មហាភូតរូប ៤ ⇄ មហាភូតរូប ៤



៣. ឱកន្តិក្ខណេ នាមរូបំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥ ⇄ បដិសន្ធិហទយវត្ថុរូប

### សរុបអង្គធម៌

**បច្ច័យ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ មហាភូតរូប ៤
បដិសន្ធិហទយវត្ថុរូប ១ ។

**បច្ចយុប្បន្ន** = ចិត្ត ៨៩ ដួង ចេតសិក ៥២ មហាភូតរូប ៤
បដិសន្ធិហទយវត្ថុរូប ១ ។

**បច្ចនិក** = ឧបាទាយរូប ២៤ ( វៀរបដិសន្ធិហទយវត្ថុរូប )។

**ដោយលក្ខណៈ ជាតិ កាល សត្តិ**

ដោយលក្ខណៈ : ជាឧបការៈដល់គ្នានឹងគ្នា ទៅវិញទៅ
មក ( អញ្ញមញ្ញលក្ខណៈ ) ។

ដោយជាតិ : ជាសហជាត ជាតិ ។

ដោយកាល : គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ : គឺ ជនកសត្តិ និងឧបត្ថម្ភកសត្តិ ។

មាន ៣ បញ្ហាវារៈ

## បញ្ហាវារៈទី ១

**កុសលោ ធម្មោ កុសលស្ស ធម្មស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

កុសលចិត្ត ២១ ចេតសិក ៣៨

⇄

កុសលចិត្ត ២១ ចេតសិក ៣៨

**កុសលោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ។**

**តយោ ខន្ធា ឯកស្ស ខន្ធស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

**ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

កុសលនាមក្ខន្ធ ១ ជាបច្ច័យនៃកុសលនាមក្ខន្ធ ៣ , កុសល-នាមក្ខន្ធ ៣ ជាបច្ច័យនៃកុសលនាមក្ខន្ធ ១ , កុសលនាមក្ខន្ធ ២ ជាបច្ច័យនៃកុសលនាមក្ខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

## បញ្ហាវារៈទី ២

**អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**



អកុសលធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយអញ្ញមញ្ញប្បច្ច័យ ។

**អកុសលចិត្ត ១២ ចេតសិក ២៧**

⇄

**អកុសលចិត្ត ១២ ចេតសិក ២៧**

**អកុសលោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

**តយោ ខន្ធា ឯកស្ស ខន្ធស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

**ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។**

អកុសលនាមក្ខន្ធ ១ ជាបច្ច័យនៃអកុសលនាមក្ខន្ធ ៣ , អកុ-សលនាមក្ខន្ធ ៣ ជាបច្ច័យនៃអកុសលនាមក្ខន្ធ ១ , អកុសលនាម-ក្ខន្ធ ២ ជាបច្ច័យនៃអកុសលនាមក្ខន្ធ ២ ដោយអញ្ញមញ្ញប្បច្ច័យ ។

## បញ្ហាវារៈទី ៣

**អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ**

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយអញ្ញមញ្ញប្បច្ច័យ ។

វិ.៣៦ កិ.២០ ចេ.៣៨ មហាភូ.៤ បដិ.ហទយ.១

⇄

វិ.៣៦ កិ.២០ ចេ.៣៨ មហាភូ.៤ បដិ.ហទយ.១

១. វិបាកាព្យាកតោ កិរិយាព្យាកតោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

តយោ ខន្ធា ឯកស្ស ខន្ធស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

( មិនមានចិត្តសមុដ្ឋានរូប ដូចសហជាតប្បច្ច័យទេ ) ។

វិបាក កិរិយានាមក្ខន្ធ ១ ជាបច្ច័យនៃវិបាក កិរិយានាមក្ខន្ធ ៣ , វិបាក កិរិយានាមក្ខន្ធ ៣ ជាបច្ច័យនៃវិបាក កិរិយានាមក្ខន្ធ ១ , វិបាក កិរិយានាមក្ខន្ធ ២ ជាបច្ច័យនៃវិបាក កិរិយានាមក្ខន្ធ ២ ដោយ អញ្ញមញ្ញប្បច្ច័យ ។

អព្យាកតចិត្ត ៥៦ ចេតសិក ៣៨

⇄

អព្យាកតចិត្ត ៥៦ ចេតសិក ៣៨



២. បដិសន្ធិក្ខណេ វិបាកាព្យាកតោ ឯកោ ខន្ធោ តិណ្ណន្នំ ខន្ធានំ វត្ថុស្ស ច អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។ តយោ ខន្ធា ឯកស្ស ខន្ធស្ស វត្ថុស្ស ច អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។ ទ្វេ ខន្ធា ទ្វិន្នំ ខន្ធានំ វត្ថុស្ស ច អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

ក្នុងខណៈបដិសន្ធិ វិបាកនាមក្ខន្ធ ១ ជាបច្ច័យនៃនាមក្ខន្ធ ៣ និងបដិសន្ធិហទយវត្ថុរូប , វិបាកនាមក្ខន្ធ ៣ ជាបច្ច័យនៃវិបាកនាមក្ខន្ធ ១ និងបដិសន្ធិហទយវត្ថុរូប , វិបាកនាមក្ខន្ធ ២ ជាបច្ច័យនៃវិបាក-នាមក្ខន្ធ ២ និងបដិសន្ធិហទយវត្ថុរូប ដោយអញ្ញមញ្ញប្បច្ច័យ ។

បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥

⇄

បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥ បដិសន្ធិហទយវត្ថុ ១

២. ខន្ធា វត្ថុស្ស អញ្ញមញ្ញប្បច្ចយេន បច្ចយោ វត្ថុ ខន្ធានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ ។

បញ្ចវោការបដិសន្ធិចិត្ត ១៥ ចេតសិក ៣៥

⇄

បដិសន្ធិហទយវត្ថុ ( ខណៈបដិសន្ធិ )

៤. ឯកំ មហាភូតំ តិណ្ណន្នំ មហាភូតានំ អញ្ញមញ្ញប្បច្ចយេន បច្ចយោ , តយោ មហាភូតា ឯកស្ស មហាភូតស្ស អញ្ញមញ្ញ-ប្បច្ចយេន បច្ចយោ , ទ្វេ មហាភូតា ទ្វិន្នំ មហាភូតានំ អញ្ញមញ្ញ-ប្បច្ចយេន បច្ចយោ ។

*មហាភូតរូប ១ ជាបច្ច័យនៃមហាភូតរូប ៣ , មហាភូតរូប ៣ ជាបច្ច័យនៃ មហាភូតរូប ១ , មហាភូតរូប ២ ជាបច្ច័យនៃមហាភូតរូប ២ , ដោយអញ្ញមញ្ញប្បច្ច័យ ។*

៥. ពាហិរំ ឯកំ មហាភូតំ ។ល។ ( *មិនមាន* មហាភូតា ឧបាទារូបានំ *ទេ* )

៦. អាហារសមុដ្ឋានានំ ។ល។

៧. ឧតុសមុដ្ឋានានំ ។ល។

៨. អសញ្ញសត្តានំ ។ល។



## ៨.និស្សយប្បច្ច័យ

១. ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញំ និស្សយប្បច្ចយេន បច្ចយោ ។

*នាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយនិស្សយប្បច្ច័យ ។*

ចិត្ត.៨៩ ចេ.៥២ ⇄ ចិត្ត.៨៩ ចេ.៥២

២. ចត្តារោ មហាភូតា អញ្ញមញ្ញំ និស្សយប្បច្ចយេន បច្ចយោ ។

*មហាភូតរូប ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយនិស្សយប្បច្ច័យ ។*

មហាភូត ៤ ⇄ មហាភូត ៤

៣. ឱក្កន្តិក្ខណេ នាមរូបំ អញ្ញមញ្ញំ និស្សយប្បច្ចយេន បច្ចយោ ។

*ក្នុងខណៈបញ្ចវោការបដិសន្ធិ នាម និងហទយរូប ជាបច្ច័យដល់គ្នានឹងគ្នា ដោយនិស្សយប្បច្ច័យ ។*

បញ្ចវោការបដិ.១៥ ចេ.៣៥ ⇄ បដិ.ហទយ.១

៤. ចិត្តចេតសិកា ធម្មា ចិត្តសមុដ្ឋានានំ រូបានំ និស្សយប្បច្ចយេន បច្ចយោ ។

ចិត្ត និងចេតសិកធម៌ទាំងឡាយ ជាបច្ច័យដល់រូបទាំងឡាយ ដែល
មានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ ។

**ចិត្ត.៧៥ ចេ.៥២ ⇄ ចិត្តជ.១៧**

**៥. មហាភូតា ឧបាទារូបានំ និស្សយប្បច្ចយេន បច្ចយោ ។**

មហាភូតរូប ៤ ជាបច្ច័យដល់ឧបាទាយរូប ដោយនិស្សយប្បច្ច័យ ។

**មហាភូត.៤ ⇄ ឧបាទាយ.២៤**

**+ ( តាំងពីប្រការទី ១ ដល់ ប្រការទី ៥ ដូចសហជាតប្បច្ច័យ )**

**៦. ចក្ខាយតនំ ចក្ខុវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ**
**និស្សយប្បច្ចយេន បច្ចយោ ។**

ចក្ខាយតនៈ ជាបច្ច័យនៃចក្ខុវិញ្ញាណធាតុ និងធម៌ទាំងឡាយ
ដែលប្រកបជាមួយ ដោយនិស្សយប្បច្ច័យ ។

**ចក្ខុបសាទ ⟶ ចក្ខុវិ.២ ចេ.៧**

**៧. សោតាយតនំ សោតវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ**
**និស្សយប្បច្ចយេន បច្ចយោ ។**



សោតាយតនៈ ជាបច្ច័យនៃសោតវិញ្ញាណធាតុ និងធម៌ទាំងឡាយ
ដែលប្រកបជាមួយ ដោយនិស្សយប្បច្ច័យ ។

**សោតបសាទ ⟶ សោតវិ.២ ចេ.៧**

**៨. ឃានាយតនំ ឃានវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ**
**និស្សយប្បច្ចយេន បច្ចយោ ។**

ឃានាយតនៈ ជាបច្ច័យនៃឃានវិញ្ញាណធាតុ និងធម៌ទាំងឡាយ
ដែលប្រកបជាមួយ ដោយនិស្សយប្បច្ច័យ ។

**ឃានបសាទ ⟶ ឃានវិ.២ ចេ.៧**

**៩. ជិវ្ហាយតនំ ជិវ្ហាវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ**
**និស្សយប្បច្ចយេន បច្ចយោ ។**

ជិវ្ហាយតនៈ ជាបច្ច័យនៃជិវ្ហាវិញ្ញាណធាតុ និងធម៌ទាំងឡាយដែលប្រកប
ជាមួយ ដោយនិស្សយប្បច្ច័យ ។

**ជិវ្ហាបសាទ ⟶ ជិវ្ហាវិ.២ ចេ.៧**

**១០. កាយាយតនំ កាយវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ និស្សយប្បច្ចយេន បច្ចយោ ។**

កាយាយតនៈ ជាបច្ច័យនៃកាយវិញ្ញាណធាតុ និងធម៌ទាំងឡាយ ដែលប្រកបជាមួយ ដោយនិស្សយប្បច្ច័យ ។

**កាយបសាទ ———→ កាយវិ.២ ចេ.៧**

( ប្រការទី ៦ ដល់ប្រការទី ១០ វត្ថុរូប ៥ ———→ ទ្វិបញ្ចវិ.១០ ចេ.៧ )

**១១ យំ រូបំ និស្សាយ មនោធាតុ ច មនោវិញ្ញាណធាតុ ច វត្តន្តិ តំ រូបំ មនោធាតុយា ច មនោវិញ្ញាណធាតុយា ច តំសម្បយុត្តកានញ្ច ធម្មានំ និស្សយប្បច្ចយេន បច្ចយោ ។**

មនោធាតុក្តី និងមនោវិញ្ញាណធាតុក្តី អាស្រ័យរូបណាប្រព្រឹត្តទៅ រូបនោះ រមែងជាបច្ច័យដល់មនោធាតុផង មនោវិញ្ញាណធាតុផង និងដល់ធម៌ទាំងឡាយដែលប្រកបជាមួយផង ដោយនិស្សយប្បច្ច័យ ។

**បច្ច័យ** = ហទយវត្ថុរូប ក្នុងបិតិខណៈ បវត្តិកាល ។

**បច្ចយុប្បន្ន** = មនោធាតុ ៣ ដួង , មនោវិញ្ញាណធាតុ ៧២ ដួង ( វៀរអរូបវិបាក ៤ ដួង ) ចេតសិក ៥២ ។

ហទយរូប ———→ មនោធាតុ ៣ , មនោវិញ្ញាណធាតុ ៧២ ( ចិត្ត ៧៥ ) ចេតសិក ៥២ ។



\+ ( ប្រការទី ៦ ដល់ប្រការទី ១១ ជាវត្ថុបុរេជាតនិស្សយបច្ច័យ )

**ចែកជា ៣ បច្ច័យ**

**១ សហជាតនិស្សយប្បច្ច័យ ។**

**២ វត្ថុបុរេជាតនិស្សយប្បច្ច័យ ។**

**៣ វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ ។**

**១. សហជាតនិស្សយប្បច្ច័យ**

**បច្ច័យ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ មហាភូតរូប ៤ បដិសន្ធិហទយវត្ថុរូប ។

**បច្ចយុប្បន្ន** = ចិត្ត ៨៩ ចេតសិក ៥២ រូប ២៨ ។

**បច្ចនិក** = មិនមាន ។

**( អង្គធម៌ទាំងអស់ ដូចជាសហជាតប្បច្ច័យដែរ )**

**ដោយលក្ខណៈ ជាតិ កាល សត្តិ**

ដោយលក្ខណៈ : មានលក្ខណៈ ២ គឺ សហជាត-

លក្ខណៈ បច្ច័យ និងបច្ចយុប្បន្នៈ កើតព្រមគ្នា ជាលក្ខណៈ ១ , និស្សយលក្ខណៈ គឺ បច្ច័យ ជាទីអាស្រ័យនៃបច្ចយុប្បន្នៈ ជាលក្ខណៈ ១ ។

ដោយជាតិ : គឺ សហជាត ជាតិ ។

ដោយកាល : គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ : គឺ សត្តិទាំងពីរ ។

## ២. វត្ថុបុរេជាតនិស្សយប្បច្ច័យ

**បច្ច័យ** = វត្ថុរូប ៦ ក្នុងឋិតិខណៈនៃរូប ។

**បច្ចយុប្បន្ន** = វិញ្ញាណធាតុ ៧ បានដល់ ចិត្ត ៨៥ ដួង ( វៀររូបវិបាក ៤ ) ចេតសិក ៥២ ( មនោ-វិញ្ញាណធាតុណា ដែលអាចកើតក្នុងអរូបព្រហ្ម បាន មនោវិញ្ញាណធាតុនោះ ជាអនេកន្តៈ ។

**បច្ចនិក** = អរូបវិបាកចិត្ត ៤ ដួង ចេតសិក ៣០ និងរូបទាំងអស់ ។



### ចំពោះបច្ចយុប្បន្នធម៌ មានឯកន្តៈ មានអនេកន្តៈ

**ឯកន្តៈ** = ទោសមូលចិត្ត ២ ដួង អហេតុកចិត្ត ១៧ ដួង ( វៀរមនោទ្វារាវជ្ជនៈ ) មហាវិបាកចិត្ត ៨ ដួង រូបាវចរចិត្ត ១៥ ដួង សោតាបត្តិមគ្គចិត្ត ១ ដួង សរុបត្រូវជា **ចិត្ត ៤៣ ដួង ចេតសិក ៤៨** ( វៀរ លោភៈ ទិដ្ឋិ មានះ វិចិកិច្ឆា ) ។

**អនេកន្តៈ** = លោភមូលចិត្ត ៨ ដួង មោហមូលចិត្ត ២ ដួង មនោទ្វារាវជ្ជនចិត្ត ១ ដួង មហាកុសលចិត្ត ៨ ដួង មហាកិរិយាចិត្ត ៨ ដួង អរូបាវចរចិត្ត ៨ ដួង ( វៀរអរូបវិបាក ៤ ) លោកុត្តរចិត្ត ៧ ដួង ( វៀរសោតាបត្តិមគ្គ ) សរុប ត្រូវជា**ចិត្ត ៤២ ដួង ចេតសិក ៤៦** ( វៀរទោសោ ឥស្សា មច្ឆរិយំ កុក្កុច្ចំ អប្បមញ្ញា ២ ) ។

### ចំពោះបច្ចនិកៈ មានឯកន្តៈ អនេកន្តៈ

**ឯកន្តៈ** = អរូបវិបាក ៤ ដួង ចេតសិក ៣០ និងរូបទាំង ៧ ពួក ( រូបទាំងអស់ ) ។

**អនេកន្តៈ** = ចិត្ត ៤២ ដួង ចេតសិក ៤៦ ដែលជាអនេកន្តៈ របស់បច្ចយុប្បន្នៈហ្នឹងឯង ព្រោះថា ចិត្តុប្បាទ ៤២ ដួងនេះ អាចកើត

ក្នុងអរូបព្រហ្មបាន ដូច្នេះ ចិត្តុប្បាទ ៤២ ដួងនេះ មិនអាស្រ័យវត្ថុរូប ក៏អាចប្រព្រឹត្តទៅបាន ពេលណាមិនអាស្រ័យវត្ថុរូប គឺជាវត្ថុបុរេជាតនិស្សយប្បច្ចនិកៈ ប៉ុន្តែបើនៅក្នុងបញ្ចវោការភព ចិត្តុប្បាទ ៤២ ដួងនេះ ទៀងតែអាស្រ័យវត្ថុរូបកើតឡើង គឺ ជាវត្ថុបុរេជាតនិស្សយប្បច្ចយុប្បន្នៈ ។

### ដោយលក្ខណៈ កាល ជាតិ សត្តិ

ដោយលក្ខណៈ = មាន ៣ លក្ខណៈ គឺ ដោយវត្ថុ ជាទីកើត ជាលក្ខណៈ ១ , ដោយបុរេជាត កើតមុន ជាលក្ខណៈ ១ , ដោយនិស្ស័យ ទីអាស្រ័យជាលក្ខណៈ ១ ។

ដោយជាតិ = គឺ ជាវត្ថុបុរេជាត ជាតិ ។

ដោយកាល = គឺ ជាបច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ បានដល់ សត្តិទាំងពីរ ។



### ៣. វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ

**បច្ច័យ** = ហទយវត្ថុរូប ដែលកើតក្នុងឧប្បាទខណៈនៃខណៈចិត្តទី ១៧ ដែលរាប់ថយក្រោយអំពីចុតិចិត្ត ជាវត្ថុដែលជាទីអាស្រ័យនៃមរណាសន្នវីថិចិត្តផង ទាំងដែលក្នុងពេលខ្លះ វត្ថុរូបនេះឯង ជាអារម្មណប្បច្ច័យនៃមរណាសន្នវីថិចិត្តទៀតផង ទាំងដែលត្រូវកើត មុនមរណាសន្នវីថិចិត្តផងនោះ ហទយវត្ថុរូបនេះឯង ទើបជាវត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ ។

**បច្ចយុប្បន្នៈ** = មរណាសន្នវីថិចិត្ត មានមនោទ្វារាវជ្ជនចិត្ត ១ ដួង កាមជវន ២៩ ដួង តទាលម្ពណចិត្ត ១១ ដួង អភិញ្ញាជវន ២ ដួង រួមត្រូវជា ៤៣ ដួង ប៉ុន្តែនៅក្នុងគម្ពីរវជីរសារជីកា បានសំដែងអំពីខណៈចិត្តគ្រប់ដួងទាំងអស់ ក្នុងនោះមហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ដួង និងហសិតុប្បាទចិត្ត ១ ដួង មិនដែលមានការកើតត្រឹម

តែ ៥ ខណៈទេ ដូច្នេះជាការសំដែងឲ្យឃើញថា ចិត្ត ៥ ដួងនេះ មិនមែនជាមរណាសន្នជវន ឡើយ ។ ដូច្នេះបើកាន់យកតាម គម្ពីរវជិរ-សារដីកា មរណាសន្នវិថិចិត្ត ដែលជាបច្ច-យុប្បន្នៈ របស់វត្ថារម្មណបុរេជាតនិស្សយប្ប-ច្ច័យ មានត្រឹម ៣៨ ដួងប៉ុណ្ណោះ ចេតសិក ៤៤ ( វៀរ ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ វិរតិ ៣ អប្បមញ្ញា ២ ) ។

**បច្ចនិកៈ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ ដែលក្នុងនោះ មិនមានចិត្តប្បាទណា ជាមរណាសន្នវិថិ និង សូម្បីជាមរណាសន្នវិថិចិត្ត ប៉ុន្តែមិនមាន ហទយវត្ថុជាទីអាស្រ័យរបស់ខ្លួននោះ ជា អារម្មណ៍ ព្រមទាំងរូបទាំងអស់ ។

**អង្គធម៌** ដែលជាបច្ចយុប្បន្នៈ ជាអនេកន្តៈទាំងអស់ មិនមាន អង្គធម៌ណាជា ឯកន្តៈឡើយ ។

**ដោយលក្ខណៈ ជាតិ កាល សត្តិ**

ដោយលក្ខណៈ : មាន ៤ គឺ វត្ថុជាទីកើត ជាលក្ខណៈ



១ , អារម្មណៈ ជាគ្រឿងតោង ជាទីរីករាយ ជាលក្ខណៈ ១ , បុរេជាត កើតមុន ជាលក្ខណៈ ១ , និស្សយ ជាទីអាស្រ័យ ជាលក្ខណៈ ១ ។

ដោយជាតិ : គឺ អារម្មណជាតិ ។

ដោយកាល : គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ : គឺ សត្តិទាំង ២ ។

**បញ្ហាវារៈ របស់សហជាតនិស្សយប្បច្ច័យ**

**មានបញ្ហាវារៈ ៩**

( ដូចសហជាតប្បច្ច័យទាំងអស់ )

**វត្ថុបុរេជាតនិស្សយប្បច្ច័យ**

**មាន ៣ បញ្ហាវារៈ**

**១ អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស និស្សយប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយនិស្សយប្បច្ច័យ ( វត្ថុបុរេជាតនិស្សយប្បច្ច័យ ) ។

**( ១ ) ចក្ខាយតនំ ចក្ខុវិញ្ញាណស្ស ( វត្ថុបុរេជាត ) និស្សយប្បច្ចយេន បច្ចយោ សោតាយតនំ ... ឃានាយតនំ ... ជិវ្ហាយតនំ ... កាយាយតនំ កាយវិញ្ញាណស្ស ( វត្ថុបុរេជាត ) និស្សយប្បច្ចយេន បច្ចយោ ។**

ចក្ខុបសាទ ជាបច្ច័យនៃចក្ខុវិញ្ញាណ ដោយវត្ថុបុរេជាត-និស្សយប្បច្ច័យ សោតបសាទ ... ឃានបសាទ ... ជិវ្ហាបសាទ ... កាយបសាទ ជាបច្ច័យនៃកាយវិញ្ញាណ ដោយវត្ថុបុរេជាតនិស្ស-យប្បច្ច័យ ។

**បច្ច័យ** = បសាទរូប ៥ ក្នុងឋិតិខណៈ ។

**បច្ចយុប្បន្ន** = ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួង ចេតសិក ៧ ។

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល និងមរណាសន្ន-



កាល ។

ដោយភូមិ : គឺ បញ្ចវោការភូមិ ។

ដោយបុគ្គល : គឺប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក ផលបុគ្គល ៤ ពួក ។

ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ទ្វាររៀង ៗ ខ្លួន ។

ដោយវិថិ : គឺ ប្រព្រឹត្តទៅបញ្ចទ្វារវិថិ និងមរណាសន្នវិថិ ។

**( ២ ) វត្ថុ វិបាកាព្យាកតានំ កិរិយាព្យាកតានំ ខន្ធានំ ( វត្ថុបុរេជាត ) និស្សយប្បច្ចយេន បច្ចយោ ។**

ហទយវត្ថុ ជាបច្ច័យនៃអព្យាកតនាមក្ខន្ធ ៤ ដោយនិស្សយប្ប-ច្ច័យ ( វត្ថុបុរេជាត ) ។

**បច្ច័យ** = ហទយវត្ថុរូប ក្នុងកាល ៣ , ទី ១ ហទយវត្ថុ ចាប់តាំងពីឧប្បាទខណៈនៃបដិសន្ធិ ជាទីអាស្រ័យនៃបឋមភវង្គជាដើម រហូតមក , ទី ២ ដោយ អនុមានលកលែចំពោះហទយវត្ថុ ដែលកើត

ឡើង មុននឹងព្រះអរហន្ត ឬព្រះអនាគាមីចេញពី និរោធសមាបត្តិ ប្រមាណ ១ ខណៈចិត្តជាដើម ជាទីអាស្រ័យនៃអរហត្តផល ឬអនាគាមិផល , ទី ៣ ហទយវត្ថុ ដែលកើតក្នុងឧប្បាទខណៈ នៃ ខណៈចិត្តទី ១៧ ដែលរាប់ថយក្រោយ ពីចុតិចិត្ត ។

**បច្ចយុប្បន្ន** = វិបាកចិត្ត ២២ ដួង មានបឋមភវង្គជាដើម ( វៀរ ទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាក ៤ ) ចេតសិក ៣៨ កិរិយាចិត្ត ២០ ដួង មាន អាវជ្ជនចិត្តជាដើមចេតសិក ៣៥ ។

**ដោយកាល ភូមិ បុគ្គល ទ្វារ**

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល និងមរណាសន្នកាល ។

ដោយភូមិ : គឺ បញ្ចវោការភូមិ ។

ដោយបុគ្គល : គឺប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក ផលបុគ្គល ៤ ពួក ។



ដោយទ្វារ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ទ្វារវៀង ៗ ខ្លួន ។

ដោយវិថិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវិថិ កាមមនោទ្វារវិថិ មរណាសន្នវិថិ ឈានវិថិ អភិញ្ញាវិថិ មគ្គវិថិ ( ផលដែលកើតឡើងក្នុងមគ្គវិថិនោះ ) ផលសមាបត្តិវិថិ និរោធសមាបត្តិវិថិ ។

## បញ្ហាវារៈទី ២

**អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស និស្សយប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃកុសលធម៌ ដោយនិស្សយប្បច្ច័យ ។

**វត្ថុ កុសលានំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ ។**

**ហទយវត្ថុ** ⟶ **កុ.២១ ចេ.៣៨**

**បច្ច័យ** = ហទយវត្ថុ ដែលកើតក្នុងខណៈនៃវោដ្ឋព្វនៈ ឬមនោទ្វារាវជ្ជនៈជាដើម ។

**បច្ចយុប្បន្នៈ** = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

### ដោយកាល ភូមិ បុគ្គល ទ្វារ វីថិ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ បញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក ព្រះសេក្ខ-
បុគ្គល ៧ ពួក ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវីថិ និងកាមមនោ-
ទ្វារវីថិ អប្បនាវីថិ មរណាសន្នវីថិ ។

### បញ្ហាវារៈទី ៣

**អព្យាកតោ ធម្មោ អកុសលស្ស ធម្មស្ស**

**និស្សយប្បច្ចយេន បច្ចយោ ។**

អព្យាកតធម៌ ជាបច្ច័យនៃអកុសលធម៌ ដោយនិស្សយប្បច្ច័យ ។

**វត្ថុ អកុសលានំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ ។**

**ហទយវត្ថុ → អកុ.១២ ចេ.២៧**



**បច្ច័យ** = ហទយវត្ថុក្នុងឋិតិខណៈ ។

**បច្ចយុប្បន្នៈ** = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

### ដោយកាល ភូមិ បុគ្គល ទ្វារ វីថិ

ដោយកាល : គឺ ប្រព្រឹត្តទៅក្នុងបវត្តិកាល ។

ដោយភូមិ : គឺ បញ្ចវោការភូមិ ។

ដោយបុគ្គល : គឺ ប្រព្រឹត្តទៅក្នុងបុថុជ្ជន ៤ ពួក ផល-
បុគ្គល ៣ ពួក ។

ដោយវីថិ : គឺ ប្រព្រឹត្តទៅក្នុងបញ្ចទ្វារវីថិកាមមនោ-
ទ្វារវីថិ ។

### បញ្ហាវារៈ ដោយមិស្សកនិស្សយប្បច្ច័យ

### បញ្ហាវារៈទី ១

**កុសលោ ច អព្យាកតោ ច ធម្មា កុសលស្ស ធម្មស្ស**

**និស្សយប្បច្ចយេន បច្ចយោ ។**

*កុសលធម៌ផង អព្យាកតធម៌ផង ជាបច្ច័យនៃកុសលធម៌*
*ដោយនិស្សយប្បច្ច័យ ។*

*កុ.២១ ចេ.៣៨ ហទយវត្ថុ ⟶ កុ.២១ ចេ.៣៨*

**កុសលោ ឯកោ ខន្ធោ ច វត្ថុ ច តិណ្ណន្នំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ , តយោ ខន្ធា ច វត្ថុ ច ឯកស្ស ខន្ធស្ស និស្សយប្បច្ចយេន បច្ចយោ , ទ្វេ ខន្ធា ច វត្ថុ ច ទ្វិន្នំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ ។**

*នាមក្ខន្ធ.១ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ.៣*
*នាមក្ខន្ធ.៣ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ.១*
*នាមក្ខន្ធ.២ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ.២*

## បញ្ហាវារៈទី ២

**អកុសលោ ច អព្យាកតោ ច ធម្មា អកុសលស្ស ធម្មស្ស**
**និស្សយប្បច្ចយេន បច្ចយោ ។**

*អកុសលធម៌ផង អព្យាកតធម៌ផង ជាបច្ច័យនៃអកុសល*
*ដោយនិស្សយប្បច្ច័យ ។*



**អកុ.១២ ចេ.២៧ ហទយវត្ថុ ⟶ កុ.១២ ចេ.២៧**

**អកុសលោ ឯកោ ខន្ធោ ច វត្ថុ ច តិណ្ណន្នំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ , តយោ ខន្ធា ច វត្ថុ ច ឯកស្ស ខន្ធស្ស និស្សយប្បច្ចយេន បច្ចយោ , ទ្វេ ខន្ធា ច វត្ថុ ច ទ្វិន្នំ ខន្ធានំ និស្សយប្បច្ចយេន បច្ចយោ ។**

*អកុ.នាមក្ខន្ធ.៤ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ ៣*
*អកុ.នាមក្ខន្ធ.៣ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ ១*
*អកុ.នាមក្ខន្ធ.២ ហទយវត្ថុក្នុងបវត្តិខណៈ ⟶ នាមក្ខន្ធ ២*

***ទាំងពីរបញ្ហាវារៈ*** *ក្នុងមិស្សកបច្ច័យនេះ ចំពោះនាមក្ខន្ធ ៤ ជាសហជាតនិស្សយប្បច្ច័យ ដល់គ្នាទៅវិញទៅមក ឯចំណែកហទយវត្ថុក្នុងបវត្តិខណៈ ជាវត្ថុបុរេជាតនិស្សយប្បច្ច័យដល់នាមក្ខន្ធ ៤ តែម្យ៉ាង ។*

## ៩. ឧបនិស្សយប្បច្ច័យ

**មាន ៣ បច្ច័យ**

*១ អារម្មណូបនិស្សយប្បច្ច័យ ។*

២ អនន្តរូបនិស្សយប្បច្ច័យ ។
៣ បកតូបនិស្សយប្បច្ច័យ ។

( ១ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ កុសលានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

កុសលធម៌ដែលកើតមុន ៗ ជាបច្ច័យនៃកុសលធម៌ដែលកើតក្រោយ ៗ ដោយឧបនិស្សយប្បច្ច័យ ។

-ដោយអារម្មណូបនិស្សយប្បច្ច័យ
-ដោយអនន្តរូបនិស្សយប្បច្ច័យ
-ដោយបកតូបនិស្សយប្បច្ច័យ

ដោយអារម្មណូបនិស្សយប្បច្ច័យ គឺ ៖

-លោកិយកុសលចិត្តុប្បាទ ១៧ ដួង ⟶ មហាកុសលញាណវិប្បយុត្ត ៤ ដួង ចេតសិក ៣២ ( វៀរ បញ្ញា វិរតិ ៣ អប្បមញ្ញា ២ ) ។

-កុសលចិត្តុប្បាទ ២០ ( វៀរអរហត្តមគ្គ ) ⟶ មហាកុសលញាណសម្បយុត្ត ៤ ដួង ចេតសិក ៣៣ ។



សរុប

-កុសលចិត្តុប្បាទ ២០ ដួង ( វៀរអរហត្តមគ្គ )

⟶

មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣

( ដូចអារម្មណាធិបតិប្បច្ច័យ )

ដោយអនន្តរូបនិស្សយប្បច្ច័យ គឺ ៖

បច្ច័យ = លោកិយកុសលចិត្ត ១៧ ដួង ចេតសិក ៣៨ ដែលកើតក្នុងខណៈមុន ៗ ។

បច្ចយុប្បន្នៈ = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ដែលកើតក្រោយ ៗ ។

( ដូចអនន្តរប្បច្ច័យ )

ដោយបកតូបនិស្សយប្បច្ច័យ គឺ ៖

បច្ច័យ = កុសលចិត្ត ២០ ដួង ចេតសិក ៣៨ ដែលកើតក្នុងខណៈមុន ៗ ច្រើនខណៈក្តី ច្រើនជាតិកន្លងទៅហើយក្តី ។

បច្ចុប្បន្នៈ = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ដែលកើតក្រោយ ៗ ។

( ២ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អកុសលានំ ធម្មានំ កេសញ្ចិ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយអារម្មណូ. និង បកតូ.

ដោយអារម្មណូ. គឺ ៖

លោកិយកុសលចិត្តុប្បាទ ១៧ ដួង ⟶ លោកមូលចិត្ត ៨ ចេ. ២២

ដោយបកតូ គឺ ៖

បច្ច័យ = លោកិយកុសលចិត្តុប្បាទ ១៧ ដួង ដ៏មានកម្លាំង ។

បច្ចុប្បន្ន = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

( ៣ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយអារម្មណូ. , អនន្តរូ. , បកតូ.

ដោយអារម្មណូបនិស្សយប្បច្ច័យ គឺ ៖



អរហត្តមគ្គចិត្តុប្បាទ ⟶ មហា.កិ.ញាណសម្ប ៤ ដួង ចេ. ៣៣ ។

ដោយអនន្តរូបនិស្សយប្បច្ច័យ គឺ ៖

បច្ច័យ = កុសលចិត្តុប្បាទ ២១ ដួង ។

បច្ចុប្បន្ន = កាមាវចរវិបាក ១១ ដួង ( ៨ . ៣ ) មហគ្គតវិបាក ៩ ដួង និងលោកុត្តរវិបាក ៤ ដួង សរុបបាន វិបាក ២៤ ដួង ចេតសិក ៣៨ ។

ដោយបកតូនិស្សយប្បច្ច័យ គឺ ៖

បច្ច័យ = កុសលចិត្តុប្បាទ ២១ ដ៏មានកម្លាំង ។

បច្ចុប្បន្ន = វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០ ដួង ចេ.៣៨ ។

( ៤ ) បុរិមា បុរិមា អកុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អកុសលានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយអារម្មណូ. , អនន្តរូ. , បកតូបនិស្សយប្បច្ច័យ

ដោយអារម្មណូបនិស្សយប្បច្ច័យ គឺ ៖

លោកៈ ៨ ចេតសិក ២២ ⟶ លោកៈ ៨ ចេតសិក ២២ ។

ដោយអនន្តរូបនិស្សយប្បច្ច័យ គឺ ៖

អកុ.១២ ចេ.២៧ មុន ៗ ⟶ អកុ.១២ ចេ.២៧ ក្រោយ ៗ ។

ដោយបកតូបនិស្សយប្បច្ច័យ គឺ ៖

អកុ.១២ ចេ.២៧ មុន ៗ ដ៏មានកម្លាំង ⟶ អកុ.១២ ចេ.២៧ ក្រោយ ៗ ។

( ៥ ) បុរិមា បុរិមា អកុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ



កុសលានំ ធម្មានំ កេសញ្ចិ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយបកតូបនិស្សយប្បច្ច័យ គឺ ៖

អកុ.១២ ចេ.២៧ មុន ៗ ដ៏មានកម្លាំង ⟶ កុ.២១ ចេ.៣៨ ក្រោយ ៗ ។

( ៦ ) បុរិមា បុរិមា អកុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ដោយអនន្តរូបនិស្សយប្បច្ច័យ និងបកតូបនិស្សយប្បច្ច័យ

ដោយអនន្តរូបនិស្សយប្បច្ច័យ គឺ ៖

អកុ.១២ ចេ.២៧ ⟶ វិបាកចិត្ត ២០

ដោយបកតូបនិស្សយប្បច្ច័យ គឺ ៖

បច្ច័យ = អកុសលចិត្ត ១២ ដ៏មានកម្លាំង ចេតសិក ២៧ ។

បច្ចយុប្បន្ន = អព្យាកតចិត្ត ៥៦ ដួង ចេតសិក ៣៨ ។

( ៧ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ អព្យាកតានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

<u>ដោយអារម្មណូ. អនន្តរូ. និងបកតូ.</u>

<u>អារម្មណូបនិស្សយប្បច្ច័យ គឺ ៖</u>

អរហត្តផល និងនិព្វាន ⟶ មហាកិ.៤ ជាបច្ចវេក្ខណញ្ញាណ

និព្វាន ⟶ ផលចិត្ត ៤ ដួង

<u>អនន្តរូបនិស្សយប្បច្ច័យ គឺ ៖</u>

អព្យាកតចិត្តមុន ៗ ⟶ អព្យាកតចិត្តក្រោយ ៗ

<u>បកតូបនិស្សយប្បច្ច័យ គឺ ៖</u>



បច្ច័យ = រូប ២៨ អព្យាកតចិត្ត ៥៦ ដួង ចេតសិក ៣៨ ។

បច្ចយុប្បន្ន = អព្យាកតចិត្ត ៥៦ ដួង ចេតសិក ៣៨ ។

( ៨ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ កុសលានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

<u>ដោយអារម្មណូ. អនន្តរូ. និងបកតូ.</u>

<u>អារម្មណូបនិស្សយប្បច្ច័យ គឺ ៖</u>

ផលចិត្ត ៣ ខាងក្រោម និងនិព្វាន ⟶ មហាកុ.៤

ជាបច្ចវេក្ខណញ្ញាណ ។

និព្វាន ⟶ មគ្គចិត្ត ៤ ដួង

<u>អនន្តរូបនិស្សយប្បច្ច័យ គឺ ៖</u>

បច្ច័យ = វោដ្ឋព្វនៈ ឬមនោទ្វារាវជ្ជនៈ ។

បច្ចយុប្បន្ន = មហាកុសលចិត្ត ជវនខណៈទី ១ ។

<u>បកតូបនិស្សយប្បច្ច័យ គឺ ៖</u>

បច្ច័យ = វិបាកចិត្ត ៣៥ ( វៀរអរហត្តផល ) ឬ
វិបាកចិត្ត ៣៦ ដួង កិរិយាចិត្ត ២០
ចេតសិក ៣៨ និងរូប ២៨ ។

បច្ចយុប្បន្ន = កុសលចិត្ត ២១ ដួង ចេតសិក ៣៨ ។

( ៨ ) បុរិមា បុរិមា អព្យាកតា ធម្មា បច្ឆិមានំ បច្ឆិមានំ អកុសលានំ ធម្មានំ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

<u>ដោយអារម្មណូ. អនន្តរូ. និងបកតូ.</u>

<u>អារម្មណូបនិស្សយប្បច្ច័យ គឺ ៖</u>

បច្ច័យ = ឥដ្ឋនិប្ផន្នរូប ១៨ លោកិយវិបាកចិត្ត ៣១



( វៀរ ទុក្ខកាយវិ. ) កិរិយាចិត្ត ២០ ដួង
ចេតសិក ៣៥ ។

បច្ចយុប្បន្ន = លោភមូលចិត្ត ៨ ដួង ចេតសិក ២២ ។

<u>អនន្តរូបនិស្សយប្បច្ច័យ គឺ ៖</u>

បច្ច័យ = វោដ្ឋព្វនៈ ឬមនោទ្វារាវជ្ជនៈ ។

បច្ចយុប្បន្ន = អកុសលចិត្ត ជវនខណៈទី ១ ។

<u>បកតូបនិស្សយប្បច្ច័យ គឺ ៖</u>

បច្ច័យ = រូប ២៨ លោកិយវិបាកចិត្ត ៣២ ដួង
កិរិយាចិត្ត ២០ ដួង ចេតសិក ៣៥ ។

បច្ចយុប្បន្ន = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

( ១០ ) ឧតុភោជនម្បិ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

( ១១ ) បុគ្គលោបិ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

( ១២ ) សេនាសនម្បិ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

សូម្បីឧតុ ភោជន បុគ្គល សេនាសនៈ ក៏ជាបច្ច័យនៃកុសល ឬអកុសល ដោយបកតូបនិស្សយប្បច្ច័យផងដែរ ។

**ដោយលក្ខណៈជាដើម ៖**

អារម្មណូ. និងអនន្តរូ. មានលក្ខណៈដូចអារម្មណាធិបតិប្បច្ច័យ និងអនន្តរប្បច្ច័យ គ្រាន់តែ **ឧបនិស្សយប្បច្ច័យ** គឺជាទីអាស្រ័យដ៏មានកម្លាំង ជាលក្ខណៈ បន្ថែមទៀតប៉ុណ្ណោះ , **បកតូបនិស្សយប្បច្ច័យ** គឺមានប្រក្រតី ជាទីអាស្រ័យដ៏មានកម្លាំង ជាលក្ខណៈ ។

កុសលក្នុងភូមិ ៣ ( កាមភូមិ រូបភូមិ អរូបភូមិ ) ជាបកតូ-បនិស្សយប្បច្ច័យ ដោយកុសលក្នុងភូមិ ៤ , អកុសល , វិបាកក្នុងភូមិ ៤ និងកិរិយាក្នុងភូមិ ៣ ។

លោកុត្តរកុសល មិនជាបកតូបនិស្សយប្បច្ច័យដល់អកុសលខ្លួនឯង ប៉ុន្តែជាបច្ច័យនៃអកុសលរបស់អ្នកដទៃ ដូចជា លោភៈ មានះជាដើម ព្រោះដឹងថា លោកគ្រូអញបានសម្រេចគុណធម៌ ឬការប្រណែន ការកំណាញ់ មានកំណាញ់ត្រកូល កំណាញ់កេរ្តិ៍ឈ្មោះជាដើម កើតឡើង ។

អកុសល ជាបកតូបនិស្សយប្បច្ច័យនៃកុសលក្នុងភូមិ ៤ អកុសល, វិបាកក្នុងភូមិ ៤ , កិរិយាទាំងអស់ ។



វិបាកក្នុងភូមិ ៣ ជាបកតូបនិស្សយប្បច្ច័យនៃអរូបនាមក្ខន្ធ ក្នុងជាតិទាំង ៤ ( កុសលជាតិ អកុសលជាតិ កិរិយាជាតិ វិបាកជាតិ ) ។

លោកុត្តរវិបាក មិនជាបច្ច័យនៃអកុសល , លោកុត្តរវិបាក ៣ ខាងក្រោមរបស់ខ្លួន ជាបកតូបនិស្សយប្បច្ច័យនៃកុសលរបស់ខ្លួន , អរហត្តផលរបស់អ្នកដទៃ ជាបច្ច័យនៃកុសលរបស់អ្នកដទៃ ដោយបកតូបនិស្សយប្បច្ច័យបាន ។

កិរិយា ក៏ជាបច្ច័យដល់នាមក្ខន្ធទាំង ៤ ជាតិ ផងដែរ ។

ឧតុ ភោជន បុគ្គលជាដើម ជាអត្ថប្បញ្ញត្តិ ជាបកតូបនិស្ស-យប្បច្ច័យនៃកុសល និងអកុសលជាដើម ។

**បកតូបនិស្សយប្បច្ច័យ ចែកជាពីរ គឺ ៖**

**១ ឧប្បាទិត** បានដល់ ចិត្ត និងចេតសិក ដែលកើតមុន ៗ ហើយរលត់ទៅនៅក្នុងសន្តានរបស់ខ្លួន ជាសភាវៈដ៏មានកម្លាំង ញ៉ាំងចិត្ត និងចេតសិកក្រោយ ៗ ឲ្យកើតឡើង ។

**២ ឧបសេវិត** បានដល់ ចិត្ត ចេតសិក រូប និងបញ្ញត្តិក្រៅអំពី

ខ្ទួន ដែលខ្ទួនឯងបានចូលទៅអាស្រ័យ រូបខ្ទួនឯងក្តី ប្រព្រឹត្តទៅក្នុងកាលទាំង ៣ ទាំងជាកាលវិមុត្តិ គឺ ជាបញ្ញត្តិ ជាបច្ច័យនៃចិត្ត និងចេតសិក ។

+ ចិត្ត និងចេតសិកប៉ុណ្ណោះ ជាបច្ចយុប្បន្នៈ ។

+ រូបទាំងអស់ ៧ ពួក ជាបច្ចនិកៈ ។

**ដោយជាតិ កាល សត្តិ**

ដោយជាតិ : បានដល់ បកតូបនិស្សយជាតិ មាន ២ យ៉ាងដែរ គឺ ៖

១ **សុទ្ធបកតូបនិស្សយជាតិ** បានដល់ ចិត្ត ចេតសិក រូប បញ្ញត្តិ ( អត្ថប្បញ្ញត្តិពួកខ្លះ និងសទ្ទប្បញ្ញត្តិពួកខ្លះ ) ក្នុងនោះមានទាំងមគ្គចេតនាផងដែរ មគ្គចេតនានេះ ជានានក្ខណិកកម្មប្បច្ច័យដល់លោកុត្តរវិបាក ( អនន្តរកម្មប្បច្ច័យ ) ។

២ **មិស្សកបកតូបនិស្សយជាតិ** បានដល់ នានក្ខណិកកម្ម-បកតូបនិស្សយប្បច្ច័យ ( វៀរមគ្គចេតនា ) បានដល់ លោកិយកម្ម ដែលធ្វើក្នុងខណៈមុន ៗ មានកម្លាំង ញុំាងវិបាកឲ្យកើតឡើង ( វៀរកម្មជរូប ) ។



ដោយកាល : ប្រព្រឹត្តទៅក្នុងកាលទាំង ៣ ព្រមទាំងកាលវិមុត្តិ ។

ដោយសត្តិ : ជាជនកសត្តិតែម្យ៉ាង ។

## បញ្ហាវារៈរបស់បកតូបនិស្សយប្បច្ច័យ

### បញ្ហាវារៈ មាន ៩

### បញ្ហាវារៈទី ១

<u>បាលីវិធី</u>

កុសលោ ធម្មោ កុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

កុ. ⟶ កុ.

កុ.២០ ( វៀរអរហត្តមគ្គ ) ចេ. ៣៨ ⟶ កុ.២១

ចេ.៣៨

<u>បាលីអនុវាទ</u>

( ១ ) សទ្ធំ ឧបនិស្សាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ឈានំឧប្បាទេតិ វិបស្សនំ ឧប្បាទេតិ មគ្គំ

**ឧប្បាទេតិ អភិញ្ញំ ឧប្បាទេតិ សមាបត្តឹ ឧប្បាទេតិ ។ សីលំ ។ល។ សុតំ ។ល។ ចាគំ ។ល។ បញ្ញំ ។ល។**

បុគ្គលអាស្រ័យសទ្ធា រមែងឲ្យទាន សមាទានសីល រក្សាឧបោសថ ញុំាងឈាន វិបស្សនា មគ្គ អភិញ្ញា សមាបត្តិ ឲ្យកើតឡើង ។ បុគ្គលអាស្រ័យ សីល សុតៈ ចាគៈ បញ្ញា រមែងឲ្យទាន សមាទានសីល រក្សាឧបោសថ ញុំាងឈាន វិបស្សនា មគ្គ អភិញ្ញា សមាបត្តិ ឲ្យកើតឡើង ។

**( ២ ) សទ្ធា ... សីលំ ... សុតំ ... ចាគោ ... បញ្ញា សទ្ធាយ សីលស្ស សុតស្ស ចាគស្ស បញ្ញាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

សទ្ធា សីល សុតៈ ចាគៈ បញ្ញា ជាបច្ច័យជួយឧបការៈដល់សទ្ធា សីល សុតៈ ចាគៈ បញ្ញា ដោយបកតូបនិស្សយប្បច្ច័យ ។

**កុ. ២០ ចេ.៣៨ ⟶ កុ.២១ ចេ.៣៨**

**( ៣ ) បឋមស្ស ឈានស្ស បរិកម្មំ បឋមស្ស ឈានស្ស**



**ឧបនិស្សយប្បច្ចយេន បច្ចយោ ទុតិយស្ស ... តតិយស្ស ... ចតុត្ថស្ស ... អាកាសនញ្ចាយតនស្ស ... វិញ្ញាណញ្ចាយតនស្ស ... អាកិញ្ចញ្ញាយតនស្ស ... នេវសញ្ញានាសញ្ញាយតនស្ស ... ។**

ចិត្តដែលធ្វើនាទីបរិកម្មរបស់ឈានទាំង ៨ មានបឋមជ្ឈានជាដើម ជាបច្ច័យជួយឧបការៈដល់ឈានទាំង ៨ ដែលកើតតអំពីបរិកម្ម ដោយឧបនិស្សយប្បច្ច័យ ។

**កុ.ញាណសំ. ៤ ចេ.៣៥ ដែលជាបរិកម្មក្នុងឈានទាំង ៨**

⟶

**មហគ្គតកុសល ៨ ចេតសិក ៣៥**

**( ៤ ) បឋមំ ឈានំ ទុតិយស្ស ឈានស្ស ឧបនិស្ស-យប្បច្ចយេន បច្ចយោ , ទុតិយំ ឈានំ តតិយស្ស ឈានស្ស , តតិយំ ឈានំ ចតុត្ថស្ស ឈានស្ស , ចតុត្ថំ ឈានំ អាកាសា-នញ្ចាយតនស្ស អាកាសានញ្ចាយតនំ វិញ្ញាណញ្ចាយតនស្ស , វិញ្ញាណញ្ចាយតនំ អាកិញ្ចញ្ញាយតនស្ស , អាកិញ្ចញ្ញាយតនំ នេវ-សញ្ញានាសញ្ញាយតនស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

ឈានខាងក្រោម មានបឋមជ្ឈានជាដើម ជាបច្ច័យដល់ឈានខាងលើតាមលំដាប់ ដោយបកតូបនិស្សយប្បច្ច័យ ។

បឋមជ្ឈានកុ. ១ ចេ. ៣៥ ⟶ ទុតិយជ្ឈានកុ.១ ចេ.៣៣
( វៀរវិតក្ក វិចារ ) ។

ទុតិយជ្ឈានកុ. ១ ចេ. ៣៣ ⟶ តតិយជ្ឈានកុ.១ ចេ.៣២
( វៀរវិតក្ក វិចារ បីតិ ) ។

តតិយជ្ឈានកុ. ១ ចេ. ៣២ ⟶ ចតុត្ថជ្ឈានកុ.១ ចេ.៣០
( វៀរវិតក្ក វិចារ បីតិ អប្ប.២ ) ។

ចតុត្ថជ្ឈានកុ. ១ ចេ. ៣០ ⟶ អាកាសា.កុ.១ ចេ.៣០

អាកាសាកុ. ១ ចេ. ៣០ ⟶ វិញ្ញា.កុ.១ ចេ.៣០

វិញ្ញាកុ. ១ ចេ. ៣០ ⟶ អាកិញ្ច.កុ.១ ចេ.៣០

អាកិញ្ចកុ. ១ ចេ. ៣០ ⟶ នេវ.កុ.១ ចេ.៣០

**( ៥ ) ទិព្វស្ស ចក្ខុស្ស បរិកម្មំ ទិព្វស្ស ចក្ខុស្ស ឧបនិស្សយ-**



**ប្បច្ចយេន បច្ចយោ ទិព្វាយ សោតធាតុយា បរិកម្មំ ទិព្វាយ សោតធាតុយា , ឥទ្ធិវិធញ្ញាណស្ស បរិកម្មំ ឥទ្ធិវិធញ្ញាណស្ស , ចេតោបរិយញ្ញាណស្ស បរិកម្មំ ចេតោបរិយញ្ញាណស្ស , បុព្វេនិវា-សានុស្សតិញ្ញាណស្ស បរិកម្មំ បុព្វេនិវាសានុស្សតិញ្ញាណស្ស , យថាកម្មុបគញ្ញាណស្ស បរិកម្មំ យថាកម្មុបគញ្ញាណស្ស , អនា-គតំសញ្ញាណស្ស បរិកម្មំ អនាគតំសញ្ញាណស្ស ឧបនិស្សយប្ប-ច្ចយេន បច្ចយោ ។**

បរិកម្មភាវនាដែលកើតមុនអភិញ្ញាផ្សេង ៗ មានទិព្វចក្ខុជាដើម ជាបច្ច័យនៃអភិញ្ញាកុសលផ្សេង ៗ តាមដែលខ្លួនត្រូវការ ដោយឧប-និស្សយប្បច្ច័យ ។

កុ.សំ.៤ ចេ.៣៣ ដែលធ្វើបរិកម្មក្នុងអភិញ្ញាវីថិ ⟶ អភិញ្ញាកុ.១ ចេ.៣០ ។

**( ៦ ) ទិព្វំ ចក្ខុ ទិព្វាយ សោតធាតុយា ឧបនិស្សយប្បច្ចយេន បច្ចយោ , ទិព្វា សោតធាតុ ឥទ្ធិវិធញ្ញាណស្ស , ឥទ្ធិវិធញ្ញាណំ ចេតោបរិយញ្ញាណស្ស , ចេតោបរិយញ្ញាណំ បុព្វេនិវាសានុស្ស-តិញ្ញាណស្ស បុព្វេនិវាសានុស្សតិញ្ញាណំ យថាកម្មុបគញ្ញាណស្ស ,**

**យថាកម្មុបគញ្ញាណំ អនាគតំសញ្ញាណស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

*អភិញ្ញាកុសល ជាបច្ច័យដល់អភិញ្ញាកុសលតាមលំដាប់ដូចជា ទិព្វចក្ខុ ជាបច្ច័យដល់ទិព្វសោតជាដើម ដោយឧបនិស្សយប្បច្ច័យ ។*

*- ទិព្វចក្ខុ ទិព្វសោត ឥទ្ធិវិធ ចេតោ បុព្វេ*
*យថាកម្មុ អភិញ្ញាកុ.១ ចេ.៣០*

→

*ទិព្វសោត ឥទ្ធិវិធ ចេតោ បុព្វេ យថាកម្មុ*
*អភិញ្ញាកុ.១ ចេ.៣០ តាមលំដាប់*

**( ៧ ) បឋមស្ស មគ្គស្ស បរិកម្មំ បឋមស្ស មគ្គស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ , ទុតិយស្ស មគ្គស្ស បរិកម្មំ ទុតិយស្ស មគ្គស្ស , តតិយស្ស មគ្គស្ស បរិកម្មំ តតិយស្ស មគ្គស្ស , ចតុត្ថស្ស មគ្គស្ស បរិកម្មំ ចតុត្ថស្ស មគ្គស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

*បរិកម្មដែលកើតមុន ៗ នៃមគ្គទាំង ៤ ជាបច្ច័យដល់មគ្គទាំង ៤ ដោយ ចំពោះរបស់ខ្លួន ដោយឧបនិស្សយប្បច្ច័យ ។*



*មហាកុ.សំ.៤ ចេ.៣៣ ដែលបរិកម្មដល់មគ្គ → មគ្គ.៤ ចេ.៣៦*
*ដោយចំពោះ ។*

**( ៨ ) បឋមោ មគ្គោ ទុតិយស្ស មគ្គស្ស ឧបនិស្សយ-ប្បច្ចយេន បច្ចយោ ទុតិយោ មគ្គោ តតិយស្ស មគ្គស្ស , តតិយោ មគ្គោ ចតុត្ថស្ស មគ្គស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

*សោតាបត្តិមគ្គ ជាបច្ច័យនៃសកទាគាមិមគ្គ , សកទាគាមិមគ្គ ជាបច្ច័យនៃអនាគាមិមគ្គ , អនាគាមិមគ្គ ជាបច្ច័យនៃអរហត្តមគ្គ ដោយឧបនិស្សយប្បច្ច័យ ។*

*-សោតាបត្តិមគ្គ. សកទាគាមិមគ្គ អនាគាមិមគ្គ ចេតសិក ៣៦*
→
*សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ*
*ចេតសិក ៣៦ តាមលំដាប់*

**( ៩ ) សេក្ខា មគ្គំ ឧបនិស្សាយ អនុប្បន្នំ សមាបត្តឹ ឧប្បាទេន្តិ ឧប្បន្នំ សមាបជ្ជន្តិ , សង្ខារេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។**

*ព្រះសេក្ខបុគ្គលទាំងឡាយ អាស្រ័យមគ្គដែលខ្លួនបានហើយ ធ្វើឈានសមាបត្តិដែលមិនទាន់កើត ឲ្យកើតឡើង កាលឈានកើត*

ហើយ ក៏ពិចារណាសង្ខារទាំងឡាយដោយភាពជាអនិច្ចំ ទុក្ខំ អនត្តា ដោយឧបនិស្សយប្បច្ច័យ ។

មគ្គ ៣ ខាងក្រោម ចេ.៣៦ ⟶ មហគ្គតកុ.៩ ចេ.៣៥

មគ្គ ៣ ខាងក្រោម ចេ.៣៦ ⟶ មហាកុ.៨ ចេ.៣៣ ( វិបស្សនា )

## សមាបត្តិ មាន ៣

**១ ឈានសមាបត្តិ** គឺ បានដល់ មហគ្គតកុសល ៩ ចូលបានទាំងបុថុជ្ជន និងសេក្ខបុគ្គល និងមហគ្គតកិរិយា ៩ គឺ ជាឈាន-សមាបត្តិរបស់ព្រះអរហន្ត ឈានសមាបត្តិទាំងកុសល ទាំងកិរិយា មានខណៈចិត្តកើតតគ្នាច្រើនខណៈមិនកំណត់ចំនួន មិនមានភវង្គជាចន្លោះឡើយ ។

**២ ផលសមាបត្តិ** បានដល់ លោកុត្តរវិបាកចិត្ត ៤ ដួង ( ដោយពិស្តារ ២០ ដួង ) សម្រាប់តែព្រះអរិយបុគ្គល ដែលចូលបានតែក្នុងផលរបស់ខ្លួន មានសោតាបត្តិផលជាដើម ( ផលទាំង ៤ នេះ មិនមែនជាផលក្នុងមគ្គវីថិទេ ) ។

**៣ និរោធសមាបត្តិ** គឺ មិនមានចិត្ត ចេតសិកឡើយ ចូលបានចំពោះតែព្រះអនាគាមី និងព្រះអរហន្តប៉ុណ្ណោះ ដោយកម្លាំងសមថៈ



( រូបឈាន និងអរូបឈាន ទាំងអស់ ) ព្រមដោយកម្លាំងវិបស្សនា ។

## មគ្គវីថិ

ចម្រើនវិបស្សនា ដល់សង្ខារុបេក្ខាញាណ និងសមគួរដល់ឧបនិស្ស័យ ហើយមគ្គវីថិត្រូវកើតឡើង បន្ទាប់ពីចិត្តធ្លាក់ចុះកាន់ភវង្គហើយ ។

**ភវង្គ ។ មនោទ្វារាវជ្ជនៈ ជវន ៧ ខណៈ ។** គឺ ១.បរិកម្មជវន ( មហាកុសលញាណសម្បយុត្ត មានសង្ខារជាអារម្មណ៍ ) , ២.ឧប-ចារជវន ( មហាកុសលញាណសម្បយុត្ត មានសង្ខារជាអារម្មណ៍ ) , ៣.អនុលោមជវន ( មហាកុសលញាណសម្បយុត្ត មានសង្ខារជាអារម្មណ៍ ) , ៤.គោត្រភូជវន ( មហាកុសលញាណសម្បយុត្ត មានព្រះនិព្វានជាអារម្មណ៍ ) , ៥.មគ្គជវន ( លោកុត្តរកុសល ៤ ដួងណាមួយ មានព្រះនិព្វានជាអារម្មណ៍ ) , ៦.ផលជវន , ៧.ផលជវន ( ផល ២ ខណៈ ចុងក្រោយនេះ ជាលោកុត្តរវិបាក ៤ ដួង ណាមួយតាមសមគួរនៃមគ្គ មាននិព្វានជាអារម្មណ៍ រួចខណៈចិត្តធ្លាក់ចុះកាន់ភវង្គ ។

បន្ទាប់ពីមគ្គវីថិបានកើតឡើងហើយនោះ ចិត្តធ្លាក់ចុះកាន់ភវង្គ ទើបមនោទ្វារវីថិកើតឡើងក្រោយទៀត ជាបច្ចវេក្ខណវីថិ ។

**<u>ចំណាំ</u>** : ក្នុងមគ្គវីថិ មានជវន ៧ ខណៈ ពេលខ្លះមិនមាន បរិកម្មជវនទេ គឺ ចាប់ផ្ដើមដោយឧបចារជវនតែម្ដង ដូច្នេះផលជវនខាងចុង ត្រូវមាន ៣ ខណៈ ។

**( ១០ ) មគ្គោ សេក្ខានំ អត្ថប្បដិសម្ភិទាយ ធម្មប្បដិសម្ភិទាយ និរុត្តិប្បដិសម្ភិទាយ បដិភាណប្បដិសម្ភិទាយ ឋានាឋានកោសល្លស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

មគ្គរបស់ព្រះសេក្ខបុគ្គលខាងក្រោម ៣ ជាបច្ច័យជួយឧបការៈ ដល់បដិសម្ភិទា ៤ និងសេចក្ដីឆ្លាតឈ្លាសក្នុងហេតុដែលសមគួរ និងមិនសមគួរ ដោយឧបនិស្សយប្បច្ច័យ ។

| | | |
|---|---|---|
| **បច្ច័យ** | = | មគ្គខាងក្រោម ៣ ចេតសិក ៣៦ ។ |
| **បច្ចយុប្បន្ន** | = | ញាណ គឺ បញ្ញាក្នុងបដិសម្ភិទា ៤ និង ឋានាឋានញ្ញាណ ។ |

## បដិសម្ភិទា ៤

**<u>អត្ថប្បដិសម្ភិទា</u>** គឺ បញ្ញាបែកធ្លាយក្នុងអត្ថ ៥ យ៉ាង ៖



( ១ ) ផលដែលកើតអំពីបច្ច័យទាំងឡាយ ។

( ២ ) ព្រះនិព្វាន ។

( ៣ ) អត្ថនៃសុភាសិត ។

( ៤ ) វិបាកធម៌ ( វិបាកាធម្មា ) ។

( ៥ ) កិរិយាធម៌ ( កិរិយាចិត្ត ចេតសិក ) ។

**អត្ថប្បដិសម្ភិទានេះ** ជាលោកិយៈក៏មាន ជាលោកុត្តរៈក៏មាន ។ បញ្ញាក្នុងមគ្គចិត្ត ផលចិត្ត មាននិព្វានជាអារម្មណ៍ នេះជាលោកុត្តរៈ ឯចំណែកលោកិយៈ គឺ បញ្ញាក្នុងមហាកុសលញាណសម្បយុត្ត ៤ ដួង និងបញ្ញាក្នុងមហាកិរិយាញាណសម្បយុត្ត ៤ ដួង ។

**<u>ធម្មប្បដិសម្ភិទា</u>** គឺ បញ្ញាបែកធ្លាយក្នុងធម្មៈ ៥ យ៉ាង ៖

( ១ ) បច្ច័យដែលជាហេតុនៃផលទាំងឡាយ ។

( ២ ) អរិយមគ្គប្រកបដោយអង្គ ៨ ។

( ៣ ) សុភាសិត មានពុទ្ធភាសិតជាដើម ។

( ៤ ) កុសលធម៌ ។

( ៥ ) អកុសលធម៌ ។

**<u>និរុត្តិប្បដិសម្ភិទា</u>** គឺ បញ្ញាបែកធ្លាយក្នុងមគធភាសា ។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងធម៌ ៨៥ ព្រះវស្សាដោយមគធភាសាតែម្យ៉ាង បុគ្គលណា ៗ ក៏អាចស្ដាប់បាន ហាក់ដូចព្រះអង្គសម្ដែងភាសា

របស់ខ្លួន ដូច្នោះឯង ។

**និរុត្តិប្បដិសម្ភិទា :** មានសទ្ទរូបជាអារម្មណ៍ អាចពោលសម្ដែងក្នុងអត្ថទាំង ៥ និងធម្មៈទាំង ៥ បាន ។

**បដិភាណប្បដិសម្ភិទា :** មានបកតូបនិស្សយប្បច្ច័យ ៣ គឺ ៖

( ១ ) **បរិយត្តិ** → **បដិភាណ**

( ២ ) **បរិបុច្ឆា** → **បដិភាណ**

( ៣ ) **អធិគម** ការបានសម្រេចគុណធម៌ជាលោកុត្តរៈ ជាបច្ច័យនៃបដិភាណ ។

**បដិសម្ភិទា ៣** ( វៀរអត្ថប្បដិសម្ភិទា ) ជាបរិត្តធម៌ គឺជាកាមា-វចរៈតែម្យ៉ាង ( បញ្ញាក្នុងមហាកុសល និងមហាកិរិយាញាណសម្ប-យុត្ត ៨ ) ។

**បដិសម្ភិទា ៤** ស្ថិតនៅក្នុងឋានៈ ២ គឺ សេក្ខភូមិ និងអសេក្ខ-ភូមិ បានសេចក្ដីថា មានតែក្នុងព្រះអរិយបុគ្គលតែប៉ុណ្ណោះ ។ ព្រះ-អរិយបុគ្គល សុទ្ធតែមាននូវបដិសម្ភិទាតាមភូមិរបស់ខ្លួន ( សេក្ខភូមិ និងអសេក្ខភូមិ ) គ្រាន់តែគ្រប់ទាំង ៤ ឬក៏មិនគ្រប់តែប៉ុណ្ណោះ ។

**បដិភាណប្បដិសម្ភិទា** មានបដិសម្ភិទា ៣ ខាងដើម ជាអារ-ម្មណ៍ ។



## ឋានាឋានញ្ញាណ

គឺ ជាបញ្ញាដែលឆ្លាតឈ្លាស ដឹងក្នុងហេតុ និងមិនមែនហេតុ ៖

- ព្រះសោតាបន្នបុគ្គល មិនប្រកាន់ដោយទិដ្ឋិវិបល្លាស ក្នុងសង្ខារទាំងឡាយថា ទៀង សុខ និងថាជាអត្តា ការមិនប្រកាន់នេះ គឺជាឋានៈប្រព្រឹត្តទៅបាន ឯការដែលព្រះសោតាបន្នបុគ្គលប្រកាន់នូវសង្ខារថា ទៀង សុខ អត្តា នេះមិនមែន ឋានៈដែលប្រព្រឹត្តទៅបានឡើយ ។

- ព្រះសោតាបន្នបុគ្គល មិនធ្វើអនន្តរិយកម្ម ៥ មិនឧទ្ទិសចំពោះសាសនាដទៃ និងមិនមានជាតិជាគម្រប់ ៨ នេះជាឋានៈ , ឯការដែលព្រះសោតាបន្នបុគ្គល ធ្វើអនន្តរិយកម្ម ៥ , ចូលសាសនាដទៃ និងមានជាតិជាគម្រប់ ៨ គឺ មិនមែនជា ឋានៈឡើយ ។

- ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងក្នុងលោក ម្ដងតែមួយព្រះអង្គប៉ុណ្ណោះ នេះជាឋានៈ , ត្រាស់ដឹងពីរអង្គព្រមគ្នា ជាអឋានៈ ។

- ស្ដេចចក្រពត្តិ មានតែមួយអង្គក្នុងលោក ក្នុងពេលតែមួយ ជាឋានៈ , ពីរអង្គព្រមគ្នា ជាអឋានៈ ។

- ព្រះសម្មាសម្ពុទ្ធ ស្ដេចចក្រពត្តិ ព្រះឥន្ទ មារាធិរាជ និងព្រហ្ម ជាបុរស ( ព្រហ្មមិនមានភាវរូប តែទ្រង់ទ្រាយសណ្ឋានជាប្រុស ) ជាឋានៈ , បុគ្គលទាំង ៥ ពួកនេះ ជាស្ត្រី គឺ ជាអឋានៈ ។

- កាយសុចរិត វចីសុចរិត មនោសុចរិត នាំមកនូវអារម្មណ៍ជាទីប្រាថ្នា និងជាត្រេកអរ ជាឋានៈ , ដែលនាំមកនូវអារម្មណ៍មិនជាទីប្រាថ្នា មិនជាទីត្រេកអរនោះ មិនជាឋានៈឡើយ ។

- កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត នាំមកនូវអារម្មណ៍មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ជាឋានៈ , នាំមកនូវអារម្មណ៍ជាទីត្រេកអរ ជាទីពេញចិត្ត ជាអឋានៈ ។

- កាយសុចរិត វចីសុចរិត មនោសុចរិត នាំឲ្យមានវិបាកបដិសន្ធិក្នុងសុគតិភូមិ ជាឋានៈ , មានវិបាកបដិសន្ធិក្នុងទុគ្គតិភូមិ ជាអឋានៈ ។

- កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត នាំឲ្យមានវិបាកបដិសន្ធិក្នុងទុគ្គតិភូមិ គឺ ជាឋានៈ , ឲ្យមានវិបាកបដិសន្ធិក្នុងសុគតិភូមិ ជាអឋានៈ ។

## បញ្ហាវារៈ ទី ២

**កុសលោ ធម្មោ អកុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

**កុ. ⟶ អកុ.**



**( ១ ) សទ្ធំ ឧបនិស្សាយ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ សីលំ សុតំ ចាគំ បញ្ញំ ឧបនិស្សាយ មានំ ជប្បេតិ ទិដ្ឋឹ គណ្ហាតិ ។**

បុគ្គលអាស្រ័យសទ្ធា សីល សុត ចាគៈ បញ្ញា របស់ខ្លួនហើយ រមែងធ្វើមានះដែលមិនទាន់កើត ឲ្យកើតឡើង មានការប្រកាន់ខុសដោយទិដ្ឋិ ។

**លោកិ.កុ.១៧ ចេ.៣៨ មានសទ្ធាជាប្រធាន ⟶ លោភ.៨ ចេ.២២**

**( ២ ) សទ្ធា សីលំ ... សុតំ ... ចាគោ ... បញ្ញា រាគស្ស ទោសស្ស មោហស្ស មានស្ស ទិដ្ឋិយា បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

សទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា ជាបច្ច័យនៃរាគៈ ទោសៈ មោហៈ ទិដ្ឋិ និងសេចក្តីប្រាថ្នាភវសម្បត្តិ ភោគសម្បត្តិ ដោយឧបនិស្សយប្បច្ច័យ ។

លោកិយកុសលដែលកើតក្នុងសន្តានរបស់ខ្លួនមុន ៗ ជាបច្ច័យនៃអកុសលចិត្ត ១២ ដួង ( **បត្ថនាយ** ប្រែថា សេចក្តីប្រាថ្នា ) បានដល់ តណ្ហានោះឯង ។

លោកិយកុ.១៧ ចេ.៣៨ → អកុ.១២ ចេ.២៧

## បញ្ហាវារៈទី ៣

កុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

កុ. → អព្យា.

( ១ ) សទ្ធំ ឧបនិស្សាយ អត្តានំ អាតាបេតិ បរិតាបេតិ បរិយិដ្ឋិមូលកំ ទុក្ខំ បច្ចនុភោតិ , សីលំ ... សុតំ ... ចាគំ ... បញ្ញំ ឧបនិស្សាយ អត្តានំ អាតាបេតិ បរិតាបេតិ បរិយិដ្ឋិមូលកំ ទុក្ខំ បច្ចនុភោតិ ។

បុគ្គលអាស្រ័យសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា ហើយធ្វើខ្លួនឯងឲ្យក្តៅ ក្តៅសព្វ និងទទួលទុក្ខ ព្រោះមានការស្វែងរកជាមូល ។

លោកិយកុសល មានសទ្ធាជាដើម ជាប្រធាន ជាបច្ច័យនៃទុក្ខសហគតកាយវិញ្ញាណ ១ ដួង ចេតសិក ៧ ។

លោកិយកុ.១៧ ចេ.៣៨ → ទុក្ខ.កាយវិញ្ញាណ.១ ចេ.៧



( ២ ) សទ្ធា សីលំ សុតំ ចាគោ បញ្ញា កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

សទ្ធាជាដើម រហូតដល់បញ្ញាជាគម្រប់ ៥ អង្គធម៌នីមួយ ៗ ជាបកតូបនិស្សយប្បច្ច័យ ដល់កាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ។

កុ.២១ ចេ.៣៨ → កាយ.វិញ្ញាណ.២ ចេ.៧ ផលចិត្ត.៤ ចេ.៣៦

( ៣ ) កុសលំ កម្មំ វិបាកស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

កុសលកម្មក្នុងភូមិ ៤ ជាបច្ច័យនៃកុសលវិបាកចិត្ត ២៩ ចេតសិក ៣៨ ដោយបកតូបនិស្សយប្បច្ច័យ មាននានាក្ខណិកកម្មប្បច្ច័យជាបច្ច័យសភាគៈ ។

កុ.២១ ចេ.៣៨ → កុ.វិ.២៩ ចេ.៣៨ ( ដោយអភិធម្មន័យ )

កុ.២១ ចេ.៣៨ → កុ.វិ.២៩ ចេ.៣៨ កម្មជរូប ២០ (ដោយសុត្តន្តន័យ) ។

( ៤ ) អរហា មគ្គំ ឧបនិស្សាយ អនុប្បន្នំ កិរិយសមាបត្តិំ ឧប្បាទេតិ ឧប្បន្នំ សមាបជ្ជតិ សង្ខារេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។

ព្រះអរហន្ត អាស្រ័យអរហត្តមគ្គដែលខ្លួនបានហើយ ធ្វើឈាន-សមាបត្តិ ដែលមិនទាន់កើត ឲ្យកើតឡើង កាលឈានកើតឡើងហើយ ក៏ពិចារណាសង្ខារទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា ។

**អរហត្តមគ្គ ១ ចេ.៣៦ ⟶ មហគ្គតកិ.៩ ចេ.៣៥**

**អរហត្តមគ្គ ១ ចេ.៣៦ ⟶ មហាកិរិយា ៨ ចេ.៣៣**

**( ៥ ) មគ្គោ អរហតោ អត្ថប្បដិសម្ភិទាយ ធម្មប្បដិសម្ភិទាយ និរុត្តិប្បដិសម្ភិទាយ បដិភាណប្បដិសម្ភិទាយ ឋានាឋានកោសលស្ស បកតូបនិស្សយប្បច្ចយេន បច្ចយោ ។**

អរហត្តមគ្គរបស់ព្រះអរហន្ត ជាបច្ច័យនៃបដិសម្ភិទា ៤ និងសេចក្តីឆ្លាតឈ្លាសក្នុងហេតុដែលសមគួរ និងមិនសមគួរ ដោយបក-តូបនិស្សយប្បច្ច័យ ។

**អរហត្តមគ្គ ១ ចេ.៣៦ ⟶ អត្ថប្បដិសម្ភិទា**

**( បញ្ញាចេតសិក ) ក្នុងអរហត្តផល និង មហាកិរិយាញាណសម្បយុត្តចិត ៤ ដួង , បដិសម្ភិទា ៣ ទៀត ព្រម ព្រមទាំងឋានាឋានញ្ញាណ ប្រព្រឹត្តទៅក្នុង មហាកិរិយាញាណសម្បយុត្តចិត្ត ៤ ដួង ។**



**( ៦ ) មគ្គោ ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

មគ្គ ជាបច្ច័យនៃផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

មគ្គ ៤ ជាបច្ច័យដល់ផលសមាបត្តិ ដោយបកតូបនិស្សយ-ប្បច្ច័យ មាននានក្ខណិកកម្មប្បច្ច័យជាសភាគៈ ។

**មគ្គចិត្ត ៤ ចេ.៣៦ ⟶ ផលសមាបត្តិ ៤ ចេ.៣៦**

## បញ្ហាវារៈទី ៤

អកុសលោ ធម្មោ អកុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

អកុ. ⟶ អកុ.

( ១ ) រាគំ ឧបនិស្សាយ

រាគៈជាទីអាស្រ័យដ៏មានកម្លាំង ( ជាបច្ច័យដល់ )

បាណំ ហនតិ = សម្លាប់សត្វ ។

អទិន្នំ អាទិយតិ = យកទ្រព្យ ដែលគេមិនបានឲ្យ ។

មុសា ភណតិ = និយាយកុហក ។

បិសុណំ ភណតិ = និយាយញុះញង់ ។

ផរុសំ ភណតិ = និយាយពាក្យអាក្រក់ ។

សម្ផំ បលបតិ = និយាយពាក្យរោយរាយ ។

សន្ធឹ ឆិន្ទតិ = កាត់ទី.ត ។

និល្លោបំ ហរតិ = លបចក់ទ្រព្យគេ ។

ឯកាគារិកំ ករោតិ = ប្លន់យកទ្រព្យក្នុងផ្ទះគេមួយខ្នង ។

បរិបន្ថេ តិដ្ឋតិ = ឈរចាំដណ្តើមទ្រព្យគេតាមផ្លូវ ។

បរទារំ គច្ឆតិ = លួចភរិយាអ្នកដទៃ ។

គាមឃាតំ ករោតិ = សម្លាប់អ្នកស្រុក ។

និគមឃាតំ ករោតិ = សម្លាប់អ្នកនិគម ។



មាតរំ ជីវិតា វោរោបេតិ = ផ្តាច់បង់ជីវិតមាតា ។

បិតរំ ជីវិតា វោរោបេតិ = ផ្តាច់បង់ជីវិតបិតា ។

អរហន្តំ ជីវិតា វោរោបេតិ = ផ្តាច់បង់ជីវិតព្រះអរហន្ត ។

ទុដ្ឋេន ចិត្តេន តថាគតស្ស លោហិតំ ឧប្បាទេតិ = ញុំាង ព្រះលោហិតព្រះតថាគតឲ្យពុរពង ដោយទោសចិត្ត ។

សង្ឃំ ភិន្ទតិ = បំបែកសង្ឃ ។

( ២ ) ទោសំ ឧបនិស្សាយ ... មោហំ ... មានំ ... ទិដ្ឋឹ ... បត្ថនំ ... ឧបនិស្សាយ បាណំ ហនតិ ។ល។ សង្ឃំ ភិន្ទតិ ។

បុគ្គលអាស្រ័យទោសៈ មោហៈ មានៈ ទិដ្ឋិ និងសេចក្តីប្រាថ្នា ក្នុងភវសម្បត្តិ ភោគសម្បត្តិ ហើយធ្វើការសម្លាប់សត្វ ។ល។ បំបែកសង្ឃ ។

អកុ.១២ ចេ.២៧ ⟶ អកុ.១២ ចេ.២៧

( ៣ ) រាគោ រាគស្ស ទោសស្ស មោហស្ស មានស្ស ទិដ្ឋិយា បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ ទោសោ ... មោហោ ...

**មានោ ... ទិដ្ឋិ ... បត្ថនា ។**

*រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្ដីប្រាថ្នា ជាបច្ច័យដល់រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ និងសេចក្ដីប្រាថ្នា ដោយឧបនិស្សយប្បច្ច័យ ។*

**អកុ.១២ ចេ.២៧ ⟶ អកុ.១២ ចេ.២៧**

**( ៤ ) បាណាតិបាតោ បាណាតិបាតស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។ បាណាតិបាតោ អទិន្នាទានស្ស ... កាមេ សុមិច្ឆារស្ស ... មុសាវាទស្ស ... បិសុណា វាចាយ ... ផរុស វាចាយ ... សម្ផប្បលាបស្ស ... អភិជ្ឈាយ ... ព្យាបាទស្ស ... មិច្ឆាទិដ្ឋិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

*ការសម្លាប់សត្វ ជាបច្ច័យដល់ការសម្លាប់សត្វ លួចទ្រព្យ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក ។ល។ ដោយឧបនិស្សយប្បច្ច័យ ។*

**ទោសៈ.២ មោហៈ.២ ចេ.២៣ ដែលទាក់ទងនឹងការសម្លាប់សត្វ**

**⟶ អកុ.១២ ចេ.២៧ ( គឺ អកុសលកម្មបទ ១០ ) ។**



**( ៥ ) អទិន្នាទានំ អទិន្នាទានស្ស ... កាមេសុមិច្ឆាចារោ ... មុសាវាទោ ... បិសុណាវាចា ... ផរុសវាចា ... សម្ផប្បលាបោ ... អភិជ្ឈា ... ព្យាបាទោ ... មិច្ឆាទិដ្ឋិ ។**

**អកុ.១២ ចេ.២៧ ដែលទាក់ទងនឹងអទិន្នាទាន**

**⟶**

**អកុសលកម្មបទ ១០ គឺ អកុ.១២ ចេ.២៧**

**( ៦ ) មាតុឃាតកម្មំ មាតុឃាតកម្មស្ស ឧបនិស្សយប្ប-ច្ចយេន បច្ចយោ មាតុឃាតកម្មំ បិតុឃាតកម្មស្ស អរហន្ត-ឃាតកម្មស្ស រុហិរុប្បាទកម្មស្ស សង្ឃភេទកម្មស្ស និយតមិច្ឆាទិដ្ឋិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។**

*មាតុឃាតកម្ម ជាបច្ច័យដល់មាតុឃាត បិតុឃាត អរហន្តឃាត លោហិតុប្បាទ សង្ឃភេទ និងនិយតមិច្ឆាទិដ្ឋិណាមួយ ដោយឧបនិ-ស្សយប្បច្ច័យ ។*

**ទោស.២ ចេ.២២ ដែលទាក់ទងនឹងមាតុឃាត**

**⟶ បញ្ចានន្តរិយកម្ម និងនិយតមិច្ឆាទិដ្ឋិ**

**( តាមសមគួរនៃតួបច្ច័យ ) ។**

( ៧ ) បិតុឃាតកម្មំ ។ល។ អរហន្តឃាតកម្មំ ។ល។ រុហិរុប្បាទកម្មំ ។ល។ សង្ឃភេទកម្មំ ។ល។ និយតមិច្ឆាទិដ្ឋិ ។ល។ ចក្កំ កាតព្វំ ។ គប្បីធ្វើជាចក្កផងចុះ ។

## បញ្ហាវារៈទី ៥

អកុសលោ ធម្មោ កុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន

បច្ចយោ ។

អកុ. ⟶ កុ.

( ១ ) រាគំ ឧបនិស្សាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ឈានំ ឧប្បាទេតិ វិបស្សនំ ឧប្បាទេតិ មគ្គំ ឧប្បាទេតិ អភិញ្ញំ ឧប្បាទេតិ សមាបត្តឹ ឧប្បាទេតិ ។

បុគ្គលអាស្រ័យរាគៈ រមែងឲ្យទាន សមាទានសីល រក្សាឧបោសថ ធ្វើឈាន វិបស្សនា មគ្គ អភិញ្ញា សមាបត្តិ ឲ្យកើតឡើង ។

លោភ.៨ ចេ.២២ ⟶ កុ.២១ ចេ.៣៨

ទោសំ ។ល។ មោហំ ។ល។ មានំ ។ល។ ទិដ្ឋឹ ។ល។ បត្ថនំ ។



ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្តីប្រាថ្នា ជាបច្ច័យដល់ ទាន សីល ឧបោសថ ឈាន វិបស្សនា មគ្គ អភិញ្ញា សមាបត្តិ ។

អកុ.១២ ចេ.២៧ ⟶ កុ.២១ ចេ.៣៨

អន្តធម៌ខាងលើ អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ជាបច្ច័យនៃកុសលចិត្ត ២១ ដួង ចេតសិក ៣៨ ដោយបកតូបនិ-ស្សយប្បច្ច័យ ។

( ២ ) រាគោ សទ្ធាយ សីលស្ស សុតស្ស ចាគស្ស បញ្ញាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។ ទោសោ ។ល។ មោហោ ។ល។ មានោ ។ល។ ទិដ្ឋិ ។ល។ បត្ថនា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

រាគៈ ជាបច្ច័យដល់សទ្ធា សីល សុតៈ ចាគ បញ្ញា
ដោយឧបនិស្សយប្បច្ច័យ ។

អកុ.១២ ចេ.២៧ ⟶ កុ.២១ ចេ.៣៨

( ៣ ) បាណំ ហន្ត>ា តស្ស បដិឃាតត្ថាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ឈានំ ឧប្បាទេតិ វិបស្សនំ ឧប្បាទេតិ មគ្គំ ឧប្បាទេតិ អភិញ្ញំ ឧប្បាទេតិ សមាបត្តឹ ឧប្បាទេតិ ។

បុគ្គលសម្លាប់សត្វ ហើយឲ្យទាន រក្សាសីលជាដើម រហូតដល់ធ្វើសមាបត្តិឲ្យកើតឡើង

អទិន្នំ អាទិយិត្វា ... មុសា ភណិត្វា ... បិសុណំ ភណិត្វា ... ផរុសំ ភណិត្វា ... សម្ផំ បលបិត្វា ... សន្ធឹ ឆិន្ទិត្វា ... និល្លោបំ ហរិត្វា ... ឯកាគារិកំ ករិត្វា ... បរិបន្ថេ ឋត្វា ... បរទារំ គន្ត>ា ... គាមឃាតំ ករិត្វា ... និគមឃាតំ ករិត្វា តស្ស បដិឃាតត្ថាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ឈានំ ឧប្បាទេតិ វិបស្សនំ ឧប្បាទេតិ មគ្គំ ឧប្បាទេតិ អភិញ្ញំ ឧប្បាទេតិ សមាបត្តឹ ឧប្បាទេតិ ។

អកុ.១២ ចេ.២៧ ⟶ កុ.២១ ចេ.៣៨

( ៤ ) មាតរំ ជីវិតា វោរោបេត្វា តស្ស បដិឃាតត្ថាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ។ បិតរំ ជីវិតា វោរោបេត្វា ។ល។ អរហន្តំ ជីវិតា វោរោបេត្វា ។ល។ ទុដ្ឋេន ចិត្តេន តថាគតស្ស ។ល។ លោហិតំ ឧប្បាទេត្វា ។ល។ សង្ឃំ ភិន្ទិត្វា តស្ស បដិឃាតត្ថាយ ទានំ ទេតិ សីលំ សមាទិយតិ ឧបោសថកម្មំ ករោតិ ។



បុគ្គលធ្វើបញ្ចានន្តរិយកម្មហើយ រមែងឲ្យទាន សមាទានសីល រក្សាឧបោសថ ដើម្បីប្រយោជន៍ដល់ការឃាត់នូវផលនៃកម្មនោះ ។

ទោសចិត្ត.២ ចេ.២២ ⟶ មហាកុ.៨ ចេ.៣៨

## បញ្ហាវារៈទី ៦

អកុសលោ ធម្មោ អព្យាកតស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

អកុ.១២ ចេ.២៧ ⟶ អព្យា.៥៦ ចេ.៣៨

### បាលីអនុវាទ

( ១ ) រាគំ ឧបនិស្សាយ អត្តានំ អាតាបេតិ បរិតាបេតិ បរិយិដ្ឋិមូលកំ ទុក្ខំ បច្ចនុភោតិ ។ ទោសំ ... មោហំ ... មានំ ... ទិដ្ឋឹ ... បត្ថនំ ឧបនិស្សាយ អត្តានំ អាតាបេតិ បរិតាបេតិ បរិយិដ្ឋិមូលកំ ទុក្ខំ បច្ចនុភោតិ ។

បុគ្គលអាស្រ័យរាគៈ ហើយធ្វើខ្លួនឯងឲ្យក្តៅ ឲ្យក្តៅសព្វ នឹងត្រូវសោយទុក្ខតាមផ្លូវកាយ ដោយការស្វែងរកជាមូល ។ អាស្រ័យ

ទោសៈ ... មោហៈ ... មានះ ... ទិដ្ឋិ ... បត្ថនៈ ។ល។

អកុ.១២ ចេ.២៧ ⟶ កាយិកទុក្ខ ចេ.៧

( ២ ) រាគោ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។ រាគោ ... ទោសោ ... មោហោ ... មានោ ... ទិដ្ឋិ ... បត្ថនា កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ សេចក្ដីប្រាថ្នា ជាបច្ច័យនៃសេចក្ដីសុខកាយ សេចក្ដីទុក្ខកាយ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

អកុ.១២ ចេ.២៧ ⟶ កាយវិ.២ ចេ.៧ ផលចិត្ត ៤ ចេ.៣៦ ។

( ៣ ) អកុសលំ កម្មំ វិបាកស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។



អកុសលកម្មដែលមានកម្លាំងទាំងក្នុងភពនេះ និងភពមុន ជាបច្ច័យឲ្យកើតអកុសលវិបាក ដោយឧបនិស្សយប្បច្ច័យ ។

អកុ.១២ ចេ.២៧ ⟶ អកុ.វិបាក.៧ ចេ.១០

## បញ្ហាវារៈទី ៧

អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស បកតូបនិស្សយប្បច្ចយេន បច្ចយោ ។

អព្យាកតធម៌ ជាបច្ច័យនៃអព្យាកតធម៌ ដោយបកតូបនិស្សយប្បច្ច័យ ។

អព្យា.៥៦ ចេ.៣៨ រូប.២៨ ⟶ អព្យា.៥៦ ចេ.៣៨

### បាលីអនុវាទ

( ១ ) កាយិកំ សុខំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។

- កាយិកំ ទុក្ខំ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ... ។ល។

សេចក្ដីសុខកាយ ជាបច្ច័យនៃកាយិកសុខ កាយិកទុក្ខ និងផលសមាបត្តិ ដោយឧបនិស្សយប្បច្ច័យ ។

កាយវិ.២ ចេ.៧ ⟶ កាយវិ.២ ចេ.៧ ផលចិត្ត.៤ ចេ.៣៦ ។

( ២ ) ឧតុ កាយិកស្ស សុខស្ស កាយិកស្ស ទុក្ខស្ស ផលសមាបត្តិយា ឧបនិស្សយប្បច្ចយេន បច្ចយោ ។ ភោជនំ ។ល។ សេនាសនំ ។ល។

( ៣ ) កាយិកំ សុខំ ... កាយិកំ ទុក្ខំ ... ឧតុ ... ភោជនំ ... សេនាសនំ ...

( ទាំង ៥ នេះ ជាបច្ច័យតែម្យ៉ាង ឯចំណែកបច្ចយុប្បន្នៈ ដូចចំណុចទី ១ និងទី ២ ដែរ គឺ មាន ៣ បានដល់ កាយិកសុខ ១ , កាយិកទុក្ខ ១ និងផលសមាបត្តិ ១ ) ។

( ៤ ) ផលសមាបត្តិ កាយិកស្ស សុខស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ ។

ផលសមាបត្តិ ជាបច្ច័យដល់សុខកាយ ដោយឧបនិស្សយប្បច្ច័យ ។



ផលសមាបត្តិ ⟶ សុខកាយ.វិ ១ ចេ.៧

( ៥ ) អរហា កាយិកំ សុខំ កាយិកំ ទុក្ខំ ឧតុ ... ភោជនំ ... សេនាសនំ ... អនុប្បន្នំ កិរិយាសមាបត្តឹ ឧប្បាទេតិ ឧប្បន្នំ សមាបជ្ជតិ សង្ខារេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។

ព្រះអរហន្ត អាស្រ័យសេចក្តីសុខកាយ ទុក្ខកាយ ឧតុ ភោជន សេនាសនៈ ហើយធ្វើឈានសមាបត្តិ ដែលនៅមិនទាន់កើត ឲ្យកើតឡើង កាលឈានកើតហើយ ក៏ពិចារណាសង្ខារទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា ។

កាយ.វិ ២ ចេ.៧ ឧតុ. ភោជន. សេនាសនៈ.

⟶

មហគ្គតកិរិយា ៩ មហាកិរិយា ៨ ចេ.៣៥

## សរុបបច្ច័យ និងបច្ចយុប្បន្នៈនៃ បញ្ហាវារៈទី ៧

បច្ច័យ = វិបាកចិត្ត ៣៦ ដួង , កិរិយាចិត្ត ២០ ដួង ចេតសិក ៣៨ និងរូប ២៨ ។

បច្ចយុប្បន្នៈ = វិបាកចិត្ត ៣៦ ដួង , កិរិយាចិត្ត ២០ ដួង
ចេតសិក ៣៨ ។

## បញ្ហាវារៈទី ៨

អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន
បច្ចយោ ។

អព្យា. ⟶ កុ.

( ១ ) កាយិកំ សុខំ កាយិកំ ទុក្ខំ ឧតុ ... ភោជនំ ... សេនាសនំ ... ឧបនិស្សាយ ទានំ ទេតិ ។ល។

( ២ ) កាយិកំ សុខំ ។ល។ សេនាសនំ សទ្ធាយ សីលស្ស សុតស្ស ចាគស្ស បញ្ញាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

បញ្ហាវារៈទី ៨ នេះ មាន ៖-

បច្ច័យ = រូប ២៨ វិបាកចិត្ត ៣៥ ដួង ( វៀរអរហត្ត-
ផល ) ឬ ៣៦ កិរិយាចិត្ត ២០ ដួង ចេត-
សិក ៣៨ ។

បច្ចយុប្បន្នៈ = កុសលចិត្ត កុសលចេតសិកទាំងអស់ ។



## បញ្ហាវារៈទី ៩

អព្យាកតោ ធម្មោ អកុសលស្ស ធម្មស្ស ឧបនិស្សយប្បច្ចយេន
បច្ចយោ ។

អព្យា. ⟶ អកុ.

( ១ ) កាយិកំ សុខំ ។ល។ ឧតុ ... ភោជនំ ... សេនាសនំ ... ឧបនិស្សាយ បាណំ ហនតិ ។ល។ សង្ឃំ ភិន្ទតិ ។

( ២ ) កាយិកំ សុខំ ។ល។ ឧតុ ... ភោជនំ ... សេនាសនំ ... រាគស្ស ទោសស្ស មោហស្ស មានស្ស ទិដ្ឋិយា បត្ថនាយ ឧបនិស្សយប្បច្ចយេន បច្ចយោ ។

- អង្គធម៌ ដូចក្នុងវិភង្គវារៈខាងដើម ។

### ឧបនិស្សយប្បច្ច័យ ២៣ វារៈ គឺ ៖

<u>១. កុសលបទ :</u> មាន ៨ វារៈ

កុ. ⟶ កុ. មាន ៣ វារៈ

-ដោយអារម្មណូ ១ វារៈ

-ដោយអនន្តរូ ១ វារៈ

-ដោយបកតូ ១ វារៈ

កុ. → អកុ. មាន ២ វារៈ

-ដោយអារម្មណូ ១ វារៈ

-ដោយបកតូ ១ វារៈ

កុ. → អព្យា. មាន ៣ វារៈ

-ដោយអារម្មណូ ១ វារៈ

-ដោយអនន្តរូ ១ វារៈ

-ដោយបកតូ ១ វារៈ

**<u>២. អកុសលបទ :</u>** **មាន ៦ វារៈ**

អកុ. → អកុ. មាន ៣ វារៈ

-ដោយអារម្មណូ ១ វារៈ

-ដោយអនន្តរូ ១ វារៈ

-ដោយបកតូ ១ វារៈ

អកុ. → កុ. មាន ១ វារៈ

-ដោយបកតូ ១ វារៈ

អកុ. → អព្យា. មាន ២ វារៈ

-ដោយអនន្តរូ ១ វារៈ



-ដោយបកតូ ១ វារៈ

**<u>៣. អព្យាកតបទ :</u>** **មាន ៩ វារៈ**

អព្យា. → អព្យា. មាន ៣ វារៈ

អព្យ. → កុ. មាន ៣ វារៈ

អព្យា. → អកុ. មាន ៣ វារៈ

---

## ១០. បុរេជាតប្បច្ច័យ

**មាន ២ បច្ច័យ គឺ ៖**

**១. វត្ថុបុរេជាតប្បច្ច័យ**

**២. អារម្មណបុរេជាតប្បច្ច័យ**

- នៅក្នុងដីកា មានថែម**វត្ថារម្មណបុរេជាតប្បច្ច័យ** ១ ទៀតផង ។ ប៉ុន្តែក្នុងអដ្ឋកថាពុំមាននូវបច្ច័យទី ៣ នេះឡើយ ព្រោះជាអារម្មណ-បុរេជាតប្បច្ច័យហ្នឹងឯង ។ វត្ថុបុរេជាតប្បច្ច័យមានអន្តធម៌ និងបញ្ហាវារៈ

ជាដើម ដូចគ្នានឹងវត្ថុបុរេជាតនិស្សយប្បច្ច័យទាំងអស់ ។

## អារម្មណបុរេជាតប្បច្ច័យ

| | | |
|---|---|---|
| **បច្ច័យ** | = | និប្ផន្នរូប ឬសភាវរូប ១៨ ដែលកើតមុន ហើយស្ថិតនៅក្នុងឋិតិខណៈ ។ |
| **បច្ចយុប្បន្នៈ** | = | ជាឯកន្តៈ បានដល់ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ ចេតសិក ១០ ។ ដែលជាអនេកន្តៈ បានដល់ កាមចិត្តក្នុងមនោទ្វារ ៤១ ដួង ( គឺ មនោទ្វារាវជ្ជនៈ ១ , កាមជវន ២៩ , តទាលម្ពណចិត្ត ១១ ដួង , ចិត្ត ៤១ ដួងនេះ បើកើតតាមបញ្ចទ្វារ ក៏ជាឯកន្តៈផងដែរ ) អភិញ្ញាជវន ២ ដួង ចេតសិក ៥០ ( វៀរអប្បមញ្ញា ២ ) ។ |
| **បច្ចនិកៈ** | = | ជាឯកន្តៈ បានដល់ មហគ្គតចិត្ត ២៧ ( វៀរអភិញ្ញា ២ ដួង ) លោកុត្តរចិត្ត ៨ ដួង ចេតសិក ៣៨ និង អប្បមញ្ញា ២ ក្នុងកាមចិត្ត រូបទាំងអស់ ឬរូបទាំង |



៧ ពួក ។ ដែលជាអនេកន្តៈ បានដល់ អនេកន្តៈក្នុងបច្ចយុប្បន្នៈហ្នឹងឯង ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ គឺ មានលក្ខណៈ ២ , **១. អារម្មណៈ** ជាទីតោង ជាទីរីករាយ , **២. បុរេជាត** កើតមុន ។

ដោយជាតិ គឺ អារម្មណជាតិ ។

ដោយកាល គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ គឺ សត្តិទាំង ២ ។

### បញ្ហាវារៈ មាន ៣

### បញ្ហាវារៈទី ១

អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

អព្យា. ⟶ អព្យា.

( ១ ) អរហា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ។ សោតំ ... ឃានំ ... ជិវ្ហំ ... កាយំ ... រូបេ ... សទ្ទេ ... គន្ធេ ... រសេ ... ផោដ្ឋព្វេ ... វត្ថុំ ... ។ល។

ឱឡារិករូប ១២ និងហទយវត្ថុរូប ⟶ មហាកិ.៨ ចេ.៣៣

( ២ ) ទិព្វេន ចក្ខុនា រូបំ បស្សតិ ។

រូបារម្មណ៍ ⟶ អភិញ្ញាកិ.១ ចេ.៣០ ដែលជាទិព្វចក្ខុ

( ៣ ) ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ។

សទ្ទារម្មណ៍ ⟶ អភិញ្ញាកិ.១ ចេ.៣០ ដែលជាទិព្វសោត

( ៤ ) រូបាយតនំ ចក្ខុវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។ល។ ផោដ្ឋព្វាយតនំ កាយវិញ្ញាណស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

បញ្ចារម្មណ៍ ⟶ ទ្វិបញ្ចវិញ្ញាណ.១០ ចេ.៧

## សរុបអង្គធម៌

| | | |
|---|---|---|
| បច្ច័យ | = | សភាវរូប ១៨ ក្នុងឋិតិខណៈ ។ |
| បច្ចយុប្បន្នៈ | = | កាមាវចរវិបាកចិត្ត ២៣ ដួង , កាមាវចរកិរិយាចិត្ត ១១ ដួង , អភិញ្ញាកិរិ- |



យាចិត្ត ១ ដួង , ចេតសិក ៣៣ ។

## បញ្ហាវារៈទី ២

អព្យាកតោ ធម្មោ កុសលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ។

( ១ ) សេក្ខា វា បុថុជ្ជនា វា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ ផោដ្ឋព្វេ វត្ថុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សន្តិ ។

ព្រះសេក្ខបុគ្គល ឬបុថុជ្ជន ពិចារណាចក្ខុបសាទ ... កាយបសាទ , រូបា- រម្មណ៍ ... ផោដ្ឋព្វារម្មណ៍ និងហទយវត្ថុ ថា អនិច្ចំ ទុក្ខំ អនត្តា ។

| | | |
|---|---|---|
| បច្ច័យ | = | វត្ថុរូប ៦ និងគោចររូប ៧ ។ |
| បច្ចយុប្បន្នៈ | = | មហាកុសលចិត្ត ៨ ដួង ចេតសិក ៣៣ ដែលជា កុសល ថ្នាក់វិបស្សនា ។ |

( ២ ) ទិព្វេន ចក្ខុនា រូបំ បស្សន្តិ ។

ព្រះសេក្ខបុគ្គល ឬបុថុជ្ជន រមែងឃើញរូបដោយទិព្វចក្ខុ ។

រូបារម្មណ៍ជាបច្ចុប្បន្ន ⟶ អភិញ្ញាកុ.១ ចេ.៣០
ដែលជាទិព្វចក្ខុ ។

( ៣ ) ទិព្វាយ សោតធាតុយា សទ្ទំ សុណាតិ ។

ព្រះសេក្ខបុគ្គល ឬបុថុជ្ជន រមែងបានឮសំឡេងដោយទិព្វសោត ។

សទ្ទារម្មណ៍ជាបច្ចុប្បន្ន ⟶ អភិញ្ញាកុ.១ ចេ.៣០
ដែលជាទិព្វសោត ។

### សរុបអត្ថធម៌

បច្ច័យ = សភាវរូប ១៨ ក្នុងឋិតិខណៈ ។

បច្ចយុប្បន្នៈ = មហាកុសលចិត្ត ៨ ដួង , អភិញ្ញាកុសល ១ ដួង ចេតសិក ៣៣ , វិរតិមានក្នុងកាលដ៏សមគួរ កើតក្នុងមហាកុសល វៀរចាករូបដែលកើតពីអកុសល ។

## បញ្ហាវារៈទី ៣

អព្យាកតោ ធម្មោ អកុសលស្ស ធម្មស្ស បុរេជាតប្បច្ចយេន បច្ចយោ ។



អព្យា. ⟶ អកុ.

ចក្ខុំ អស្សាទេតិ អភិនន្ទតិ តំ អារព្ភ រាគោ ឧប្បជ្ជតិ ទិដ្ឋិ ... វិចិកិច្ឆា ... ឧទ្ធច្ចំ ... ទោមនស្សំ ... ។ សោតំ ។ល។ វត្ថុំ ។ល។

### សរុបអត្ថធម៌

បច្ច័យ = សភាវរូប ១៨ ក្នុងឋិតិខណៈ ។

បច្ចយុប្បន្នៈ = អកុសលចិត្ត ១២ ដួង ចេតសិក ២៧ ។

## ១១. បច្ឆាជាតប្បច្ច័យ

បច្ឆាជាតា ចិត្តចេតសិកា ធម្មា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ ។

ពួកចិត្តចេតសិកធម៌ដែលកើតក្រោយ , ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ ។

**បច្ច័យ** = ចិត្ត ៨៥ ដួង ( វៀរអរូបវិបាក ៤ និង បដិសន្ធិទាំងអស់ ) ចេតសិក ៥២ ក្នុង ឧប្បាទខណៈ និងឋិតិខណៈ ដែលកើត ក្រោយបច្ចយុប្បន្នធម៌ ក្នុងបញ្ចវោការ-ភព ។

**បច្ចយុប្បន្នៈ** = រូបកាយ មាន៣ សមុដ្ឋាន នៅព្រហ្ម-លោក និងរូបកាយ មានសមុដ្ឋានទាំង ៤ តាមលំដាប់ ចាប់ពីបដិសន្ធិមក នៅក្នុងកាមភពនេះ ដែលជាឋិតិខណៈ ។

**បច្ចនិកៈ** = ចិត្ត ៨៩ ដួង ចេតសិក ៥២ , ឧប្បាទខណៈនៃរូប ៥ ពួក គឺ ចិត្តជរូប , បដិសន្ធិកម្មជរូប , បវត្តិកម្មជរូប , ឧតុជរូប និងអាហារជរូប , រូបពីរពួកទៀត គឺ ពាហិររូប និងអសញ្ញសត្តរូប ។ រូបដែលកើតឡើង ក្នុងខណៈទាំងបីនៃ ចុតិចិត្ត រូបដែលកើតក្នុងខណៈទាំងបី ( ខណៈចិត្តតូច ) នៅវសញ្ញានាសញ្ញា-



យតនចិត្ត ខណៈចិត្តធំទីពីរ មុននឹងចូលនិរោធសមាបត្តិ រូបដែលកើតក្នុងនិរោធ-សមាបត្តិ ហើយរលត់ទៅមុនផលចិត្តកើតឡើង ឬរលត់ដំណាលគ្នានឹងផល-ចិត្តកើត ។

+ បរិច្ឆេទរូប គ្រាន់តែជាទីចន្លោះនៃកលាបៈរូប ។
+ វិញ្ញត្តិរូប ២ ជារូបប្រព្រឹត្តទៅតាមចិត្ត ។
+ ឧបចយរូប និងសន្តតិរូប រូបទាំងពីរនេះ ជាជាតិរូប គឺ ជាឧប្បាទខណៈនៃសភាវរូបហ្នឹងឯង ។
+ អនិច្ចតារូប គឺ ជាភង្គខណៈនៃសភាវរូប ។

**រូបទាំងនេះ សុទ្ធតែជាបច្ឆាជាតប្បច្ចនិកៈទាំងអស់ ។**

## ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ បច្ឆាជាតលក្ខណៈ ។

ដោយជាតិ = គឺ បច្ឆាជាតជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ ឧបត្ថម្ភកសត្តិ តែម្យ៉ាង ។

## បញ្ហាវារៈ មាន ៣

កុ. → អព្យា ,
អកុ. → អព្យា. ,
អព្យា. → អព្យា.

---

## ១២. អាសេវនប្បច្ច័យ

៧ ? ៧

( ១ ) បុរិមា បុរិមា កុសលា ធម្មា បច្ឆិមានំ បច្ឆិមានំ កុសលានំ ធម្មានំ អាសេវនប្បច្ចយេន បច្ចយោ ។

( ២ ) អកុ. → អកុ.

( ៣ ) កិរិយា → កិរិយា

**បច្ច័យ** = ជវនចិត្ត ៤៧ ដួង ( លោកិយកុសលចិត្ត១៧ ដួង អកុសលចិត្ត ១២ ដួង កិរិយាជវន-



ចិត្ត ១៨ ដួង ) ចេតសិក ៥២ វៀរជវនចុង ចុងក្រោយ ដែលមានជាតិ ដូចគ្នា ។

**បច្ចយុប្បន្នៈ** = ជវនចិត្ត ៥១ ដួង ( វៀរផលចិត្ត ៤ ) ចេត-សិក ៥២ ( វៀរកាមជវនចិត្ត ២៩ ដួង ក្នុង ខណៈទី ១ ) ។

**បច្ចនិកៈ** = កាមជវនចិត្ត ២៩ ដួង ក្នុងខណៈទី ១ អហេតុកកិរិយាចិត្ត ២ ដួង ( វៀរហសិតុប្បាទ ) វិបាកចិត្ត ៣៦ ដួង ចេតសិក ៥២ និងរូប ទាំងអស់ ។

**កំណត់ចំណាំ :** អាសេវនប្បច្ច័យ ចំពោះតែជវន ៣ ជាតិ តែប៉ុណ្ណោះ បច្ច័យ និងបច្ចយុប្បន្នៈ ត្រូវមានជាតិដូចគ្នា ទោះជា អារម្មណ៍ផ្សេងគ្នា និងភូមិផ្សេងគ្នា ( ក្នុងមគ្គវីថិ ) ក៏បាន ។

មហាកុសលញាណវិប្បយុត្ត ជាបច្ច័យនៃមហាកុសលញាណ-វិប្បយុត្តតែម៉្យាង , មហាកុសលញាណសម្បយុត្ត ជាបច្ច័យនៃមហា-កុសលញាណសម្បយុត្ត ក៏មាន ។

មហាកុសលគូទី ១ ( ញាណសម្បយុត្តប្រកបដោយសោម-

នស្ស ) ជាបច្ច័យដល់ឈានចិត្ត និងមគ្គចិត្ត ប្រកបដោយសោមនស្ស (បឋមជ្ឈានដល់ចតុត្ថជ្ឈាន ) ក៏មាន ។

មហាកុសលគូទី ៣ ( ញាណសម្បយុត្តប្រកបដោយឧបេក្ខា ) ជាបច្ច័យដល់ឈានចិត្ត និងមគ្គចិត្ត ប្រកបដោយឧបេក្ខា ( បញ្ចមជ្ឈានជវន រូប , អរូប , មគ្គ ) ។

\+ មហគ្គតកុសល ជាបច្ច័យនៃមហគ្គតកុសលតែម្យ៉ាង ។

\+ លោកុត្តរកុសល មិនជាបច្ច័យឡើយ ។

\+ អកុសល ជាបច្ច័យនៃអកុសលតាមជួរនៃជវនតែម្យ៉ាង ។

\+ មហាកិរិយាញាណវិប្បយុត្ត ឬញាណសម្បយុត្ត ជាបច្ច័យទំនងដូចមហាកុសលដែរ គ្រាន់តែមិនជាបច្ច័យដល់មគ្គ ដូចមហាកុសលញាណសម្បយុត្តឡើយ ។

\+ មហគ្គតកិរិយា ជាបច្ច័យនៃមហគ្គតកិរិយាតែម្យ៉ាង ។

\+ ហសិតុប្បាទៈ ជាបច្ច័យនៃហសិតុប្បាទៈតែម្យ៉ាង ។

\+ វិបាកទាំងអស់ មិនមែនជាបច្ច័យ ទាំងមិនមែនជាបច្ចយុប្បន្នៈ ព្រោះគ្រាន់តែជាវិបាកនៃកម្ម មិនបានសេពនូវកម្លាំងគ្នាកើតឡើងឡើយ ព្រោះអាសេវនៈ ប្រែថា សេពរឿយ ៗ ។



## ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ គឺ អាសេវនលក្ខណៈ មានការសេពនូវអារម្មណ៍រឿយ ៗ ក្នុងជវនវីថិជាមួយគ្នា ជាលក្ខណៈ ។

ដោយជាតិ គឺ អនន្តរជាតិ ។

ដោយកាល គឺ អតីតកាល ។

ដោយសត្តិ គឺ ជនកសត្តិតែម្យ៉ាង ។

## បញ្ហាវារៈ មាន ៣

កុ. → កុ.

អកុ. → អកុ.

កិ. → កិ.

## ១៣. កម្មប្បច្ច័យ

**១- កុសលាកុសលំ កម្មំ វិបាកានំ ខន្ធានំ កដត្តា ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

កុសលចេតនា ២១ និងអកុសលចេតនា ១២ ដែលជាអតីត: គឺ កន្លងទៅហើយ ជាបច្ច័យនៃវិបាកនាមក្ខន្ធ ៤ បានដល់ វិបាកចិត្ត ៣៦ ដួង ចេតសិក ៣៨ ។ ចេតនា ២៥ ( ១២ + ៨ + ៥ ) ជាបច្ច័យនៃបដិសន្ធិកម្មជរូប , បវត្តិកម្មជរូប និងអសញ្ញសត្តកម្មជរូប តាមសមគួរដល់កម្មជាបច្ច័យ ។

**( ១ )** តិហេតុកឧក្កដ្ឋមហាកុសលចេតនា ជាបច្ច័យនៃអហេតុកកុសលវិបាកចិត្តុប្បាទ ៨ ដួង , មហាវិបាកចិត្តុប្បាទ ៨ ដួង ។ កាមសុគតិតិហេតុកបដិសន្ធិកម្មជរូប ២០ និងបវត្តិឥដ្ឋកម្មជរូប ។

**( ២ )** តិហេតុកឱមកមហាកុសលចេតនា ៤ និងទ្វិហេតុកឧក្កដ្ឋមហាកុសលចេតនា ៤ ជាបច្ច័យនៃអហេតុកកុសលវិបាកចិត្តុប្បាទ ៨ និងមហាវិបាកញាណវិប្បយុត្តចិត្តុប្បាទ ៤ ។ កាមសុគតិទុហេតុកបដិសន្ធិកម្មជរូប ២០ និងបវត្តិឥដ្ឋកម្មជរូប ២០ ។

**( ៣ )** ទុហេតុកឱមកមហាកុសលចេតនា ៤ ជាបច្ច័យនៃ



អហេតុកកុសលវិបាកចិត្តុប្បាទ ៨ ដួង ។ កាមសុគតិអហេតុកបដិសន្ធិកម្មជរូបតាមសមគួរ និង បវត្តិឥដ្ឋកម្មជរូប ។

**( ៤ )** រូបជ្ឈានចេតនា ៥ ជាបច្ច័យនៃរូបាវចរវិបាក ធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិ ក្នុងរូបភូមិតាមសមគួរ និងបដិសន្ធិកម្មជរូប បវត្តិកម្មជរូប អសញ្ញសត្តកម្មជរូប ។

**( ៥ )** អរូបជ្ឈានចេតនា ៤ ជាបច្ច័យនៃអរូបាវចរវិបាកចិត្តុប្បាទ ៤ ដួង ធ្វើកិច្ចបដិសន្ធិ ភវង្គ ចុតិក្នុងអរូបភូមិតាមសមគួរ ។

**( ៦ )** មគ្គចេតនា ៤ ជាបច្ច័យនៃផលចិត្តុប្បាទ ៤ ដួង ក្នុងមគ្គវីថិ និងក្នុង ផលសមាបត្តិវីថិ តាមសមគួរ ។

**( ៧ )** អកុសលចេតនា ១២ ជាបច្ច័យនៃអកុសលវិបាកចិត្តុប្បាទ ៧ ដួង អបាយបដិសន្ធិកម្មជរូប តាមសមគួរ ( វៀរមោហឧទ្ធច្ចសម្បយុត្តចេតនា ព្រោះមិនជាបច្ច័យនៃបដិសន្ធិ ) បវត្តិអនិដ្ឋកម្មជរូប ។

**២- ចេតនាសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ កម្មប្បច្ចយេន បច្ចយោ ។**

ប្រែ : ចេតនាក្នុងចិត្ត ៨៩ ដួង ជាបច្ច័យដល់ចិត្ត ៨៩ ដួង

ចេតសិក ៥១ ( វៀរចេតនា ) និងបដិសន្ធិកម្មជរូប ២០ ចិត្តជរូប ១៧ ដោយសហជាតកម្មប្បច្ច័យ ។

## នានក្ខណិកកម្មប្បច្ច័យ

**បច្ច័យ** = ចេតនា ៣៣ គឺ កុសលាកុសលចេតនា ( ២១+១២ ) ដែលជាអតីតៈ គឺ អតីតៈ នៃបច្ចយុប្បន្នៈ ។

**បច្ចយុប្បន្នៈ** = វិបាកចិត្ត ៣៦ ដួង ចេតសិក ៣៨ និង រូប ៣ ពួក គឺ បដិសន្ធិកម្មជរូបបវត្តិ-កម្មជរូប និងអសញ្ញសត្តកម្មជរូប ។

**បច្ចនិកៈ** = កុសលចិត្ត ២១ ដួង អកុសលចិត្ត ១២ ដួង កិរិយាចិត្ត ២០ ដួង ចេតសិក ៥២ និងរូប ៤ ពួក គឺ ចិត្តជរូប ពាហិររូប ឧតុជរូប អាហារជរូប ។

**ដោយលក្ខណៈ មាន ២ គឺ ៖**

**នានក្ខណៈ** បានដល់ បច្ច័យក្នុងខណៈផ្សេងអំពីខណៈនៃ បច្ចយុប្បន្នៈ ( បច្ច័យជាអតីតនៃបច្ចយុប្បន្នៈ ) និង **កម្ម** ជាលក្ខណៈ



មួយទៀត ដែលមានកិច្ចជាពូជ ក្នុងការញ៉ាំងផលឲ្យកើតឡើងជាខាង ក្រោយ ។

- **ដោយជាតិ :** ជានានក្ខណិកកម្មជាតិ ។
- **ដោយកាល :** ជាអតីតកាល ។
- **ដោយសត្តិ :** ជាជនកសត្តិ តែម្យ៉ាង ។

## បញ្ហាវារៈមាន ២

កុ. ⟶ អព្យា.

អកុ. ⟶ អព្យា.

## អនន្តរនានក្ខណិកកម្មប្បច្ច័យ

**នានក្ខណិកកម្មជាត** មានពីរប្រការ ៖

( ១ ) បកតូបនិស្សយនានក្ខណិកកម្មជាតិ ។

( ២ ) អនន្តរបកតូនិស្សយនានក្ខណិកកម្មជាតិ ។

**អនន្តរនានក្ខណិកកម្មប្បច្ច័យ** មានអង្គធម៌ គឺ ៖

**បច្ច័យ** = មគ្គចេតនា ៤ ។

**បច្ចយុប្បន្នៈ** = ផលចិត្ត ៤ ដួង ចេតសិក ៣៦ ក្នុង

មគ្គវីថិ ១ ខណៈ បន្ទាប់អំពីមគ្គ ។

**បច្ចនិកៈ** = កុសលចិត្ត ២១ ដួង អកុសលចិត្ត ១២ ដួង លោកិយវិបាកចិត្ត ៣២ កិរិយា-ចិត្ត ២០ ចេតសិក ៥២ និងរូបទាំងប្រាំពីរពួក ។

## បញ្ហាវារៈមាន ១

កុ. ⟶ អព្យា.

## បច្ច័យយជនា

( រួមបច្ច័យ ) មាន ៧

១. នានក្ខណិកកម្មប្បច្ច័យ ( បច្ច័យប្រធាន ) ។

២. អនន្តរប្បច្ច័យ , ៣. សមនន្តរប្បច្ច័យ , ៤. អនន្ត-រូបនិស្សយប្បច្ច័យ , ៥. បកតូបនិស្សយប្បច្ច័យ , ៦. នត្ថិប្បច្ច័យ , ៧. វិគតប្បច្ច័យ ។

( ប្រាំមួយបច្ច័យខាងក្រោយនេះ ជាបច្ច័យសភាគៈ )



## សហជាតកម្មប្បច្ច័យ

**បច្ច័យ** = ចេតនាក្នុងចិត្ត ៨៩ ដួង ស្ថិតនៅជាបច្ចុប្បន្ន កើតស្មើគ្នានឹងបច្ចយុប្បន្នៈ ។

**បច្ចយុប្បន្នៈ** = ចិត្ត ៨៩ ដួង ចេតសិក ៥១ ( វៀរចេតនា ) បដិសន្ធិកម្មជរូប ២០ និងចិត្តជរូប ១៧ ។

**បច្ចនិកៈ** = ចេតនា ៨៩ ដួង រូបប្រាំពួក ( វៀររូបពីរពួក ដែលជាបច្ចយុប្បន្នៈ ) ។

**ដោយលក្ខណៈមាន ២ គឺ ៖**

១. សហជាតកម្មប្បច្ច័យ , ២. នានក្ខណិកកម្មប្បច្ច័យ ។

ដោយជាតិ : គឺ សហជាតជាតិ ។

ដោយកាល : គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ : គឺ ដោយសត្តិទាំងពីរ ។

## បញ្ហាវារៈមាន ៧

( កុសលោ ធម្មោ កុសលស្ស ធម្មស្ស សហជាតកម្មប្បច្ចយេន បច្ចយោ )

| | |
|---|---|
| ១. កុ. ⟶ កុ. | ៤. អកុ. ⟶ អកុ. |
| ២. កុ. ⟶ អព្យា. | ៥. អកុ. ⟶ អព្យា. |
| ៣. កុ. ⟶ កុ. + អព្យា. | ៦. អកុ. ⟶ អកុ. + អព្យា. |

៧. អព្យា. ⟶ អព្យា.

---

## ១៤. វិបាកប្បច្ច័យ

**វិបាកា ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញំ វិបាកប្បច្ចយេន បច្ចយោ ។**

វិបាកនាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយវិបាកប្បច្ច័យ ។

\+ **ក្នុងបញ្ហាវារៈ** មានបដិសន្ធិកម្មជរូប និងចិត្តជរូប ជាបច្ចយុប្បន្នធម៌ផង ដែរ ។

**បច្ច័យ** = វិបាកចិត្ត ៣៦ ដួង ចេតសិក ៣៨ ( ១ , ៣ , ២ ) ។

**បច្ចយុប្បន្នៈ** = វិបាកចិត្ត ៣៦ ដួង ចេតសិក ៣៨ ( ៣ , ១ , ២ ) និងបដិសន្ធិកម្មជរូប ២០ , ចិត្តជរូប ១៥ ( វៀរ វិញ្ញត្តិរូប ២ ) ។



**បច្ចនិកៈ** = កុសលចិត្ត ២១ ដួង អកុសលចិត្ត ១២ កិរិយាចិត្ត ២០ ( រួម ៥៣ ) ចេតសិក ៥២ ចិត្តជរូបដែលមាន ចិត្ត ៥៣ ដួង ( វៀរវិបាកចិត្ត ) ជាសមុដ្ឋាន ពាហិររូប ឧតុជរូប អាហារជរូប អសញ្ញសត្តកម្មជរូប បវត្តិកម្មជរូប ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈតែម្យ៉ាង គឺ ជាផលដែលកម្មបានចំអិនហើយ ។

ដោយជាតិ គឺ សហជាតជាតិ ។

ដោយកាល គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ គឺ សត្តិទាំងពីរ ។

**បញ្ហាវារៈ មាន ១**

អព្យា. ⟶ អព្យា

---

## ១៥. អាហារប្បច្ច័យ

**( ១ ) កពលិង្ការោ អាហារោ ឥមស្ស កាយស្ស អាហារប្បច្ចយេន បច្ចយោ ។**

កវលិង្ការាហារ ( អាហារជ្ជឱជា ) ជាបច្ច័យនៃកាយនេះ ដោយអាហារប្បច្ច័យ ។

**( ២ ) អរូបិនោ អាហារា សម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ អាហារប្បច្ចយេន បច្ចយោ ។**

នាមអាហារ ៣ គឺ ផស្សាហារ ១ , មនោសញ្ចេតនាហារ ១ និងវិញ្ញាណាហារ ១ ក្នុងចិត្ត ៨៩ ដួង ជាបច្ច័យដល់សម្បយុត្តធម៌ និងបដិសន្ធិកម្មជ្ជរូប ចិត្តជ្ជរូប ។

### អាហារប្បច្ច័យដែលជារូប

**<u>ន័យទី ១</u> :**

**បច្ច័យ** = ពហិទ្ធឱជា ដែលជាកវលិង្ការាហារ បានដល់អាហារខាងក្រៅ ដែលបរិភោគលេបចូលទៅ ។

**បច្ចយុប្បន្ន:** = អាហារជ្ជរូប ។

**បច្ចនិក:** = ចិត្ត ៨៩ ដួង ចេតសិក ៥២ និងរូប ៦



ពួកទៀត វៀរអាហារជ្ជរូប ។

**<u>ន័យទី ២ :</u>**

**បច្ច័យ** = ចតុសមុដ្ឋានិកឱជា ដែលជាខាងក្នុង និងពហិទ្ធឱជា ( ឧតុជ្ជឱជាខាងក្រៅ ) ។

**បច្ចយុប្បន្ន:** = ចតុសមុដ្ឋានិករូប ដែលជារូបកលាប:កើតរួមជាមួយនឹងបច្ច័យ ព្រមទាំងកលាបរូបដទៃទៀត និងចតុសមុដ្ឋានិករូបទាំងអស់ ដែលអាស្រ័យពហិទ្ធឱជា ។

**បច្ចនិក:** = ចិត្ត ៨៩ ដួង ចេតសិក ៥២ និងពហិទ្ធរូប ។

### ដោយលក្ខណ: ជាតិ កាល សត្តិ

ដោយលក្ខណ: = រូបអាហារនាំមកនូវអាហារជ្ជរូប ជាលក្ខណ: ។

ដោយជាតិ = រូបអាហារជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ ជនកសត្តិ និងឧបត្ថម្ភកសត្តិ ឬជនកសត្តិ និងអនុបាលកសត្តិ ។

### នាមាហារប្បច្ច័យ និងសហជាតាហារប្បច្ច័យ

**បច្ច័យ** = ផស្ស:ក្នុងចិត្ត ៨៩ ដួង , ចេតនាក្នុងចិត្ត ៨៩ ដួង និងចិត្ត ៨៩ ដួង ( ផស្សាហារ ១ ,

មនោសញ្ចេតនាហារ ១ និងវិញ្ញាណាហារ ១ ) ។

**បច្ចយុប្បន្ន** = ចិត្ត ៨៩ ដួង ចេតសិក ៥២ បដិសន្ធិកម្ម-ជរូប ២០ និងចិត្តជរូប ១៧ ។

**បច្ចនិកៈ** = រូប ៥ ពួក ( វៀរ រូបដែលជាបច្ចយុប្បន្ន ) ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ នាំមកនូវផល ជារូបធម៌ និងនាមធម៌ ជាលក្ខណៈ ។

ដោយជាតិ = គឺ សហជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ សត្តិទាំងពីរ ( ជនកកិច្ច + ឧបត្ថម្ភកកិច្ច ) ។

### បញ្ហាវារៈមាន ៧

( ដូចជា ហេតុប្បច្ច័យ )

<u>កុសលបទ</u> :

កុ. ⟶ កុ. , កុ. ⟶ អព្យា , កុ. ⟶ កុ. + អព្យា.

<u>អកុសលបទ</u> :

អកុ. ⟶ អកុ. , អកុ. ⟶ អព្យា , អកុ. ⟶ អកុ.+អព្យា.



<u>អព្យាកតបទ</u> :

អព្យា. ⟶ អព្យា.

---

## ១៦. ឥន្ទ្រិយប្បច្ច័យ

( ១ ) ចក្ខុន្ទ្រិយំ ចក្ខុវិញ្ញាណធាតុយា តំសម្បយុត្តកានញ្ច ធម្មានំ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

- សោតិន្ទ្រិយំ ។ល។ កាយិន្ទ្រិយំ ...... ។ល។

( ២ ) រូបជីវិតិន្ទ្រិយំ កដត្តារូបានំ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

( ៣ ) អរូបិនោ ឥន្ទ្រិយា សម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ ឥន្ទ្រិយប្បច្ចយេន បច្ចយោ ។

## បុរេជាតិន្ទ្រិយប្បច្ច័យ

**បច្ច័យ** = បសាទរូប ៥ ក្នុងឋិតិខណៈ ។

**បច្ចយុប្បន្ន:** = ទ្វិបញ្ចវិញ្ញាណ ១០ ចេតសិក ៧ ។

**បច្ចនិក:** = ចិត្ត ៨៩ ដួង ( វៀរទ្វិបញ្ចវិញ្ញាណ ១០ ) ចេតសិក ៥២ និងរូបទាំង ៧ ពួក ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = មាន ២ គឺ

១. បុរេជាតលក្ខណៈ មានលក្ខណៈកើតមុន ។

២. ឥន្ទ្រិយលក្ខណៈ ជាធំក្នុងការគ្រប់គ្រងទៅតាមនាទីរបស់ខ្លួន ។

ដោយជាតិ = គឺ វត្ថុបុរេជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ សត្តិទាំងពីរ ជនកសត្តិ និងឧបត្ថម្ភកសត្តិ ។

### បញ្ហាវារៈ មាន ១

អព្យា. ⟶ អព្យា.



**អព្យាកតោ ធម្មោ អព្យាកតស្ស ធម្មស្ស បុរេជាតិឥន្ទ្រិយប្បច្ចយេន បច្ចយោ ។**

## រូបជីវិតិន្ទ្រិយប្បច្ច័យ

**បច្ច័យ** = រូបជីវិតិន្ទ្រិយ គ្រប់កលាបរូបមានកម្មាំងជាបច្ច័យ អនុបាលរក្សានូវសហជាតរូប ក្នុងឋិតិខណៈ ។

**បច្ចយុប្បន្ន:** = រូបនៅក្នុងកលាបៈ ៩ រូប ឬ ៨ រូប ។

**បច្ចនិក :** = ចិត្ត ចេតសិកទាំងអស់ រូបទាំងអស់ក្រៅអំពីរូបដែលជាបច្ចយុប្បន្នៈ ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ រូបលក្ខណៈ ១ , ឥន្ទ្រិយលក្ខណៈ ១ ។

ដោយជាតិ = គឺ រូបជីវិតិន្ទ្រិយជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ អនុបាលកសត្តិ តែម៉្យាង ។

### បញ្ហាវារៈមាន ១

អព្យា. ⟶ អព្យា.

## សហជាតិន្ទ្រិយប្បច្ច័យ

**បច្ច័យ** = អត្ថធម៌ ៨ គឺ ជីវិតិន្ទ្រិយចេតសិក ១ ក្នុងចិត្តទាំងអស់ , មនិន្ទ្រិយ ១ ចិត្តទាំងអស់ , វេទ- និន្ទ្រិយ វេទនាទាំងអស់ , សទ្ធិន្ទ្រិយ ១ សទ្ធា ទាំងអស់ , វីរិយិន្ទ្រិយ ១ , សតិន្ទ្រិយ ១ , សមាធិន្ទ្រិយ ១ ឯកគ្គតាចេតសិក ( វៀរឯក-គ្គតាក្នុងចិត្ត ១៧ គឺ ចិត្ត ១៦ មិនមានវីរិយៈ និងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ) និងបញ្ញិន្ទ្រិយ ១ បញ្ញាទាំងអស់ ។

**បច្ចយុប្បន្នៈ** = ចិត្ត ចេតសិកទាំងអស់ និងបដិសន្ធិកម្មជ-រូប ២០ ចិត្តជរូប ១៧ ។

**បច្ចនិកៈ** = រូប ៥ ពួក មានពាហិររូប ជាដើម ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ ជាសហជាតលក្ខណៈ ១ និងជាឥន្ទ្រិយលក្ខណៈ ១ ។

ដោយជាតិ = គឺ សហជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។



ដោយសត្តិ = គឺ សត្តិទាំង ២ ។

### បញ្ហាវារៈមាន ៧

<u>កុសលបទ :</u>

កុ. → កុ. , កុ. → អព្យា. , កុ. → កុ.+ អព្យា.

<u>អកុសលបទ :</u>

អកុ. → អកុ. , អកុ. → អព្យា. , អកុ. → អកុ.+អព្យា.

<u>អព្យាកតបទ :</u>

អព្យា. → អព្យា.

### ក្នុងឥន្ទ្រិយ ២២

- ឥន្ទ្រិយ ២០ ( វៀរ ភាវរូប ២ ) ជាឥន្ទ្រិយប្បច្ច័យ ។

\+ ឥន្ទ្រិយ ២២ ចែកជា ៖-

- កុសលសុទ្ធ មាន ១ គឺ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ។
- អកុសលសុទ្ធ មាន ១ គឺ ទោមនស្សិន្ទ្រិយ ។
- អព្យាកតសុទ្ធ មាន ១០ គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជិវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , សុខិន្ទ្រិយ ,

ទុក្ខិន្ទ្រិយ , ឥត្ថិន្ទ្រិយ , បុរិសិន្ទ្រិយ និងអញ្ញាតាវិន្ទ្រិយ ( គឺបញ្ញា-ចេតសិកក្នុងអរហត្តផល ) ។

- ជាកុសលផង អព្យាកតផង មាន ៤ គឺ សទ្ធិន្ទ្រិយ , សតិន្ទ្រិយ , បញ្ញិន្ទ្រិយ , អញ្ញិន្ទ្រិយ ។

- ជាកុសលផង អកុសលផង អព្យាកតផង មាន ៦ គឺ មនិន្ទ្រិយ , សោមនស្សិន្ទ្រិយ , ឧបេក្ខិន្ទ្រិយ , វីរិយិន្ទ្រិយ , សមាធិន្ទ្រិយ និងជីវិតិន្ទ្រិយ ។

**+ ចែកជាលោកិយៈ និងលោកុត្តរៈ**

**- ជាលោកិយ មាន ១០** គឺ ចក្ខុន្ទ្រិយ , សោតិន្ទ្រិយ , ឃានិន្ទ្រិយ , ជិវ្ហិន្ទ្រិយ , កាយិន្ទ្រិយ , បុរិសិន្ទ្រិយ , ឥត្ថិន្ទ្រិយ , ទុក្ខិន្ទ្រិយ , សុខិន្ទ្រិយ , ទោមនស្សិន្ទ្រិយ ។

**- ជាលោកុត្តរៈ មាន ៣** គឺ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ , អញ្ញិន្ទ្រិយ , អញ្ញាតាវិន្ទ្រិយ ។

**- ជាលោកិយៈផង ជាលោកុត្តរៈផង មាន ៩** គឺ សោមន-ស្សិន្ទ្រិយ , ឧបេក្ខិន្ទ្រិយ , មនិន្ទ្រិយ , ជីវិតិន្ទ្រិយ , សទ្ធិន្ទ្រិយ , សតិន្ទ្រិយ , វីរិយិន្ទ្រិយ , សមាធិន្ទ្រិយ និងបញ្ញិន្ទ្រិយ។

---



## ឈានប្បច្ច័យ

**ឈានង្គានិ ឈានសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ ឈានប្បច្ចយេន បច្ចយោ ។**

**បច្ច័យ = ឈានង្គានិ** អង្គឈានមាន ៧ គឺ ៖

១. វិតក្ក បដិបក្ខនឹង ថីនមិទ្ធៈ

២. វិចារៈ បដិបក្ខនឹង វិចិកិច្ឆា

៣. បីតិ បដិបក្ខនឹង ព្យាបាទៈ

៤. សោមនស្ស បដិបក្ខនឹង ឧទ្ធច្ចកុក្កុច្ចៈ

៥. ទោមនស្ស បដិបក្ខនឹង បីតិ + សោមនស្ស

៦. ឧបេក្ខា បដិបក្ខនឹង ឧទ្ធច្ចកុក្កុច្ចៈ+ទោមនស្ស

៧. ឯកគ្គតា បដិបក្ខនឹង កាមច្ឆន្ទៈ

ក្នុងអត្ថន័យខាងលើនេះ **ឈាន** ប្រែថា **ដុត** ។ ក្នុងមហា-កុសល គឺ ដុតអកុសលដែលជាបដិបក្ខ ដោយតទង្គប្បហាន , ជាមហគ្គតៈ ដុតបដិបក្ខ ដោយវិក្ខម្ភនប្បហាន , ជាលោកុត្តរៈ ដុតបដិបក្ខ ដោយសមុច្ឆេទប្បហាន ។ បើអង្គឈាន ជាអកុសល ក៏ដុតបំផ្លាញនូវកុសលធម៌វិញផងដែរ ។

ន័យម្យ៉ាងទៀត **ឈាន** ប្រែថា **សំឡឹងនូវអារម្មណ៍** សំឡឹង

អារម្មណ៍ធម្មតាក្តី សំឡឹងដោយសមថកម្មដ្ឋានទៅក្នុងកសិណជាដើម ក្តី សំឡឹងក្នុងលក្ខណៈជាបរមត្ថក្តី ការសំឡឹងទាំងអស់នេះ ហៅថា **ឈាន** ។

ការសំឡឹងអារម្មណ៍ រួមមកមាន ២ គឺ ៖

១. អារម្មណូបនិជ្ឈាន ។

២. លក្ខណូបនិជ្ឈាន ( វិបស្សនា , មគ្គ , ផល ) ។

## អង្គធម៌

១. វិតក្ក ដែលកើតក្នុងចិត្ត ៥៥ ដួង ។

២. វិចារៈ ដែលកើតក្នុងចិត្ត ៦៦ ដួង ។

៣. បីតិ ដែលកើតក្នុងចិត្ត ៥១ ដួង ។

៤. សោមនស្ស ដែលកើតក្នុងចិត្ត ៦២ ដួង ។

៥. ទោមនស្ស ដែលកើតក្នុងចិត្ត ២ ដួង គឺ ទោសមូលចិត្ត។

៦. ឧបេក្ខា ដែលកើតក្នុងចិត្ត ៤៧ ដួង ( វៀរចក្ខុវិញ្ញាណ ២ , សោតវិញ្ញាណ ២ , ឃានវិញ្ញាណ ២ និង ជិវ្ហាវិញ្ញាណ ២ ) ។

៧. ឯកគ្គតា ដែលកើតក្នុងចិត្ត ៧៩ ដួង ( វៀរទ្វិបញ្ចវិញ្ញាណ ១០ ) ។

**បច្ចយុប្បន្នៈ = ឈានសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានា-**



**នញ្ច រូបានំ ។**

បានដល់ ចិត្ត ៧៩ ដួង ( វៀរទ្វិបញ្ចវិញ្ញាណ ១០ ) ចេតសិក ៥២ បដិសន្ធិកម្មជរូប ២០ និងចិត្តជរូប ១៧ ។ ( **បច្ចនិកៈ** ទ្វិបញ្ចវិញ្ញាណ ១០ ចេតសិក ៧ និងរូប ៥ ពួក ) ។

**ឈានប្បច្ចយេន បច្ចយោ** = បានដល់ ឈានប្បច្ច័យ ដែលជាប្រធាន និងបច្ច័យ ១០ ទៀត រួមឧបការៈដល់បច្ចយុប្បន្នៈ ជាមួយនឹងឈានប្បច្ច័យ គឺ ៖

១. សហជាតប្បច្ច័យ , ២. អញ្ញមញ្ញប្បច្ច័យ , ៣. សហជាតនិស្សយប្បច្ច័យ , ៤. វិបាកប្បច្ច័យ , ៥. សហជាតិន្ទ្រិយប្បច្ច័យ , ៦ . មគ្គប្បច្ច័យ , ៧. សម្បយុត្តប្បច្ច័យ , ៨. សហជាតវិប្បយុត្តប្បច្ច័យ , ៩. សហជាតត្ថិប្បច្ច័យ , ១០. សហជាតអវិគតប្បច្ច័យ ។

## ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ នាំសហជាតធម៌ ឲ្យសំឡឹងទៅក្នុងអារម្មណ៍ ឬដុតនូវធម៌ដែលជាបដិបក្ខ ( **ឈាន** ) ជាលក្ខណៈ ។

ដោយជាតិ = គឺ សហជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ សត្តិទាំង ២ ។

## បញ្ហាវារៈមាន ៧

<u>កុសលបទ :</u>

កុ. ⟶ កុ. , កុ. ⟶ អព្យា. , កុ. ⟶ កុ.+អព្យា

<u>អកុសលបទ :</u>

អកុ. ⟶ អកុ. , អកុ. ⟶ អព្យា. , អកុ. ⟶ អកុ.+អព្យា.

<u>អព្យាកតបទ :</u>

អព្យា. ⟶ អព្យា.

---

## ១៨. មគ្គប្បច្ច័យ

**មគ្គង្គានិ មគ្គសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ មគ្គប្បច្ចយេន បច្ចយោ ។**

*អង្គមគ្គទាំងឡាយ ជាបច្ច័យដល់ធម៌ដែលកើតជាមួយអង្គមគ្គ និងរូប ដោយ មគ្គប្បច្ច័យ ។*



**មគ្គង្គានិ** ជាបច្ច័យ បានដល់ អង្គមគ្គ ១២ មានអង្គធម៌ ៩ គឺ៖

១. **ទិដ្ឋិ** ជាសម្មាទិដ្ឋិ កើតក្នុងចិត្ត ៤៧ ដួង , ជាមិច្ឆាទិដ្ឋិ កើតក្នុងលោភមូលចិត្ត ៤ ដួង ។

២. **វិតក្ក** កើតក្នុងចិត្ត ៤៧ ដួង ( វៀរអហេតុកចិត្ត ៨ ដួង ) ។

៣. **វិរតិ ៣** កើតក្នុងចិត្ត ១៦ ដួង គឺ មហាកុសលចិត្ត ៨ ដួង លោកុត្តរចិត្ត ៨ ដួង ។

៤. **វីរិយ** កើតក្នុងចិត្ត ៧១ ( វៀរវីរិយៈកើតក្នុងអហេតុកចិត្ត ២ ) ។

៥. **សតិ** កើតក្នុងសោភណចិត្ត ៥៩ ដួង ( វៀរអសោភណចិត្ត ៣០ ) ។

៦. **ឯកគ្គតា** កើតក្នុងចិត្ត ៧០ ដួង ( វៀរអហេតុកចិត្ត ១៨ និងវិចិកិច្ឆាសម្បយុត្តចិត្ត ) ។

\+ **ជាកុសល** មានអង្គមគ្គ ៨ ( វៀរអង្គមគ្គ ដែលជាទិដ្ឋិចេតសិក ) ។

\+ **ជាអកុសល** មានអង្គមគ្គ ៤ គឺ ទិដ្ឋិ ១ , វិតក្ក ១ , វីរិយៈ ១ , ឯកគ្គតា ១ ។

**+ ជាអព្យាកត** មានអង្គមគ្គ ៨ ដូចកុសលដែរ ។

អង្គមគ្គ មានអង្គធម៌ ៩ គឺ ៖

ទិដ្ឋិចេតសិក ១ , បញ្ញា ១ , វិតក្ក ១ , វិរតិ ៣ , វិរិយៈ ១ , សតិ ១ និងឯកគ្គតា ១ ។

### មគ្គសម្បយុត្តកានំ ធម្មានំ តំសមុដ្ឋានានញ្ច រូបានំ

គឺជាបច្ចយុប្បន្នៈ បានដល់ សហេតុកចិត្ត ៧១ ដួង និង ចេតសិកសម្បយុត្ត ៥២ សហេតុកចិត្តជរូប ១៧ សហេតុកបដិសន្ធិ-កម្មជរូប ២០ ( **បច្ចនិក:** គឺ អហេតុកចិត្ត ១៨ ដួង ចេតសិក ១២ ( វៀរ ឆន្ទៈ ) អហេតុកចិត្តជរូប ១៧ អហេតុកចិត្តបដិសន្ធិកម្មជរូប ២០ និងរូប ៥ ពួកទៀត ) ។

ក្នុងបដិសន្ធិកាល : មានអង្គមគ្គ ៥ ឬ ៤ , អង្គមគ្គ ៥ គឺ បញ្ញា ១ , វិតក្ក ១ , វិរិយៈ ១ , សតិ ១ , ឯកគ្គតា ១ ។ ឯអង្គមគ្គ ៤ ក៏ត្រូវវៀរបញ្ញា ១ ឬត្រូវវៀរវិតក្ក ១ ( វៀរ បញ្ញា ព្រោះជាទុហេតុកបដិសន្ធិ,ដែលមិនមានវិតក ព្រោះបដិសន្ធិដោយទុតិយ-ជ្ឈានវិបាកឡើងទៅ ) ។

**មគ្គប្បច្ចយេន បច្ចយោ** សម្ដែងដល់បច្ច័យ ដែលមានឧប-



ការៈដល់បច្ចយុប្បន្នៈ ក្នុងពេលតែមួយ ១៣ បច្ច័យ មានមគ្គប្បច្ច័យ ជាប្រធាន ។

**បច្ច័យ ១៣ គឺ ៖**

១ ហេតុប្បច្ច័យ , ២ សហជាតធិបតិប្បច្ច័យ , ៣ សហជា-តប្បច្ច័យ , ៤ អញ្ញមញ្ញប្បច្ច័យ , ៥ សហជាតនិស្សយប្បច្ច័យ , ៦ វិបាកប្បច្ច័យ , ៧ សហជាតិន្ទ្រិយប្បច្ច័យ , ៨ ឈានប្បច្ច័យ , ៩ មគ្គប្បច្ច័យ , ១០ សម្បយុត្តប្បច្ច័យ , ១១ សហជាតវិប្ប-យុត្តប្បច្ច័យ , ១២ សហជាតត្ថិប្បច្ច័យ , ១៣ សហជាតអវិគតប្បច្ច័យ តាមសមគួរ ។

### ដោយលក្ខណៈ ជាតិ កាល សត្តិ

ដោយលក្ខណៈ = គឺ មគ្គលក្ខណៈ ជាផ្លូវទៅកាន់ទុគ្គតិ សុគតិ និងនិព្វាន ( ផ្លូវទៅកាន់ទុគ្គតិ សុគតិ មាន នានក្ខណិកកម្មជាសំខាន់ ចំណែកជាមគ្គដែល នាំទៅកាន់ព្រះនិព្វាន សំខាន់ត្រង់មគ្គអង្គ ៨ ) ។ អង្គមគ្គក្នុងទីនេះ ដោយត្រង់ គឺ មគ្គ នាំសម្ប-យុត្តធម៌ទៅកាន់អារម្មណ៍ និងនាំឲ្យសម្រេចជា កម្ម ដោយកាយកម្ម វចីកម្ម មនោកម្ម ។

ដោយជាតិ = គឺ សហជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ សត្តិទាំង ២ ។

## បញ្ហាវារៈមាន ៧

<u>**កុសលបទ :**</u>

កុ. ⟶ កុ. , កុ. ⟶ អព្យា. , កុ. ⟶ កុ.+អព្យា

<u>**អកុសលបទ :**</u>

អកុ. ⟶ អកុ. , អកុ. ⟶ អព្យា. , អកុ. ⟶ អកុ.+អព្យា.

<u>**អព្យាកតបទ :**</u>

អព្យា. ⟶ អព្យា.



## ១៩. សម្បយុត្តប្បច្ច័យ

**ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញំ សម្បយុត្តប្បច្ចយេន បច្ចយោ ។**

នាមក្ខន្ធ ៤ ជាបច្ច័យដល់គ្នានឹងគ្នា ដោយសម្បយុត្តប្បច្ច័យ ។

**ចត្តារោ ខន្ធា អរូបិនោ** = គឺ បច្ច័យ បានដល់ ចិត្ត ៨៩ ដួង ចេតសិក ៥២ ចែកជាខន្ធ ៤ គឺ ខន្ធ ១ ជាបច្ច័យដល់ខន្ធ ៣ , ខន្ធ៣ ជាបច្ច័យដល់ខន្ធ ១, ខន្ធ ២ ជាបច្ច័យនៃខន្ធ ២ ។

**អញ្ញមញ្ញំ** = គឺ ជាបច្ចយុប្បន្នធម៌ បានដល់ ចិត្ត ៨៩ ដួង ចេតសិក ៥២ ( រូបទាំងអស់ ជាបច្ចនិកៈ ) ។

**សម្បយុត្តប្បច្ចយេន បច្ចយោ** = សម្ដែងដល់បច្ច័យ ដែលជាឧបការៈដល់បច្ចយុប្បន្នៈ មាន ៦ បច្ច័យ ឬ ៧ បច្ច័យ មានសម្បយុត្តប្បច្ច័យជាប្រធាន ។

**៦ បច្ច័យ ក្នុងចិត្តដែលមិនមែនជាវិបាក គឺ** ១. សម្បយុត្តប្បច្ច័យ , ២. សហជាតប្បច្ច័យ , ៣. អញ្ញមញ្ញ , ៤. សហជាតនិស្សយប្បច្ច័យ , ៥. សហជាតត្ថិប្បច្ច័យ , ៦. សហជាតអវិគតប្បច្ច័យ ។ បើក្នុងវិបាក- ចិត្ត ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល មានវិបាកប្បច្ច័យមួយ

ទៀត ជាគម្រប់ ៧ ។

**ដោយលក្ខណៈ ជាតិ កាល សត្តិ**

ដោយលក្ខណៈ = គឺ មានការប្រកបជាមួយគ្នាយ៉ាងជិតស្និទ្ធ ហាក់ដូចតែមួយ មានការកើត.រលត់ជាមួយគ្នា ដឹងអារម្មណ៍ជាមួយគ្នា បើក្នុងបញ្ចវោការភព អាស្រ័យវត្ថុជាមួយគ្នាទៀតផង ពួកធម៌នេះ ហៅថា សារម្មណធម្មា " ធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិក មានអារម្មណ៍ ឬដឹងអារម្មណ៍ " ។

ដោយជាតិ = គឺ សហជាត ជាតិ ។

ដោយកាល = គឺ បច្ចុប្បន្នកាល ។

ដោយសត្តិ = គឺ សត្តិ ទាំងពីរ ។

**បញ្ហាវារៈមាន ៣**

កុ. ⟶ កុ. អកុ. ⟶ អកុ. អព្យា. ⟶ អព្យា.

---



## ២០. វិប្បយុត្តប្បច្ច័យ

**១-រូបិនោ ធម្មា អរូបីនំ ធម្មានំ វិប្បយុត្តប្បច្ចយេន បច្ចយោ ។**

**២-អរូបិនោ ធម្មា រូបីនំ ធម្មានំ វិប្បយុត្តប្បច្ចយេន បច្ចយោ ។**

ក្នុងចំណុចទី ១ :

**រូបិនោ ធម្មា** បានដល់ រូបធម៌ជាបច្ច័យ គឺ សហជាតវិប្បយុត្តប្បច្ច័យ ១ និងវត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ ១ ។

**អរូបិនំ ធម្មានំ** បានដល់ បច្ចយុប្បន្នធម៌ នៃបច្ច័យទាំង ២ ។

**វិប្បយុត្តប្បច្ចយេន បច្ចយោ** ដោយបច្ច័យ ៦ មានវិប្បយុត្តប្បច្ច័យជាប្រធាន ។

ក្នុង ៦ បច្ច័យនេះ មានសហជាតវិប្បយុត្តប្បច្ច័យ ១ , បច្ច័យសភាគៈមាន ៥ គឺ ១. សហជាតប្បច្ច័យ , ២. អញ្ញមញ្ញប្បច្ច័យ ៣. សហជាតនិស្សយប្បច្ច័យ , ៤. សហជាតត្ថិប្បច្ច័យ , ៥. សហជាតអវិគតប្បច្ច័យ ។

វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ ចែកជា ២ បច្ច័យ គឺ ១. បុរេជាតវិប្បយុត្តប្បច្ច័យ , ២. វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ ។

បុរេជាតវិប្បយុត្តប្បច្ច័យ មានបច្ច័យសភាគៈ ៤ បច្ច័យ គឺ ៖

១. វត្ថុបុរេជាតនិស្សយ , ២. បុរេជាត , ៣. បុរេជាតត្ថិ , ៤. បុរេ-ជាតអវិគត ។

បើបច្ច័យជាបញ្ចវត្ថុ **បច្ចយុប្បន្ន:** គឺ ទ្វិបញ្ចវិញ្ញាណ ត្រូវថែមបច្ច័យសភាគ: ១ ទៀត គឺ បុរេជាតិន្ទ្រិយ ។

វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ មានបច្ច័យសភាគ: ៥ បច្ច័យ គឺ ១. អារម្មណប្បច្ច័យ , ២. វត្ថារម្មណបុរេជាតនិស្សយ , ៣. វត្ថារម្មណបុរេជាត , ៤. វត្ថារម្មណបុរេជាតត្ថិ , ៥. វត្ថារម្មណបុរេជា- តអវិគត ។

បើក្នុងមរណាសន្នជវននោះ ជាលោកជវន ត្រូវបន្ថែមបច្ច័យសភាគ: ២ ទៀត គឺ ១. អារម្មណាធិបតិ , ២. អារម្មណូបនិស្សយ ដែលមានវត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ ជាប្រធាន ។

+ **ចំណុចទី ២ :**

**អរូបិនោ ធម្មា** បានដល់ ចិត្ត ចេតសិក ក្នុងបញ្ចវោការភព ជាបច្ច័យនៃបដិសន្ធិកម្មជរូប និងចិត្តជរូប ដោយសហជាតវិប្បយុត្តប្បច្ច័យ ម្យ៉ាងទៀត ចិត្ត.ចេតសិក ដែលកើតក្រោយ ជាបច្ច័យដល់ចតុ-សមុដ្ឋានិករូប ដែលកើតមុនតាមសមគួរ ដោយបច្ឆាជាតវិប្បយុត្ត-ប្បច្ច័យ ។



**រូបីនំ ធម្មានំ** បានដល់ បច្ចយុប្បន្នធម៌ របស់បច្ច័យទាំង ២ ។

សហជាតវិប្បយុត្តប្បច្ច័យ ក្នុងចំណុចទី ២ នេះ មានបច្ច័យសភាគ: ៦ ដោយសរុប គឺ ១. សហជាត , ២. អញ្ញមញ្ញ , ៣. សហជាតនិស្សយ , ៤. វិបាក , ៥. សហជាតត្ថិ , ៦. សហជាតអ-វិគត ។

បច្ឆាជាតវិប្បយុត្តប្បច្ច័យ មានបច្ច័យសភាគ: ៣ គឺ ១. បច្ឆាជាត , ២. បច្ឆាជាតត្ថិ , ៣. បច្ឆាជាតអវិគត: ។

## សហជាតវិប្បយុត្តប្បច្ច័យ

**បច្ច័យ** = ចិត្ត ៧៥ ដួង ចេតសិក ៥២ ( វៀរទ្វិបញ្ច-វិញ្ញាណ ១០ ដួង អរូបវិបាកចិត្ត ៤ ដួង និងចុតិចិត្តព្រះអរហន្ត ) ក្នុងបញ្ចវោការភព ហទ-យវត្ថុ ក្នុងខណៈបដិសន្ធិ ។

**បច្ចយុប្បន្ន:** = បដិសន្ធិកម្មជរូប ២០ ចិត្តជរូប ១៧ បញ្ច-វោការបដិសន្ធិនាមក្ខន្ធ ៤ ( ចិត្ត ១៥ ចេតសិក ៣៥ ) ។

**បច្ចនិក:** = ចិត្ត ៨៩ ដួង ចេតសិក ៥២ ( វៀរបញ្ចវោ-ការបដិសន្ធិនាមក្ខន្ធ ៤ ) រូប ៥ ពួក ។

\+ **វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ** ដូចគ្នានឹង **វត្ថុបុរេជាតនិស្សយ-បច្ច័យ** ។

\+ **វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ** ដូចគ្នានឹង **វត្ថារម្មណ-បុរេជាតនិស្សយប្បច្ច័យ** ។

\+ **បច្ឆាជាតវិប្បយុត្តប្បច្ច័យ** ដូច **បច្ឆាជាតប្បច្ច័យ** ។

**វិប្បយុត្តៈ** មាន ២ ៖

វិភាវវិប្បយុត្តៈ = វិប្បយុត្តព្រោះមិនមានសភាវៈ ដូចញាណ-វិប្បយុត្ត ឬទិដ្ឋិវិប្បយុត្តជាដើម ។

**វិសំសដ្ឋវិប្បយុត្តៈ** = វិប្បយុត្តដោយមិនប្រឡូកប្រឡំ តែអាចជាបច្ច័យដល់គ្នាបាន បានដល់ វិប្ប-យុត្តបច្ច័យនេះឯង ។

**ដោយលក្ខណៈ ជាតិ** តាមសមគួរដល់បច្ច័យទាំង ៤ ។

**ដោយកាល** = ជាបច្ចុប្បន្នកាល ទាំង ៤ បច្ច័យ ។

**ដោយសត្តិ** = បច្ឆាជាតវិប្បយុត្ត ជាឧបត្ថម្ភកសត្តិតែម្យ៉ាង , បច្ច័យ ៣ ទៀត ដោយសត្តិទាំង ២ ។

### សហជាតវិប្បយុត្ត មាន ៣ បញ្ហាវារៈ

កុ. ⟶ អព្យា. អកុ. ⟶ អកុ. អព្យា. ⟶ អព្យា.



### វត្ថុបុរេជាត មាន ៣ បញ្ហាវារៈ

អព្យា.. ⟶ អព្យា. អព្យា. ⟶ កុ. អព្យា. ⟶ អកុ.

### វត្ថារម្មណបុរេជាត មាន ៣ បញ្ហាវារៈ

អព្យា.. ⟶ អព្យា. អព្យា. ⟶ កុ. អព្យា. ⟶ អកុ.

### បច្ឆាជាតវិប្បយុត្ត មាន ៣ បញ្ហាវារៈ

កុ. ⟶ អព្យា. អកុ. ⟶ អព្យា. អព្យា. ⟶ អព្យា.

---

## ២១. អត្ថិប្បច្ច័យ

មាន ៦ បច្ច័យ :

១. សហជាតត្ថិ ដូចសហជាតប្បច្ច័យ ។

២. បុរេជាតត្ថិ ដូចវត្ថុបុរេជាតប្បច្ច័យ ។

៣. អារម្មណបុរេជាតត្ថិ ដូចអារម្មណបុរេជាតប្បច្ច័យ ។

៤. បច្ឆាជាតត្ថិ ដូចបច្ឆាជាតប្បច្ច័យ ។

៥. អាហារត្ថិ ដូចរូបអាហារប្បច្ច័យ ។

៦. ឥន្ទ្រិយត្ថិ ដូចរូបជីវិតិន្ទ្រិយប្បច្ច័យ ។

**អត្ថិប្បច្ច័យ** គឺ បច្ច័យនោះ នៅមានប្រាកដចំពោះមុខ មិនទាន់ប្រាសទៅ ។

---

## ២២. នត្ថិប្បច្ច័យ

**នត្ថិ** ប្រែថា មិនមាន ព្រោះប្រាសទៅហើយ ដូចអនន្តរប្បច្ច័យដែរ ។

---

## ២៣. វិគតប្បច្ច័យ

**វិគតៈ** ប្រែថា ប្រាសទៅ ជាការបញ្ជាក់ដល់នត្ថិប្បច្ច័យ ដែលថាមិនមាននោះ មិនមែនមិនធ្លាប់មានទេ គ្រាន់តែជាការប្រាសទៅតែប៉ុណ្ណោះ ។



## ២៤. អវិគតប្បច្ច័យ

**អវិគតៈ** ប្រែថា មិនទាន់ប្រាសទៅ បញ្ជាក់ដល់អត្ថិប្បច្ច័យ ដោយសេចក្ដីថា មិនមែនមានរហូតនោះឡើយ គ្រាន់តែមិនទាន់ប្រាសទៅប៉ុណ្ណោះ ។

### បែកបច្ច័យ ២៤ ជា ៤៨ បច្ច័យ

១. ហេតុប្បច្ចយោ

២. អារម្មណប្បច្ចយោ

៣. សហជាតាធិបតិប្បច្ចយោ

៤. អារម្មណាធិបតិប្បច្ចយោ

៥. អនន្តរប្បច្ចយោ

៦. សមនន្តរប្បច្ចយោ

៧. សហជាតប្បច្ចយោ

៨. អញ្ញមញ្ញប្បច្ចយោ

៩. សហជាតនិស្សយប្បច្ចយោ

១០. វត្ថុបុរេជាតនិស្សយប្បច្ចយោ

១១. វត្ថារម្មណបុរេជាតនិស្សយប្បច្ចយោ

១២. អារម្មណូបនិស្សយប្បច្ចយោ

១៣. អនន្តរូបនិស្សយប្បច្ចយោ

១៤. បកតូបនិស្សយប្បច្ចយោ

១៥. វត្ថុបុរេជាតប្បច្ចយោ

១៦. អារម្មណបុរេជាតប្បច្ចយោ

១៧. បច្ឆាជាតប្បច្ចយោ

១៨. អាសេវនប្បច្ចយោ

១៩. សហជាតកម្មប្បច្ចយោ

២០. នានក្ខណិកកម្មប្បច្ចយោ

២១. អនន្តរកម្មប្បច្ចយោ

២២. វិបាកប្បច្ចយោ

២៣. រូបាហារប្បច្ចយោ

២៤. នាមាហារប្បច្ចយោ

២៥. សហជាតិន្ទ្រិយប្បច្ចយោ

២៦. បុរេជាតិន្ទ្រិយប្បច្ចយោ

២៧. រូបជីវិតិន្ទ្រិយប្បច្ចយោ



២៨. ឈានប្បច្ចយោ

២៩. មគ្គប្បច្ចយោ

៣០. សម្បយុត្តប្បច្ចយោ

៣១. សហជាតវិប្បយុត្តប្បច្ចយោ

៣២. វត្ថុបុរេជាតវិប្បយុត្តប្បច្ចយោ

៣៣. វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ចយោ

៣៤. បច្ឆាជាតវិប្បយុត្តប្បច្ចយោ

៣៥. សហជាតត្ថិប្បច្ចយោ

៣៦. វត្ថុបុរេជាតត្ថិប្បច្ចយោ

៣៧. អារម្មណបុរេជាតត្ថិប្បច្ចយោ

៣៨. បច្ឆាជាតត្ថិប្បច្ចយោ

៣៩. អាហារត្ថិប្បច្ចយោ

៤០. ឥន្ទ្រិយត្ថិប្បច្ចយោ

៤១. នត្ថិប្បច្ចយោ

៤២. វិគតប្បច្ចយោ

៤៣. សហជាតាវិគតប្បច្ចយោ

៤៤. វត្ថុបុរេជាតាវិគតប្បច្ចយោ

៤៥. អារម្មណបុរេជាតាវិគតប្បច្ចយោ

៤៦. បច្ឆាជាតាវិគតប្បច្ចយោ

៤៧. អាហារាវិគតប្បច្ចយោ

៤៨. ឥន្ទ្រិយាវិគតប្បច្ចយោ

## ៤៨ បច្ច័យ ចែកដូចតទៅ

### ក. នាមជាបច្ច័យដល់នាម ៨ បច្ច័យ គឺ ៖

១. អនន្តរប្បច្ច័យ , ២. សមនន្តរប្បបច្ច័យ , ៣. អនន្តរូបនិស្សយប្បច្ច័យ , ៤. អាសេវនប្បច្ច័យ , ៥. អនន្តរកម្មប្បច្ច័យ , ៦. សម្បយុត្តប្បច្ច័យ , ៧. នត្ថិប្បច្ច័យ , ៨. វិគតប្បច្ច័យ ។

### ខ. នាមជាបច្ច័យដល់រូប ៤ បច្ច័យ គឺ ៖

១. បច្ឆាជាតប្បច្ច័យ , ២. បច្ឆាជាតវិប្បយុត្តប្បច្ច័យ , ៣. បច្ឆាជាតត្ថិប្បច្ច័យ , ៤. បច្ឆាជាតាវិគតប្បច្ច័យ ។

### គ. នាមជាបច្ច័យដល់នាម.រូប ៩ បច្ច័យ គឺ ៖

១. ហេតុប្បច្ច័យ , ២. សហជាតាធិបតិប្បច្ច័យ , ៣. សហជាតកម្មប្បច្ច័យ , ៤. នានក្ខណិកកម្មប្បច្ច័យ , ៥.វិបាកប្បច្ច័យ , ៦. នាមាហារប្បច្ច័យ , ៧. សហជាតិន្ទ្រិយប្បច្ច័យ , ៨. ឈានប្បច្ច័យ , ៩. មគ្គប្បច្ច័យ ។



### ឃ. រូបជាបច្ច័យដល់រូប ៦ បច្ច័យ គឺ ៖

១. រូបាហារប្បច្ច័យ , ២. រូបជីវិតិន្ទ្រិយប្បច្ច័យ , ៣. អាហារត្ថិប្បច្ច័យ , ៤. ឥន្ទ្រិយត្ថិប្បច្ច័យ , ៥. អាហារាវិគតប្បច្ច័យ , ៦. ឥន្ទ្រិយាវិគតប្បច្ច័យ ។

### ង. រូបជាបច្ច័យដល់នាម ១១ បច្ច័យ គឺ ៖

១. វត្ថុបុរេជាតនិស្សយប្បច្ច័យ , ២. វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ , ៣. វត្ថុបុរេជាតប្បច្ច័យ , ៤. អារម្មណបុរេជាតប្បច្ច័យ , ៥. បុរេជាតិន្ទ្រិយប្បច្ច័យ , ៦. វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ , ៧. វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ , ៨. វត្ថុបុរេជាតត្ថិប្បច្ច័យ , ៩. អារម្មណបុរេជាតត្ថិប្បច្ច័យ , ១០. វត្ថុបុរេជាតាវិគតប្បច្ច័យ , ១១. អារម្មណបុរេជាតាវិគតប្បច្ច័យ ។

**ច. នាម.រូប ជាបច្ច័យដល់នាម ២ បច្ច័យ គឺ ៖**

១. អារម្មណាធិបតិប្បច្ច័យ , ២. អារម្មណូបនិស្សយប្បច្ច័យ ។

( នាមក្នុងទីនេះ មាននិព្វានផង ) ។

**ឆ. នាម.រូប ជាបច្ច័យដល់នាម.រូប ៦ បច្ច័យ គឺ ៖**

១. សហជាតប្បច្ច័យ , ២. អញ្ញមញ្ញប្បច្ច័យ , ៣. សហជាត- និស្សយប្បច្ច័យ , ៤. សហជាតវិប្បយុត្តប្បច្ច័យ , ៥. សហជាតត្ថិ- ប្បច្ច័យ , ៦. សហជាតាវិគតប្បច្ច័យ ។

**ជ. នាម.រូប និងបញ្ញត្តិ ដល់នាម ២ បច្ច័យ គឺ ៖**

១. អារម្មណប្បច្ច័យ , ២. បកតូបនិស្សយប្បច្ច័យ ។

## ចែកបច្ច័យតាមភូមិ

**២៤ បច្ច័យ ឬ ៤៨ បច្ច័យ** ប្រព្រឹត្តទៅក្នុងបញ្ចវោការភូមិ ទាំងអស់ ។



**២១ បច្ច័យ ឬ ២៦ បច្ច័យ មានក្នុងចតុវោការភូមិ ៖**

១.ហេតុប្បច្ច័យ , ២.អារម្មណប្បច្ច័យ , ៣.អធិបតិប្បច្ច័យទាំង ២ , ៤.អនន្តរប្បច្ច័យ , ៥.សមនន្តរប្បច្ច័យ , ៦.សហជាតប្បច្ច័យ , ៧.អញ្ញមញ្ញប្បច្ច័យ , ៨.សហជាតនិស្សយប្បច្ច័យ , ៩.ឧបនិស្សយ- ប្បច្ច័យ ទាំង ៣ , ១០.អាសេវនប្បច្ច័យ , ១១.កម្មប្បច្ច័យទាំង ៣ , ១២.វិបាកប្បច្ច័យ , ១៣.នាមាហារប្បច្ច័យ , ១៤.សហជាតិន្ទ្រិយប្ប- ច្ច័យ , ១៥.ឈានប្បច្ច័យ , ១៦.មគ្គប្បច្ច័យ , ១៧.សម្បយុត្តប្បច្ច័យ , ១៨.សហជាតត្ថិប្បច្ច័យ , ១៩.នត្ថិប្បច្ច័យ , ២០.វិគតប្បច្ច័យ , ២១. សហជាតាវិគតប្បច្ច័យ ។

**៧ បច្ច័យ ឬ ៩ បច្ច័យ មានក្នុងឯកវោការភព ៖**

១.សហជាតប្បច្ច័យ , ២.អញ្ញមញ្ញប្បច្ច័យ , ៣.សហជាតនិ- ស្សយប្បច្ច័យ , ៤.នានក្ខណិកកម្មប្បច្ច័យ , ៥.រូបជីវិតិន្ទ្រិយប្បច្ច័យ , ៦.អត្ថិប្បច្ច័យ ២ បច្ច័យ ( សហជាតត្ថិ និងឥន្ទ្រិយត្ថិ ) , ៧.អវិគត- ប្បច្ច័យ ២ បច្ច័យ ( សហជាតាវិគត និងឥន្ទ្រិយាវិគត ) ។

**៥ បច្ច័យ មានក្នុងធម្មជាតិក្រៅពីមនុស្សសត្វ ៖**

១.សហជាតប្បច្ច័យ , ២.អញ្ញមញ្ញប្បច្ច័យ , ៣.សហជាតនិ-

ស្សយប្បច្ច័យ , ៤.សហជាតត្ថិប្បច្ច័យ , ៥.សហជាតាវិគតប្បច្ច័យ ។

**៦ បច្ច័យ តែងប្រព្រឹត្តទៅបានភូមិទាំង ៣ គឺ ៖**

១.សហជាតប្បច្ច័យ , ២.អញ្ញមញ្ញប្បច្ច័យ , ៣.សហជាតនិស្សយប្បច្ច័យ , ៤.នានក្ខណិកកម្មប្បច្ច័យ , ៥.សហជាតត្ថិប្បច្ច័យ , ៦.សហជាតាវិគតប្បច្ច័យ ។

**៤ បច្ច័យ ប្រព្រឹត្តទៅក្នុងសន្តតធម៌ ទាំងរូប.ទាំងនាម ទាំងមានជីវិត.អត់ជីវិតក្តី** ហៅថា " **សព្វត្ថានិកប្បច្ច័យ** " បួនបច្ច័យ គឺ ៖

១.សហជាតប្បច្ច័យ , ២.សហជាតនិស្សយប្បច្ច័យ , ៣.សហតត្ថិប្បច្ច័យ , ៤.សហជាតាវិគតប្បច្ច័យ ។

**៤៤ បច្ច័យទៀត ជាអសព្វត្ថានិកប្បច្ច័យ ។**

## ជាតិនៃបច្ច័យទាំងអស់មាន ៩ ជាតិ

១.សហជាត ជាតិ

២.អារម្មណជាតិ

៣.អនន្តរជាតិ



៤.បុរេជាត ជាតិ

៥.បច្ឆាជាត ជាតិ

៦.អាហារជាតិ

៧.រូបជីវិតិន្ទ្រិយជាតិ

៨.បកតូបនិស្សយជាតិ

៩.នានក្ខណិកកម្មជាតិ

## ក- ១៥ បច្ច័យ ជាសហជាត ជាតិ ៖

១.ហេតុប្បច្ច័យ , ២.សហជាតាធិបតិ , ៣.សហជាតប្បច្ច័យ , ៤.អញ្ញមញ្ញប្បច្ច័យ , ៥.សហជាតនិស្សយប្បច្ច័យ , ៦.សហជាតកម្មប្បច្ច័យ , ៧.វិបាកប្បច្ច័យ , ៨.នាមាហារប្បច្ច័យ , ៩.សហជាតិន្ទ្រិយប្បច្ច័យ , ១០.ឈានប្បច្ច័យ , ១១.មគ្គប្បច្ច័យ , ១២.សម្បយុត្តប្បច្ច័យ , ១៣.សហជាតវិប្បយុត្តប្បច្ច័យ , ១៤.សហជាតត្ថិប្បច្ច័យ , ១៥.សហជាតាវិគតប្បច្ច័យ ។

## សហជាត ជាតិ មាន ៣ ពួក ៖

**១. សហជាត ជាតិ ធំ មាន ៤ បច្ច័យ គឺ :**

១.សហជាតប្បច្ច័យ , ២.សហជាតនិស្សយប្បច្ច័យ , ៣.សហជាតត្ថិប្បច្ច័យ , ៤.សហជាតាវិគតប្បច្ច័យ ។

**២. សហជាត ជាតិ កណ្តាល មាន ៤ បច្ច័យ គឺ :**

១.អញ្ញមញ្ញប្បច្ច័យ , ២.វិបាកប្បច្ច័យ , ៣.សម្បយុត្តប្បច្ច័យ , ៤.សហជាតវិប្បយុត្តប្បច្ច័យ ។

**៣. សហជាត ជាតិ តូច មាន ៧ បច្ច័យ គឺ :**

១.ហេតុប្បច្ច័យ , ២.សហជាតាធិបតិប្បច្ច័យ , ៣.សហជាតកម្មប្បច្ច័យ , ៤.នាមាហារប្បច្ច័យ , ៥.សហជាតិន្ទ្រិយប្បច្ច័យ , ៦.ឈានប្បច្ច័យ , ៧.មគ្គប្បច្ច័យ ។

## ខ- ៨ បច្ច័យ ជាអារម្មណជាតិ គឺ :

១.អារម្មណប្បច្ច័យ , ២.អារម្មណាធិបតិប្បច្ច័យ , ៣.វត្ថារម្មណបុរេជាតនិស្សយប្បច្ច័យ , ៤.អារម្មណូបនិស្សយប្បច្ច័យ , ៥.អារម្មណបុរេជាតប្បច្ច័យ , ៦.វត្ថារម្មណបុរេជាតវិប្បយុត្តប្បច្ច័យ , ៧.អារម្មណបុរេជាតត្ថិប្បច្ច័យ , ៨.អារម្មណបុរេជាតាវិគតប្បច្ច័យ ។



## គ- ៧ បច្ច័យ ជាអនន្តរជាតិ គឺ :

១.អនន្តរប្បច្ច័យ , ២.សមនន្តរប្បច្ច័យ , ៣.អនន្តរូបនិស្សយប្បច្ច័យ , ៤.អាសេវនប្បច្ច័យ , ៥.អនន្តរកម្មប្បច្ច័យ , ៦.នត្ថិប្បច្ច័យ , ៧.វិគតប្បច្ច័យ ។

## ឃ- ៦ បច្ច័យ ជាវត្ថុបុរេជាត ជាតិ គឺ :

១.វត្ថុបុរេជាតនិស្សយប្បច្ច័យ , ២.វត្ថុបុរេជាតប្បច្ច័យ , ៣.បុរេជាតិន្ទ្រិយប្បច្ច័យ , ៤.វត្ថុបុរេជាតវិប្បយុត្តប្បច្ច័យ , ៥.វត្ថុបុរេជាតត្ថិប្បច្ច័យ , ៦.វត្ថុបុរេជាតាវិគតប្បច្ច័យ ។

## ង- ៤ បច្ច័យ ជាបច្ឆាជាត ជាតិ គឺ :

១.បច្ឆាជាតប្បច្ច័យ , ២.បច្ឆាជាតវិប្បយុត្តប្បច្ច័យ , ៣.បច្ឆាជាតត្ថិប្បច្ច័យ , ៤.បច្ឆាជាតាវិគតប្បច្ច័យ ។

## ច- ៣ បច្ច័យ ជាអាហារជាតិ គឺ :

១.រូបាហារប្បច្ច័យ , ២.អាហារត្ថិប្បច្ច័យ , ៣.អាហារាវិគតប្បច្ច័យ ។

**ឆ- ៣ បច្ច័យ ជារូបជីវិតិន្ទ្រិយជាតិ គឺ :**

១.រូបជីវិតិន្ទ្រិយប្បច្ច័យ , ២.ឥន្ទ្រិយត្ថិប្បច្ច័យ , ៣.ឥន្ទ្រិយាវិគតប្បច្ច័យ ។

**ជ- បកតូបនិស្សយប្បច្ច័យ**

ជាបកតូបនិស្សយជាតិ ( សុទ្ធ.+មិស្សក. ) ។

**ឈ- នានក្ខណិកកម្មប្បច្ច័យ**

ជានានក្ខណិកកម្មជាតិ ។

**ដោយកាល មាន ៣ ពួក**

**១- ៤ បច្ច័យ ប្រព្រឹត្តទៅក្នុងកាលទាំង ៣ និងកាលវិមុត្តិ :**

១.អារម្មណប្បច្ច័យ , ២.អារម្មណាធិបតិប្បច្ច័យ , ៣.អារម្មណូបនិស្សយប្បច្ច័យ , ៤.បកតូបនិស្សយប្បច្ច័យ ( ៣ បច្ច័យខាងដើម មានព្រះនិព្វាន , អារម្មណៈ និងបកតូ មានបញ្ញត្តិ ) ។

**២- ៨ បច្ច័យ ជាអតីតកាល :**

១.អនន្តរប្បច្ច័យ , ២.សមនន្តរប្បច្ច័យ , ៣.អនន្តរូបនិស្សយប្បច្ច័យ , ៤.អាសេវនប្បច្ច័យ , ៥.នានក្ខណិកកម្មប្បច្ច័យ , ៦.អនន្តរកម្មប្បច្ច័យ , ៧.នត្ថិប្បច្ច័យ ,៨.វិគតប្បច្ច័យ ។



**៣- ៣៦ បច្ច័យទៀត** ជាបច្ចុប្បន្នកាល ។

**ដោយសត្តិ មាន ៤ ក្រុម :**

**១- ជនកសត្តិ មាន ៩ បច្ច័យ គឺ :**

១.អនន្តរប្បច្ច័យ , ២.សមនន្តរប្បច្ច័យ , ៣.អនន្តរូបនិស្សយប្បច្ច័យ , ៤.បកតូបនិស្សយប្បច្ច័យ , ៥.អាសេវនប្បច្ច័យ , ៦.នានក្ខណិកកម្មប្បច្ច័យ , ៧.អនន្តរកម្មប្បច្ច័យ , ៨.នត្ថិប្បច្ច័យ , ៩.វិគតប្បច្ច័យ ។

**២- ឧបត្ថម្ភកសត្តិ មាន ៤ បច្ច័យ គឺ :**

១.បច្ឆាជាតប្បច្ច័យ , ២.បច្ឆាជាតវិប្បយុត្តប្បច្ច័យ , ៣.បច្ឆាតត្ថិប្បច្ច័យ , បច្ឆាជាតាវិគតប្បច្ច័យ ។

**៣- អនុបាលសត្តិ ៣ បច្ច័យ គឺ :**

១.រូបជីវិតិន្ទ្រិយប្បច្ច័យ , ២.ឥន្ទ្រិយត្ថិប្បច្ច័យ , ៣.ឥន្ទ្រិយាវិ-

គតប្បច្ច័យ ។

**៤- នៅ ៣២ បច្ច័យទៀត** ជាជនកសត្តិ និងឧបត្ថម្ភកសត្តិ ។

\+ ក្នុងអដ្ឋកថាបញ្ចបករណៈ ប្រាប់ថា បច្ច័យ ៣ គឺ :

១.រូបាហារប្បច្ច័យ , ២.អាហារត្ថិប្បច្ច័យ , ៣.អាហារាវិគតប្បច្ច័យ ជាជនកសត្តិ និងអនុបាលកសត្តិ ។

## គូនៃបច្ច័យ ៥ ឈ្មោះ

**១- អត្ថយុគ** ជាគូដោយអត្ថន័យ (អនន្តរ+សមនន្តរ )

**២- សទ្ទយុគ** ជាគូដោយការបញ្ចេញសំឡេងពោល គឺ និស្សយប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

**៣- កាលបដិបក្ខយុគ** គូបដិបក្ខចំពោះកាលមុន.ក្រោយ គឺ បុរេជាតប្បច្ច័យ និងបច្ឆាជាតប្បច្ច័យ ។

**៤- អញ្ញោញ្ញបដិបក្ខយុគ** គូបដិបក្ខដោយលក្ខណៈ អាការផ្ទុយគ្នា មាន ៣ គូ គឺ :

គូទី ១- សម្បយុត្ត និងវិប្បយុត្ត ។

គូទី ២- អត្ថិ និងនត្ថិ ។

គូទី ៣- វិគតៈ និងអវិគតៈ ។

**៥- ហេតុប្ផលយុគ** គូដោយហេតុ.ផល គឺ កម្មប្បច្ច័យ ( នានក្ខណិក+អនន្តរកម្ម ) និងវិបាកប្បច្ច័យ ។

**\+ ក្រៅអំពី ១៤ បច្ច័យ ខាងលើ ជាបច្ច័យអត់គូ ។**



ការសិក្សាចប់ដោយបរិបូរណ៍ នៅថ្ងៃ ១២ កើត ខែ អស្សុជ ឆ្នាំ ច ព.ស ២៥៥០

ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០០៦